ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៦-២០២៨

*« ដើម្បីរក្សាលំនឹងជីវភាពប្រជាជន និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការពង្រឹងប្រសិទ្ធភាព និង ធានាចីរភាពហិរញ្ញវត្ថុសាធារណៈ សំដៅលើកកម្ពស់សមធម៌សង្គម ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងជំរុញការអភិវឌ្ឍ ឆ្ពោះទៅចក្ខុវិស័យកម្ពុជា ២០៥០»*

ខែ មេសា ឆ្នាំ ២០២៥

# បុព្វកថា

ទោះបីជាកម្ពុជាបានឆ្លងផុតវិបត្តិជំងឺកូវីដ-១៩ ដោយជោគជ័យ តែជារួម ស្លាកស្នាមដែលនៅសេសសល់ពីវិបត្តិនេះ នៅជះឥទ្ធិពលដល់ការអភិវឌ្ឍរបស់កម្ពុជា នៅឡើយ, ខណៈដែលសកលលោក និង តំបន់ ក៏ដូចជាកម្ពុជា កំពុងស្ថិតក្នុងអន្តរកាលនៃពហុវិបត្តិ, ជាពិសេសការកើនឡើងកាន់តែខ្លាំងនូវគោលនយោបាយគាំពារនិយម (Protectionism) និង សង្គ្រាមពាណិជ្ជកម្ម, ភាពតានតឹងនៃការប្រកួតប្រជែងភូមិសាស្ត្រសេដ្ឋកិច្ច និងនយោបាយ, និង ផលប៉ះពាល់កាន់តែធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ។ ថ្មីៗនេះ, គោលនយោបាយពន្ធគយបដិការ របស់សហរដ្ឋអាម៉េរិក ដែលមានចរិតសកល បានបង្កជាកម្មវិបាកជាអវិជ្ជមាន ទៅលើនិន្នាការសេដ្ឋកិច្ចសកល និង តំបន់, រួមទាំងកម្ពុជា ផងដែរ ។

ក្រោយពីបានចាប់ផ្តើមបើកប្រទេសឡើងវិញក្នុងចុងឆ្នាំ ២០២១, សេដ្ឋកិច្ចកម្ពុជាលើគ្រប់វិស័យ បានបន្តងើបឡើងជាបន្តបន្ទាប់, ដែលក្នុងឆ្នាំ ២០២៣ កម្ពុជាសម្រេចបានកំណើន ៥% និង ក្នុងឆ្នាំ ២០២៤ សម្រេចបានកំណើនក្នុងអត្រា ៦% ហើយទំហំពាណិជ្ជកម្មអន្តរជាតិ, ទាំងការនាំចេញ និងការនាំចូល, បានកើនឡើងគួរឱ្យកត់សម្គាល់ ។ លើទិដ្ឋភាពហិរញ្ញវត្ថុសាធារណៈវិញ ការប្រមូលចំណូលថវិកាជាតិក្នុងឆ្នាំ ២០២៤ សម្រេចបានកំណើនវិជ្ជមានក្នុងអត្រាប្រមាណ ២,៤% ធៀបនឹងការអនុវត្តឆ្នាំ ២០២៣ ខណៈចំណាយសរុបត្រូវបានធ្វើវិចារណកម្ម និងគ្រប់គ្រងដោយប្រយ័ត្នប្រយែង ហើយរាជរដ្ឋាភិបាលក៏នៅតែអាចទ្រទ្រង់ប្រតិបត្តិការចាំបាច់គ្រប់ផ្នែក និងរក្សាបាននូវចលនការកែទម្រង់សំខាន់ៗ ផងដែរ ។

មុនការដាក់ចេញគោលនយោបាយពន្ធគយបដិការ កាលពីថ្ងៃទី ២ ខែមេសា, កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានវាយតម្លៃថានឹងបន្តចលនការប្រសើរ ក្នុងរង្វង់ ៦,៣% សម្រាប់ឆ្នាំ ២០២៥ និង ២០២៦ និង ៦,៥% សម្រាប់រយៈពេលមធ្យមខាងមុខ ។ យ៉ាងណាមិញ, កំណើននេះ ត្រូវបានវាយតម្លៃជាថ្មីឡើងវិញថានឹងថមថយបន្តិចវិញ និងមានវេទយិតភាពខ្ពស់ ចំពោះទៅនឹងការវិវត្តនៃសភាពការណ៍ ដែលពិបាកនឹងប៉ាន់ស្មានជាមុនបាន ។

ក្នុងបរិបទថ្មីប្រកបដោយភាពមិនប្រាកដប្រជាខ្ពស់នេះ, ទស្សនវិស័យកំណើនសេដ្ឋកិច្ចកម្ពុជា ត្រូវបានកែ-សម្រួលមកនៅត្រឹមអត្រា **៥,២% និង ៥,០% រៀងគ្នា សម្រាប់ឆ្នាំ ២០២៥ និង ២០២៦ និងប្រមាណជា ៥,៦%** សម្រាប់រយៈពេលមធ្យម ។ គួរកត់សម្គាល់ផងដែរថា, ការវាយតម្លៃឡើងវិញលើកំណើននេះ ក៏មាននិន្នាការស្រដៀងគ្នាទៅនឹងស្ថាប័នអន្តរជាតិធំៗ ដែលបានកែតម្រូវកំណើនសេដ្ឋកិច្ចកម្ពុជាពីការព្យាករគោលដែលត្រូវបានដាក់ចេញកាលពីដើមឆ្នាំ ២០២៥ នេះ ដោយនៅរក្សាបានកំណើនក្នុងកម្រិតសមរម្យ តួយ៉ាងដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានកែតម្រូវកំណើនសេដ្ឋកិច្ចកម្ពុជាពីអត្រា ៥,៨% និង ៦,២% មកក្នុងអត្រា ៤% និង ៣,៤%, ធនាគារពិភពលោក ពី ៥,៤% និង ៥,៤% មក ៤% និង ៤,៥%, និងការិយាល័យស្រាវជ្រាវម៉ាក្រូ-សេដ្ឋកិច្ចអាស៊ានបូកបី (AMRO) ពី ៥,៨% និង ៦,០% មក ៤,៩% និង ៤,៧%, សម្រាប់ឆ្នាំ ២០២៥ និង ២០២៦ រៀងគ្នា ។

ខាងទិដ្ឋភាពថវិកាសម្រាប់រយៈពេលមធ្យម, ផ្នែកចំណូលអាចនឹងសម្រេចបានកំណើនយឺត ដោយសារចំណូលសារពើពន្ធពីវិស័យសក្តានុពលមួយចំនួន អាចនឹងត្រូវថមថយ គួបផ្សំនឹងការបន្តអនុវត្តវិធានការលើកទឹកចិត្តពន្ធដែលមានស្រាប់ ខណៈមូលដ្ឋានចំណូល, ទាំងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ, នៅមានភាពតូចចង្អៀត និងប្រមូលផ្តុំ ។ ទន្ទឹមនេះ, តម្រូវការចំណាយថវិកាកាន់តែមាននិន្នាការកើនឡើងក្នុងបរិការណ៍ក្រោយវិបត្តិជំងឺកូវីដ-១៩ សម្រាប់បន្តដោះស្រាយបញ្ហាដែលនៅសេសសល់ និងគ្រប់គ្រងស្ថាន-ការណ៍បច្ចុប្បន្ន ក៏ដូចជាដើម្បីជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ និងកសាងមូលដ្ឋានសង្គម-សេដ្ឋកិច្ចថ្មី ដែលមាន

ភាពធន់នឹងវិបត្តិ, ខណៈដែលលម្ហថវិកាក៏កាន់តែរួមតូច ។ ការណ៍នេះ ទាមទារឱ្យមានការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ដោយមានការគិតគូរទាំងស្ថានភាពចំពោះមុខ និងសម្រាប់រយៈពេលមធ្យមទៅមុខ ដើម្បីធានាឱ្យបាននូវស្ថិរភាពនៃកំណើនសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាធានាបន្តការកែលម្អជីវភាពរបស់ប្រជាពលរដ្ឋ ។

ដូចឆ្នាំមុនដែរ **«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៦-២០២៨»** ឬ ហៅខ្លីថា **«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨»** ត្រូវបានរៀបចំជាឯកសារគោល ដោយផ្ដល់នូវទស្សនវិស័យ និងតម្រង់ទិសការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ស្របតាមទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះ អាទិភាពចំពោះមុខ គឺគ្រប់គ្រងផលប៉ះពាល់ពីកត្តាខាងក្រៅដែលកំពុងកើតមាន ដោយប្រឹងប្រែងរក្សាឱ្យបានល្អនូវលំនឹងជីវភាពប្រជាពលរដ្ឋ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច គួបផ្សំជាមួយនឹងកិច្ចប្រឹងប្រែងបន្តជំរុញកំណើនសេដ្ឋកិច្ចដែលមានចីរភាព, ពិពិធកម្ម និងភាពធន់ ។ ជារួម, ការរៀបចំ **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨** មានគោលបំណងសំខាន់ៗចំនួន ៣ រួមមាន៖ (១). គាំទ្រការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល, (២). ពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល និងការវិភាជថវិកា, និង (៣). ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ ។ បន្ថែមលើនេះ, **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨** ក៏មានតួនាទីបង្កើនតម្លាភាពនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងជាមូលដ្ឋានសម្រាប់ការរៀបចំ **ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨** និង **សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦** ផងដែរ ។ **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨** នេះ ត្រូវបានរៀបចំក្នុងទម្រង់ ៣ ឆ្នាំរំកិល ដើម្បីគាំទ្រគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដោយពិចារណាលើធនធានដែលអាចកៀរគរបាន និងប្រកបដោយភាពបត់បែន ដោយផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងដោយមានការកំណត់នូវវិធានផ្សេងៗ សម្រាប់ធានានូវចីរភាពហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការវិភាគនូវហានិភ័យហិរញ្ញវត្ថុសាធារណៈ ផងដែរ ។

ឈរលើស្មារតីនេះ, **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨** កំណត់ទស្សនវិស័យកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងអត្រាដូចបានលើកឡើងខាងលើ ដោយឈរលើគោលគំនិតនៃការគិតគូរដែលមានសុទិដ្ឋិនិយមប្រយ័ត្នប្រយែង និងមិនទុទិដ្ឋិនិយមជ្រុល ហើយទាមទារឱ្យភាគីពាក់ព័ន្ធទាំងអស់, ទាំងរាជរដ្ឋាភិបាល និងវិស័យឯកជន, បន្តខិតខំប្រឹងប្រែងក្នុងការធ្វើពិពិធកម្ម, លើកកម្ពស់ភាពប្រកួតប្រជែង និងកសាងភាពធន់ ក៏ដូចជាការខិតខំឈ្មុសឈ្មុលរក្សាលក្ខខណ្ឌអំណោយផលសម្រាប់ការនាំចេញ ។ លើទិដ្ឋភាពហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលនឹងបន្តប្រកាន់យកនូវ **«ជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន (Gradual Fiscal Consolidation Stance)»** ដើម្បីធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម និងចាប់ផ្ដើមកសាងទុនបម្រុងថវិកាជាតិឡើងវិញ នៅពេលកាលៈទេសៈអនុញ្ញាត តាមរយៈការបន្តពង្រឹងការកៀរគរ និងពង្រីកមូលដ្ឋានចំណូល ព្រមទាំងសិក្សា និងធ្វើវិចារណកម្មចំណាយសារពើពន្ធក្រោមវិធានការលើកទឹកចិត្តដែលមានស្រាប់, ខណៈបង្កើនភាពប្រយ័ត្នប្រយែងខ្ពស់ ចំពោះករណីលើកលែងពន្ធថ្មីណាមួយ ។ ចំណាយសាធារណៈនឹងត្រូវបានរៀបចំប្រកបដោយភាពបត់បែន និងស្មារតីប្រុងប្រយ័ត្នខ្ពស់ ដោយផ្ដោតលើការបន្តពង្រឹងប្រសិទ្ធភាពថវិកា, ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ, តាមរយៈការបន្តធ្វើអាទិភាវូបនីយកម្មចំណាយឱ្យចំគោលដៅ, ជាពិសេសក្នុងវិស័យដែលរងកម្មវិបាកពីភាពមិនប្រាកដប្រជា ក្នុងគោលបំណងធានាលំនឹងជីវភាពប្រជាជន

និងលើកកម្ពស់សមធម៌សង្គម ព្រមទាំងធានាឱ្យបាននូវលទ្ធភាព ក្នុងការទ្រទ្រង់ដំណើរការនៃកិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, និរន្តរភាពប្រតិបត្តិការការងារ, ចលនការកែទម្រង់ និងការអនុវត្តកម្មវិធីគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ។

**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨ គ្រោងការប្រមូលចំណូលចរន្តឱ្យមានកំណើនជាមធ្យម ក្នុងរង្វង់ ៧,០% សម្រាប់ឆ្នាំ ២០២៦-២០២៨ ដែលក្នុងនោះ សម្រាប់ឆ្នាំ ២០២៦ មានកំណើន ៥,៩% សមមូលនឹង ១៤,១៣% នៃ ផ.ស.ស. ។ ចំណាយសាធារណៈសរុប ត្រូវបានគ្រោងនឹងមានកំណើនជាមធ្យម ៤,៦% ក្នុងមួយឆ្នាំ ដែលក្នុងនោះ ចំណាយចរន្តសម្រាប់ឆ្នាំ ២០២៦ គ្រោងក្នុងកំណើនប្រមាណ ២,៥% សមមូលនឹង ១២,០៥% នៃ ផ.ស.ស. ។ ជាលទ្ធផល, ឱនភាពថវិកានឹងថមថយមកត្រឹមរង្វង់ -២,២០% នៃ ផ.ស.ស. ជាមធ្យម សម្រាប់ឆ្នាំ ២០២៦-២០២៨ ដែលក្នុងនោះ សម្រាប់ឆ្នាំ ២០២៦ មានទំហំប្រមាណ -២,១៩% នៃ ផ.ស.ស. ។ ជារួម, ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ធានាបាននូវចីរភាព អនុលោមតាមសូចនាករសំខាន់ៗ ដែលត្រូវបានកំណត់នៅក្រោមយុថ្កាហិរញ្ញវត្ថុ និង នៅក្នុងវិធានប្រតិបត្តិ ។**

ក្នុងនាមរាជរដ្ឋាភិបាល, ខ្ញុំសម្រេចដាក់ចេញនូវ **«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៦-២០២៨»** ដែលនឹងក្លាយជាឧបករណ៍ដ៏សំខាន់ សម្រាប់រាជរដ្ឋាភិបាល ក្នុងការអនុវត្តវិធានការគោល-នយោបាយនានា ប្រកបដោយភាពម្ចាស់ការ សំដៅរក្សាបាននូវលំនឹងជីវភាពប្រជាជន, ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការពង្រឹង និងការពង្រីកសសរស្តម្ភសេដ្ឋកិច្ចជាតិឱ្យមានជវភាព, ពិពិធភាព, ភាពរឹងមាំ និងភាពធន់ ។ ខ្ញុំសូមបញ្ជាក់ថា នេះគឺជាលើកទីពីរនៃការដាក់ចេញក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម បន្ទាប់ពីការដាក់ឱ្យប្រើប្រាស់ជាផ្លូវការលើកដំបូងក្នុងឆ្នាំ ២០២៤ ទោះបីកម្ពុជាស្ថិតនៅក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាខ្ពស់ ដែលបង្កជាបញ្ហាប្រឈមជាច្រើនសម្រាប់វាយតម្លៃទស្សនវិស័យរយៈពេលមធ្យមក្តី ។ រាជរដ្ឋាភិបាលនឹងបន្តតាមដាន ដោយយកចិត្តទុកដាក់លើការវិវត្ត និងវាយតម្លៃសភាពការណ៍ឡើងវិញ មុនពេលរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ ដើម្បីកែសម្រួលក្របខ័ណ្ឌនេះតាមការចាំបាច់ និងតាមការណ៍ជាក់ស្តែង ជាពិសេសក្នុងកាលៈទេសៈដែលសភាពការណ៍មិនអំណោយផល ។

ថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# មាតិកា


**បុព្វកថា** ........ ii

**១. បរិការណ៍រួម** ........ ១

**២. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច** ........ ៤

**២.១. បរិការណ៍សេដ្ឋកិច្ចសកល** ........ ៤

**២.២. ទិដ្ឋភាពសេដ្ឋកិច្ចកម្ពុជា** ........ ៦

ក. សមិទ្ធផលសេដ្ឋកិច្ចឆ្នាំ ២០២៤ និងទស្សនវិស័យ ឆ្នាំ ២០២៥ ........ ៦

ខ. ទស្សនវិស័យសេដ្ឋកិច្ចរយៈពេលមធ្យម ឆ្នាំ ២០២៦-២០២៨ ........ ៧

គ. ហានិភ័យ និងទិសដៅគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ........ ២១

**៣. យុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈ** ........ ២៣

**៣.១. ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ** ........ ២៣

**៣.២. វិធានហិរញ្ញវត្ថុសាធារណៈ** ........ ២៤

ក. យុថ្កាហិរញ្ញវត្ថុសាធារណៈ ........ ២៤

ខ. វិធានប្រតិបត្តិ ........ ២៥

**៣.៣. អាទិភាពគោលនយោបាយ** ........ ២៥

**៤. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ** ........ ២៦

**៤.១. ការអនុវត្តថវិកា ឆ្នាំ ២០២៤ និង ២០២៥** ........ ២៦

ក. ការអនុវត្តថវិកា ឆ្នាំ ២០២៤ ........ ២៦

ខ. ការប៉ាន់ស្មានការអនុវត្តថវិកាឆ្នាំ ២០២៥ ........ ២៨

គ. លទ្ធផលអនុវត្តថវិកាធៀបទៅនឹងវិធានហិរញ្ញវត្ថុសាធារណៈ ........ ២៩

**៤.២. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៦-២០២៨** ........ ២៩

ក. ក្របខ័ណ្ឌចំណូល ........ ៣០

ខ. ក្របខ័ណ្ឌចំណាយសាធារណៈ ........ ៣៥

គ. ឱនភាពថវិកា និងហិរញ្ញប្បទាន ........ ៤០

ឃ. លទ្ធផលក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមធៀបទៅនឹងវិធានហិរញ្ញវត្ថុសាធារណៈ ........ ៤១

**៥. ហានិភ័យហិរញ្ញវត្ថុសាធារណៈ** ........ ៤២

ក. ហានិភ័យម៉ាក្រូសេដ្ឋកិច្ច ........ ៤៣

ខ. ភាពជាដៃគូរវាងរដ្ឋ និងឯកជន ........ ៤៥

គ. ហានិភ័យបំណុលរបស់រដ្ឋាភិបាល ........ ៤៦
ឃ. ហានិភ័យពីសហគ្រាសសាធារណៈ និងការវិនិយោគសាធារណៈ ........ ៤៦
ង. ហានិភ័យពីវិស័យហិរញ្ញវត្ថុ ........ ៤៧
ច. ភាពជឿទុកចិត្តបាននៃក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ........ ៤៧
**៦. សេចក្តីសន្និដ្ឋាន ........ ៤៨**
**ឧបសម្ព័ន្ធ ........ ៥០**
**ឧបសម្ព័ន្ធ ក៖ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២២-២០២៨ ........ ៥០**
**ឧបសម្ព័ន្ធ ខ៖ ក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ឆ្នាំ ២០២៤-២០២៨ ........ ៥១**
**ឧបសម្ព័ន្ធ គ៖ ការបែងចែកចំណាយថ្នាក់ជាតិតាមវិស័យ ........ ៥៣**

## ១. បរិការណ៍រួម

សន្តិភាពពេញលេញ, ស្ថិរភាពនយោបាយ និងសន្តិសុខសង្គម ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ បានបង្កើតជាមូលដ្ឋានគ្រឹះដ៏ចាំបាច់ ក្នុងការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ចីរភាពកំណើន, និងរចនាសម្ព័ន្ធសេដ្ឋកិច្ចដែលកាន់តែមានពិពិធភាព, ដែលរួមចំណែកជំរុញការអភិវឌ្ឍលើគ្រប់វិស័យ, ពង្រឹងភាពធន់សង្គម-សេដ្ឋកិច្ច, និង លើកកម្ពស់ជីវភាព និងសុខុមាលភាពប្រជាជន, ជាពិសេសតាមរយៈការ-ដាក់ឱ្យអនុវត្តប្រព័ន្ធគាំពារសង្គមដែលមានវិសាលភាពគ្របដណ្តប់ប្រសើរជាងមុន និងកាន់តែមានបរិយាប័ន្ន ។ កិច្ចខិតខំប្រឹងប្រែងកាន់តែមោះមុតក្នុង**ការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងការតភ្ជាប់ទៅនឹងច្រវាក់ផ្គត់ផ្គង់តំបន់ និងសកល, ការកែសម្រួលបរិយាកាសវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម ដើម្បីទាក់ទាញវិនិយោគថ្មីៗបន្ថែម, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសារវន្តដើម្បីបង្កើនការតភ្ជាប់, ការបន្តអភិវឌ្ឍមូលធនមនុស្ស, និងការកែទម្រង់ស្ថាប័ន និងអភិបាលកិច្ច** បានបង្កលក្ខណៈឱ្យកម្ពុជាសម្រេចបាននូវបង្គោលចរអភិវឌ្ឍន៍ជាបន្តបន្ទាប់ ដែលរួមមាន ការ-ចាកចេញពីឋានៈជាប្រទេសដែលមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក្នុងឆ្នាំ ២០១៥ និងបន្តត្រៀមខ្លួនចាកចេញពី **ចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួច** នៅឆ្នាំ ២០២៩ ខាងមុខ ។ ក្នុងរយៈពេលជាងពីរទសវត្សរ៍នេះ, កម្ពុជាសម្រេចបានគួរជាទីមោទនៈ នូវការកសាងភាពធន់គន្លឹះទាំង ៥ គឺ ភាពធន់នៃស្ថាប័នសាធារណៈ, ភាពធន់នៃសេដ្ឋកិច្ច, ភាពធន់នៃសង្គម និងប្រជាជន, ភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ, និង ភាពធន់នៃបរិស្ថាន និងអាកាសធាតុ ។ ភាពធន់ទាំង ៥ នេះហើយ ដែលអនុញ្ញាតឱ្យកម្ពុជាឆ្លងកាត់វិបត្តិជំងឺកូវីដ-១៩ ដ៏កាចសាហាវ ដោយកម្ពុជាមិនត្រឹមតែបានប្រយុទ្ធឈ្នះលើសមរភូមិសុខភាពសាធារណៈប៉ុណ្ណោះទេ; ប៉ុន្តែក៏មានជ័យជម្នះក្នុងសមរភូមិអប់រំ, គាំពារសង្គម, ហិរញ្ញវត្ថុ ក៏ដូចជាសេដ្ឋកិច្ច និងឈានទៅបើកប្រទេសឡើងវិញទាំងស្រុងនៅចុងឆ្នាំ ២០២១ និងបានអនុញ្ញាតឱ្យសកម្មភាពសង្គម-សេដ្ឋកិច្ច វិលទៅរកប្រក្រតីភាពឡើងវិញបន្តិចម្តងៗ រហូតដល់រាជរដ្ឋាភិបាលអាណត្តិទី ៧ បានចាប់ផ្តើមក្នុងខែ សីហា ឆ្នាំ ២០២៣ ។

រយៈពេលជិត ២ ឆ្នាំ, រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា, ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយថាមពលរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា,** បានបន្តបំពេញបេសកកម្មជាតិដ៏ថ្លៃថ្លាប្រកបដោយឧត្តមគតិ និងការប្តេជ្ញាចិត្តដ៏មោះមុត ដើម្បីបន្តពុះពារបម្រើ និងការពារឧត្តមប្រយោជន៍ជាតិ និងប្រជាជនកម្ពុជាគ្រប់កាលៈទេសៈ ស្របតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាជន ក៏ដូចជាលើកស្ទួយកិត្យានុភាពជាតិទាំងនៅក្នុងតំបន់ និងលើឆាកអន្តរជាតិ ។ ក្រោយពីបានដាក់ចេញ និងអនុវត្តជាបណ្តើរៗនូវ **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** និងការពង្រឹងការដ្ឋានកែទម្រង់សំខាន់ៗ, រាជរដ្ឋាភិបាល បានបន្តខិតខំដោះស្រាយបញ្ហាប្រឈមនានា និងជំរុញកែទម្រង់កាន់តែមុតស្រួច ក្នុងការសម្របខ្លួនឱ្យទាន់ការវិវត្តនៃសភាពការណ៍សកល និងតំបន់ ប្រកបដោយស្មារតីបុរេសកម្ម, ជាពិសេសគឺការចាប់យកនូវកាលានុវត្តភាព ដែលលេចចេញក្នុងបរិការណ៍នៃការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃនិម្មាបនកម្មសង្គម-សេដ្ឋកិច្ចសកល ។ ក្នុងសភាពការណ៍នេះ រាជរដ្ឋាភិបាលបានបន្តរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាខិតខំស្តារ និងជំរុញកំណើនជាបណ្តើរៗឡើងវិញបន្ទាប់ពីវិបត្តិកូវីដ-១៩ ដោយសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រា ៥% ក្នុងឆ្នាំ ២០២៣ និងប្រមាណ ៦% ក្នុងឆ្នាំ ២០២៤ ។

ទោះជាយ៉ាងនេះក្តី, ស្លាកស្នាមនៃវិបត្តិជំងឺកូវីដ-១៩ នៅកំពុងបន្តបន្ទចបង្អាក់ដល់ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ច ខណៈវិបត្តិនានាកំពុងកើតឡើងជាបន្តបន្ទាប់ ។ ការវិវត្តថ្មីនៃការរងនូវការដាក់ពន្ធគយបដិការ (Reciprocal Tariff) របស់សហរដ្ឋអាម៉េរិក និងភាពមិនច្បាស់លាស់នៃគោលនយោបាយពាណិជ្ជកម្មរបស់ដៃគូ

ពាណិជ្ជកម្មសំខាន់ៗ ធ្វើឱ្យកម្ពុជាប្រឈមនឹងការលំបាកទ្វេដង ក្នុងការបត់បែនគោលនយោបាយរបស់ខ្លួនទាំងផ្នែកសេដ្ឋកិច្ច និងផ្នែកការទូត ដើម្បីបញ្ចៀសនូវកម្មវិបាកនានា, ទាំងផ្ទាល់ និងប្រយោល, មកលើសេដ្ឋកិច្ច និងសង្គម ។ ក្នុងន័យនេះ, កំណើនសេដ្ឋកិច្ចកម្ពុជាដែលគ្រោងថាអាចសម្រេចបាន ៦,៣% សម្រាប់ឆ្នាំ ២០២៥ ត្រូវបានប៉ាន់ស្មានបឋមថានឹងថមថយមកត្រឹម ៥,២% ក្រោមឥទ្ធិពលហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់នៃគោលនយោបាយពាណិជ្ជកម្មរបស់ប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជា ស្របនឹងការថមថយនៃទស្សនវិស័យសេដ្ឋកិច្ចសកល ព្រមទាំងហានិភ័យផ្សេងៗទៀត ដែលលេចរូបរាងកាន់តែច្បាស់ឡើង ។

សម្រាប់ឆ្នាំ ២០២៦ សេដ្ឋកិច្ចសកល, តំបន់ និងកម្ពុជា នឹងត្រូវប្រឈមនឹងហានិភ័យ និងភាពមិនប្រាកដប្រជាកាន់តែខ្លាំងឡើង ត្បិតទស្សនវិស័យសេដ្ឋកិច្ចសកល, តំបន់ និងកម្ពុជាបន្តស្ថិតក្នុងអន្តរកាលនៃពហុវិបត្តិ ដែលរួមមាន បញ្ហាភូមិសាស្ត្រនយោបាយដែលកាន់តែឡើងកំដៅ, ការកើនឡើងនូវគោលនយោបាយគាំពារនិយម (Protectionism) របស់ប្រទេសមហាអំណាច, ជាពិសេសសង្គ្រាមពាណិជ្ជកម្ម ពាក់ព័ន្ធនឹងការដំឡើងពន្ធគយ (Tariff) និងការកាត់បន្ថយជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ព្រមទាំងការប្រកួតប្រជែងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងបញ្ញាសិប្បនិម្មិតកាន់តែខ្លាំងក្លា ដែលទាំងអស់នេះបានរុញសភាពការណ៍ឱ្យកាន់តែស្មុគស្មាញថែមទៀត ។ ជាមួយគ្នានេះ, នៅក្នុងបរិបទនៃភាពមិនប្រាកដប្រជាកាន់តែស្រួចស្រាល់ កម្ពុជាក៏អាចទទួលនូវកាលានុវត្តភាពមួយចំនួនផងដែរ ប្រសិនបើយើងប្រកាន់ភាពបត់បែន និងអាចសម្របខ្លួនទាន់សភាពការណ៍តំបន់ និងពិភពលោក ហើយអាចត្រៀមខ្លួនរួចរាល់ក្នុងការប្រែក្លាយបញ្ហាប្រឈមនានាឱ្យទៅជាកាលានុវត្តភាព និងប្រើប្រាស់លក្ខខណ្ឌអំណោយផលទាំងឡាយដែលអាចកើតចេញពីការវិវត្តសភាពការណ៍នេះ សម្រាប់លើកកម្ពស់ភាពប្រកួតប្រជែង, បង្កើនពិពិធកម្ម និងពង្រឹងភាពធន់នៃសង្គម-សេដ្ឋកិច្ចជាតិ ។ ក្នុងរយៈពេលមធ្យមទៅមុខ (២០២៧-២០២៨) ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា ត្រូវបានសន្មតថា នឹងមាននិន្នាការល្អឡើងវិញដោយសន្សឹមៗ ។ សកម្មភាពសង្គម-សេដ្ឋកិច្ច នឹងរំពឹងថាងើបវិញជាបណ្ដើរៗ ចំណែកអត្រាអតិផរណាក៏នឹងត្រលប់ទៅរកប្រក្រតីភាពវិញ ស្របពេលដែលស្ថានភាពហិរញ្ញវត្ថុសកលមានភាពប្រសើរ គួបផ្សំជាមួយនឹងការរក្សាបានស្ថិរភាពសង្គម-សេដ្ឋកិច្ចកម្ពុជា, ការបន្តស្ដារវិស័យចន្លល់កំណើនដែលមានស្រាប់, ការលើកកម្ពស់វិស័យសក្ដានុពលថ្មីមួយចំនួនទៀត ក៏ដូចជាការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអាជីវកម្ម និងកិច្ចសម្រួលពាណិជ្ជកម្ម ដើម្បីជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា ។ ក្រោមសម្មតិកម្មនេះ, កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករបន្តថមថយបន្តិចក្នុងរង្វង់ **៥,០% សម្រាប់ឆ្នាំ ២០២៦ និងងើបវិញក្នុងអត្រាមធ្យម ៥,៦% សម្រាប់ឆ្នាំ ២០២៧-២០២៨** ។ គួរគូសបញ្ជាក់ថា, ផ្អែកលើការវាយតម្លៃស្ថានភាពសេដ្ឋកិច្ចមុនពេលព្រឹត្តិការណ៍ពន្ធគយបដិការ, កំណើនសេដ្ឋកិច្ចកម្ពុជាអាចសម្រេចបាន ៦,៣% នៅឆ្នាំ ២០២៦ និង ៦,៥% ក្នុងរយៈពេលមធ្យម ។ គួរកត់សម្គាល់ផងដែរថា, ការវាយតម្លៃឡើងវិញលើកំណើននេះ ក៏មាននិន្នាការស្រដៀងគ្នាទៅនឹងស្ថាប័នអន្តរជាតិធំៗ ដែលបានកែតម្រូវកំណើនសេដ្ឋកិច្ចកម្ពុជាពីការព្យាករគោល ដោយនៅរក្សាបានកំណើនក្នុងកម្រិតសមរម្យ គួរយ៉ាងដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានកែតម្រូវកំណើនសេដ្ឋកិច្ចកម្ពុជាពីអត្រា ៥,៨% និង ៦,២% មកក្នុងអត្រា ៤% និង ៣,៤%, ធនាគារពិភពលោក ពី ៥,៤% និង ៥,៤% មក ៤% និង ៤,៥%, និងការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូកបី (AMRO) ពី ៥,៨% និង ៦,០% មក ៤,៩% និង ៤,៧%, សម្រាប់ឆ្នាំ ២០២៥ និង ២០២៦ រៀងគ្នា ។ យ៉ាងណាមិញ, រាជរដ្ឋាភិបាលក៏ទទួលស្គាល់ថា កម្ពុជានៅបន្តប្រឈមនឹងហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់, ទាំងក្នុងក្របខ័ណ្ឌសកល តំបន់ និងក្នុងស្រុក, និងកាន់តែ

ស្រួចស្រាល់ជាងមុន ដែលនឹងធ្វើឱ្យសម្មតិកម្មខាងលើមិនឆ្លើយតបនឹងតថភាពជាក់ស្តែង និងអាចនឹងតម្រូវឱ្យមានការកែសម្រួលទៅលើក្របខ័ណ្ឌកំណើនខាងលើ បន្ថែមទៀតផងដែរ ។

ឈរលើទស្សនវិស័យកំណើនខាងលើនេះ, គោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ត្រូវរៀបចំឡើងដោយបន្តប្រកាន់យក **«ជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន** (Gradual Fiscal Consolidation Stance)» ដើម្បី, **ម្ខាង,** ឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់ចំពោះមុខក្នុងការគ្រប់គ្រង និងឆ្លើយតបទៅនឹងឥទ្ធិពលនៃកម្មវិបាកដែលកើតមានដោយសារបញ្ហាកត្តាខាងក្រៅ ដោយខិតខំរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជនដែលអាចរងការប៉ះទង្គិច និងរក្សាលំនឹងម៉ាក្រូសេដ្ឋកិច្ចជារួម ក៏ដូចជារក្សានិរន្តរភាពប្រតិបត្តិការការងារ និងការអនុវត្តកម្មវិធីគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និង **ម្ខាងទៀត,** កសាងនូវទ្រនាប់ថវិកាជាតិឡើងវិញ នៅពេលកាលៈទេសៈអនុញ្ញាត ដើម្បីជានាពូនគរធនធានត្រៀមបម្រុងថវិកាសម្រាប់ឆ្លើយតបនឹងការវិវត្តមិនអំណោយផលនៃសភាពការណ៍ និងវិបត្តិនានាជាយថាហេតុ នាអនាគត ។

ជាការពិត, សភាពការណ៍សកល និងតំបន់ មានការវិវត្តយ៉ាងរហ័ស ពោរពេញទៅដោយភាពមិនប្រាកដប្រជាខ្ពស់នៅឡើយ ហើយភាគច្រើនមិនចំណុះក្រោមការគ្រប់គ្រងរបស់កម្ពុជាទាំងស្រុងនោះទេ ។ កម្ពុជា, ក្នុងនាមជាប្រទេសតូច បើកចំហ និងផ្អែកខ្លាំងលើពាណិជ្ជកម្មអន្តរជាតិ, ពិតជាមិនអាចត្រៀមវិធានការគោលនយោបាយ សម្រាប់គ្រប់សេណារីយ៉ូដែលអាចកើតឡើងបានឡើយ ។ ក្នុងន័យនេះ, អ្វីដែលកម្ពុជាអាចធ្វើបាន គឺបន្តគ្រប់គ្រងស្ថានការណ៍ជាប្រចាំដោយប្រុងប្រយ័ត្ន តាមរយៈការក្តាប់ឱ្យបាននូវជីពចរនៃសេដ្ឋកិច្ច និងសង្គមជាមួយនឹងការដាក់ចេញវិធានការអន្តរាគមន៍ចាំបាច់ បុរេសកម្ម និងទាន់ពេល ឆ្លើយតបទៅនឹងភាពចល័តនៃសភាពការណ៍ តាមរយៈការបន្តពង្រឹងការដ្ឋានកែទម្រង់ ដោយហ៊ានវះកាត់ និងដាក់ចេញនូវវិធានការដាក់លាក់មុតស្រួច និង ចំគោលដៅ ដើម្បីដោះស្រាយបញ្ហាជាឧបសគ្គរាំងស្ទះទាំងឡាយ និងសំដៅបញ្ចៀសនូវហានិភ័យទាំងឡាយឱ្យបានជាអតិបរមាតាមដែលអាចធ្វើទៅបាន ។ ក្នុងស្ថានភាពនេះ, គោលនយោបាយហិរញ្ញវត្ថុសាធារណៈ (Fiscal Policy) ស្ថិតក្នុងភាពប្រុងប្រយ័ត្នជាប្រចាំ រក្សាភាពបត់បែនខ្ពស់ និងខិតខំឆ្លើយតបឱ្យចំគោលដៅ ដើម្បីការធានាឱ្យបាននូវចីរភាពផ្នែកហិរញ្ញវត្ថុសាធារណៈ គឺជាកត្តាមិនអាចខ្វះបាន ។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងដាក់ចេញនូវ **«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៦-២០២៨»** ឬ ហៅខ្លីថា **«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨»** ដែលបង្ហាញពីការព្យាករទស្សនវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម, កំណត់យុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈ (Fiscal Strategy) និងកំណត់នូវ **ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ (Fiscal Policy Stance)** ដោយប្រកាន់ខ្ជាប់នូវ **វិធានហិរញ្ញវត្ថុសាធារណៈមួយចំនួន (Fiscal Rules)** ព្រមទាំងធ្វើការវិភាគនូវ**ហានិភ័យហិរញ្ញវត្ថុសាធារណៈ (Fiscal Risks)** ផងដែរ ។

ជារួម, ការដាក់ចេញឱ្យអនុវត្តជាផ្លូវការនូវ **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨** គឺអនុលោមតាម **ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ** និងជាផ្នែកមួយនៃការអនុវត្ត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការគាំទ្រដល់៖ **(១)**-ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល, **(២)**-ការពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល និងការវិភាជថវិកា, និង **(៣)**-ការធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ ។ ម៉្យាងវិញទៀត, ការដាក់ចេញនូវក្របខ័ណ្ឌខាងលើក៏ស្របតាម **«យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ និងបច្ចុប្បន្នកម្ម ២០២៥-២០២៨»** ដោយមានគោលបំណងពង្រឹងវិន័យថវិកា ចាប់តាំងពីការរៀបចំផែនការ រហូតដល់ការវិភាជ និងការអនុវត្តថវិកា តាមរយៈ

ការផ្សារភ្ជាប់ថវិកាទៅគោលនយោបាយអាទិភាព និងការវិភាជថវិកាដោយផ្អែកលើព័ត៌មានសមិទ្ធកម្ម ។ **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨** នេះត្រូវបានរៀបចំឡើងក្រោមទម្រង់ ៣ ឆ្នាំរំកិល (Three Years Rolling) ដែលក្នុងនោះ ពិតានថវិកាជាក់លាក់សម្រាប់ឆ្នាំ ២០២៦ (ដែលជាឆ្នាំទី ១) នឹងជាផ្នែកមួយនៃការ-រៀបចំច្បាប់ថវិកាឆ្នាំ ២០២៦ ខណៈដែលចំណោលសម្រាប់ឆ្នាំ២០២៧ (ឆ្នាំទី ២) និង ឆ្នាំ២០២៨ (ឆ្នាំទី ៣) នឹងអាចត្រូវបានកែតម្រូវនៅឆ្នាំបន្តបន្ទាប់ ដើម្បីឱ្យស្របទៅតាមការប្រែប្រួលនៃស្ថានភាពសង្គម-សេដ្ឋកិច្ចក្នុងស្រុក និងបរិយាកាសខាងក្រៅ ។ ក្របខ័ណ្ឌនេះនឹងក្លាយជាមូលដ្ឋានសម្រាប់ការរៀបចំនូវ «**ក្របខ័ណ្ឌថវិការយៈ-ពេលមធ្យម ឆ្នាំ ២០២៦-២០២៨**» និង «**សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦**» ។ ក្របខ័ណ្ឌនេះ នឹងចែកចេញជា ៦ ផ្នែកសំខាន់ៗ រួមមាន ៖ (១). បរិការណ៍រួម (ផ្នែកនេះ); (២). ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច; (៣). យុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈ; (៤). ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ; (៥). ហានិភ័យហិរញ្ញវត្ថុសាធារណៈ; និង (៦). សេចក្តីសន្និដ្ឋាន ។

# ២. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

## ២.១. បរិការណ៍សេដ្ឋកិច្ចសកល

មុនការដាក់ចេញពន្ធគយបដិការ បើផ្អែកតាមការវាយតម្លៃរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ចេញផ្សាយក្នុងខែ មករា ឆ្នាំ ២០២៥, សេដ្ឋកិច្ចសកលត្រូវបានព្យាករណ៍ថានឹងមានកំណើន ក្នុងអត្រា ៣,៣% ដូចគ្នា ក្នុងឆ្នាំ ២០២៥ និង ២០២៦ ជាមួយនឹងនិន្នាការបោះឆ្ពោះទៅរកវិថីនៃកំណើនសក្តានុពល ។ ចលនការនៃកំណើននេះ គឺត្រូវបានរំពឹងថានឹងគាំទ្រដោយនិន្នាការល្អប្រសើរនៃសេដ្ឋកិច្ចរបស់បណ្តាប្រទេសអភិវឌ្ឍន៍ និងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ រួមទាំង ចិន ស្របពេលដែលគោលនយោបាយរឹតបន្តឹងរូបិយវត្ថុ ត្រូវបានបន្ធូរបន្ថយជាសន្សឹមៗ ដោយសារអត្រាអតិផរណាបានខិតទៅរកអត្រាគោលដៅបន្តិចម្តងៗ ។ ត្បិតការព្យាករ និងទស្សនវិស័យសេដ្ឋកិច្ចសកលនាពេលនោះ បានហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់, ក៏ប៉ុន្តែស្ថានភាពជារួម មិនរំពឹងថានឹងវិវត្តទៅក្នុងទិសដៅអវិជ្ជមាន ដែលអាចនាំឱ្យមានផលជះដល់ទស្សនវិស័យនៃកំណើនសេដ្ឋកិច្ចខ្លាំងក្លាគួរឱ្យកត់សម្គាល់ឡើយ ។

យ៉ាងណាមិញ, ការកើនឡើងយ៉ាងឆាប់រហ័សជាងការរំពឹងទុកនៃចរន្តគាំពារនិយម (Protectionist policies) ដែលស្តែងចេញ ជាពិសេសតាមរយៈការដំឡើងពន្ធគយ (Broad-based tariff hike) និងពន្ធគយបដិការ (Reciprocal tariff) បានធ្វើឱ្យការគិតគូរ និងមូលដ្ឋានសម្មតិកម្មទាំងឡាយនៃការព្យាករសេដ្ឋកិច្ចសកល នាកាលនោះ មិនឆ្លុះបញ្ចាំងពីតថភាពជាក់ស្តែងដែលបាននិងកំពុងកើតឡើង ។ ក្នុងន័យនេះ, បើផ្អែកតាមការវាយតម្លៃរបស់ IMF ចេញផ្សាយក្នុង ខែ មេសា ឆ្នាំ ២០២៥ នាពេលថ្មីៗនេះ, សេដ្ឋកិច្ចសកលត្រូវបានទាញទម្លាក់មកត្រឹមអត្រាកំណើនប្រមាណ ២,៨% និង ៣,០% ក្នុងឆ្នាំ ២០២៥ និង ២០២៦ ពោលគឺធ្លាក់ក្នុងកម្រិតប្រមាណ ០,៥ និង ០,៣ ពិន្ទុភាគរយរៀងគ្នា ពីការព្យាករ ក្នុងខែ មករា ឆ្នាំ ២០២៥ ដោយសារផលប៉ះពាល់ និងកម្មវិបាកនៃគោលនយោបាយគាំពារនិយម ដែលស្តែងឡើងតាមរយៈការដំឡើងពន្ធគយ និងនាពេលថ្មីៗនេះ គឺការដាក់ឱ្យអនុវត្តនូវពន្ធគយបដិការ ។ សម្រាប់សេដ្ឋកិច្ចសហរដ្ឋអាម៉េរិក, បើទោះបីការប្រើប្រាស់ក្នុងស្រុកកាលពីឆ្នាំទៅមានចលនការល្អ, និន្នាការនេះបានចាប់ផ្តើមមានការថមថយ ពោលគឺចាប់តាំងពីមុនការប្រកាសនូវពន្ធគយបដិការ ស្របពេលដែលពន្ធនេះ ក៏អាចនឹងជំរុញការហក់ឡើងវិញនៃសម្ពាធអតិផរណាក្នុងប្រទេសផងដែរ ។ ក្នុងន័យនេះ, ផលជះនៃការអនុវត្តពន្ធគយបដិការ នឹងកាន់តែផ្តល់កម្មវិបាកជាអវិជ្ជមានមួយកម្រិតថែមទៀតដល់ការប្រើប្រាស់ និងសកម្មភាពវិនិយោគក្នុងស្រុក ។ សេដ្ឋកិច្ចតំបន់ចាយប្រាក់អឺរ៉ូ ក៏នៅបន្តមាន

កំណើនយឺត ដោយសារការថមថយនៃសកម្មភាពផលិតកម្ម ជាពិសេស ក្នុងប្រទេសអាល្លឺម៉ង់ និងអ៊ីតាលី ស្របពេលដែលសម្ទុះនៃការប្រើប្រាស់ក៏នៅមានភាពទ្រើង ។ ចលនការកំណើននៃសេដ្ឋកិច្ចចិន ក៏រំពឹងថាមានសម្ទុះថមថយជាងការរំពឹងទុក ដោយសារកំណើនយឺតនៃការនាំចេញ និងការប្រើប្រាស់ក្នុងស្រុក ស្របពេលដែលស្ថានភាពវិនិយោគ ជាពិសេស ក្នុងវិស័យអចលនទ្រព្យ នៅបន្តមានភាពទ្រើង, ខណៈដែលសេដ្ឋកិច្ចជារួម ក៏នឹងទទួលរងផលជះជាអវិជ្ជមានពីគោលនយោបាយគាំពារនិយម ពោលគឺការដំឡើងពន្ធគយ ។

ជាការពិត, ការកើនឡើងហួសជាងការរំពឹងទុកនៃគោលនយោបាយគាំពារនិយម បាននិងកំពុងទាញគម្លាតនៃកំណើនសេដ្ឋកិច្ចសកល ឱ្យកាន់តែឃ្លាតឆ្ងាយពីគន្លងសក្តានុពល ក៏ដូចជាជំរុញឱ្យមានអតុល្យភាពនៃកំណើនសេដ្ឋកិច្ច (Growth divergence) កាន់តែខ្លាំង ។ មកទល់បច្ចុប្បន្ន, ទស្សនវិស័យសេដ្ឋកិច្ចសកលនៅតែបន្តហ៊ុមព័ទ្ធដោយភាពមិនប្រាកដប្រជាខ្ពស់ ហើយមានទំនោរទៅរកហានិភ័យច្រើនជាងកាលានុវត្តភាព ក្នុងន័យថា គោលនយោបាយគាំពារនិយម ជាពិសេសការដំឡើងពន្ធគយ បានបង្កើតនូវចំណុចប្រែប្រួលមួយថ្មីគួរឱ្យកត់សម្គាល់ (Critical juncture) ដែលបាននិងកំពុងបង្កើនកំដៅបន្ថែមទៀតដល់កិច្ចសហប្រតិបត្តិការសកល ។ ជារួម, គោលនយោបាយគាំពារនិយម ត្រូវបានមើលឃើញថានឹងផ្តល់បច្ច័យអវិជ្ជមានច្រើនជាងវិជ្ជមានដូចជា ការកើនឡើងថ្លៃដើមទំនិញស្តែងចេញពីកត្តាផ្គត់ផ្គង់ (Supply-side inflationary pressure) និងបន្ទប់បង្អាក់ដល់ខ្សែប្រវាក់ផលិតកម្ម និងដឹកជញ្ជូន និងប៉ះពាល់ដល់រំហូរពាណិជ្ជកម្ម ជារួម ហើយអាចនឹងឈានដល់សង្គ្រាមពាណិជ្ជកម្ម (Trade war) ពេញទំហឹង និងសង្គ្រាមបច្ចេកវិទ្យា (Tech war) និងការបែកខ្ញែកកិច្ច-សហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម ។

ការរំពឹងទុកនៃកម្មវិបាកជាអវិជ្ជមាន ដែលស្តែងចេញពីហានិភ័យទាំងឡាយ និងជាពិសេសគោល-នយោបាយដំឡើងពន្ធគយនេះ ក៏បានធ្វើឱ្យមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ផងដែរ លើការគិតគូរឡើងវិញនូវទិសដៅ និងវិធានការគោលនយោបាយ ។ ជាក់ស្តែង, ការបន្ធូរបន្ថយគោលនយោបាយរឹតបន្តឹងរូបិយវត្ថុ ត្រូវបានមើលឃើញថាជាសញ្ញាវិជ្ជមានសម្រាប់ទស្សនវិស័យសេដ្ឋកិច្ចសកល, ប៉ុន្តែល្បឿននៃការបន្ធូរបន្ថយ និងព្យាសកម្ម (Calibration) វិធានការគោលនយោបាយ នាពេលបច្ចុប្បន្ន ត្រូវបានធ្វើឡើងក្នុងល្បឿនទាបជាងការរំពឹងទុក និងក្នុងស្មារតីប្រុងប្រយ័ត្នខ្ពស់ ត្បិតត្រូវថ្លឹងថ្លែងឱ្យបានល្អិតល្អន់ ជាពិសេសចំពោះហានិភ័យនៃការហក់ឡើងវិញនៃសម្ពាធអតិផរណា ។ ម្យ៉ាងទៀត, បើទោះបីប្រទេសចិនបានប្រកាសដាក់ចេញនូវកញ្ចប់អន្តរាគមន៍ ដើម្បីគាំពារកំណើនសេដ្ឋកិច្ច, ក៏មកទល់បច្ចុប្បន្នកញ្ចប់អន្តរាគមន៍ទាំងនេះ នៅមិនទាន់លេចចេញជាវិធានការជាក់លាក់ណាមួយនោះឡើយ ត្បិតរដ្ឋាភិបាលចិនក៏ត្រូវថ្លឹងថ្លែងប្រកបដោយស្មារតីប្រុងប្រយ័ត្នខ្ពស់ ព្រោះថាការអនុវត្តវិធានការពាក់ព័ន្ធនឹងគោលនយោបាយសារពើពន្ធ អាចលេចចេញនូវហានិភ័យទ្វេទិស និងប៉ះពាល់ដល់ចីរភាពហិរញ្ញវត្ថុសាធារណៈ ស្របពេលដែលលម្ហូថវិកាមានកំណត់ ។

## តារាងទី ១៖ កំណើនសេដ្ឋកិច្ចសកល និងតំបន់

| | សេដ្ឋកិច្ចសកល | ប្រទេសអភិវឌ្ឍន៍ | សេដ្ឋកិច្ចកំពុងរីកលូតលាស់ និងប្រទេសកំពុងអភិវឌ្ឍ | សហរដ្ឋអាម៉េរិក | តំបន់ចាយប្រាក់អឺរ៉ូ | ចក្រភពអង់គ្លេស | ជប៉ុន | ចិន | អាស៊ាន-៥ |
|---|---|---|---|---|---|---|---|---|---|
| 2023 | 3.3 | 1.7 | 4.4 | 2.9 | 0.4 | 0.3 | 1.5 | 5.2 | 4.0 |
| 2024 | 3.3 | 1.8 | 4.3 | 2.8 | 0.9 | 1.1 | 0.1 | 5.0 | 4.6 |
| 2025 | 2.8 | 1.4 | 3.7 | 1.8 | 0.8 | 1.1 | 0.6 | 4.0 | 4.0 |
| 2026 | 3.0 | 1.5 | 3.9 | 1.7 | 1.2 | 1.4 | 0.6 | 4.0 | 3.9 |
| 2027 | 3.2 | 1.7 | 4.2 | 2.0 | 1.3 | 1.5 | 0.6 | 4.2 | 4.2 |
| 2028 | 3.2 | 1.7 | 4.1 | 2.1 | 1.3 | 1.5 | 0.6 | 4.1 | 4.3 |

*ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ, ទស្សនវិស័យសេដ្ឋកិច្ចសកល ខែ មេសា ឆ្នាំ ២០២៥*

ក្នុងន័យនេះ, ក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ, ទស្សនវិស័យសេដ្ឋកិច្ចសកលមានទំនោរទៅរកហានិភ័យ ច្រើនជាងកាលានុវត្តភាព តួយ៉ាងដូចជា ៖ **(១).** កម្មវិបាកនៃការបន្តកើនឡើងនៃចរន្តគាំពារនិយមរបស់សហរដ្ឋអាមេរិក ដែលអាចលេចចេញនូវសង្គ្រាមពាណិជ្ជកម្ម, សង្គ្រាមបច្ចេកវិទ្យា និងការហក់ឡើងវិញនៃថ្លៃទំនិញសកល; **(២).** ភាពតានតឹងនៃកត្តាភូមិសាស្ត្រនយោបាយ ជាក់ស្តែងដូចជានៅតំបន់មជ្ឈិមបូព៌ា; **(៣).** ការបន្តកើនឡើងសម្ពាធបំណុលសាធារណៈ; **(៤).** ការបន្តធ្លាក់ចុះនៃវិស័យអចលនទ្រព្យនៅចិន; និង **(៥).** ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ។ យ៉ាងណាមិញ, ការបន្តបន្ធូរបន្ថយគោលនយោបាយរឹតបន្តឹងរូបិយវត្ថុ, ការដាក់ចេញនូវកញ្ចប់អន្តរាគមន៍របស់ប្រទេសចិន និង លទ្ធភាពក្នុងការធ្វើសមាហរណកម្មស៊ីជម្រៅនៃពាណិជ្ជកម្មប្រទេសដទៃផ្សេងពីសហរដ្ឋអាមេរិក ក៏នៅតែអាចជាកាលានុវត្តភាព សម្រាប់ទស្សនវិស័យសេដ្ឋកិច្ចសកល និងតំបន់ ផងដែរ ។

## ២.២. ទិដ្ឋភាពសេដ្ឋកិច្ចកម្ពុជា

បើទោះបីសេដ្ឋកិច្ចសកលហ៊ុមព័ទ្ធទៅនឹងភាពមិនប្រាកដប្រជាខ្ពស់ ក៏សេដ្ឋកិច្ចកម្ពុជាត្រូវបានវាយតម្លៃថានៅបន្តរក្សាបាននូវចលនការរឹងមាំ ជាមួយអត្រាកំណើន ៦,០% ក្នុងឆ្នាំ ២០២៤ បើធៀបនឹងប្រមាណ ៥,០% ក្នុងឆ្នាំ ២០២៣ ។ មុននឹងគោលនយោបាយពន្ធគយបដិការរបស់សហរដ្ឋអាមេរិកចូលជាធរមាន, កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានវាយតម្លៃថា នឹងបន្តចលនការប្រសើរ ពោលគឺក្នុងរង្វង់ ៦,៣% សម្រាប់ឆ្នាំ ២០២៥ ដោយសារការបន្តនិន្នាការប្រសើរនៃតម្រូវការសកល ដែលនឹងបន្តគាំទ្រដល់វិស័យបម្រើការនាំចេញកម្ពុជា ពោលគឺវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ។ ជាមួយគ្នានេះ, សកម្មភាពសេដ្ឋកិច្ចក្នុងស្រុកក៏នៅបន្តរក្សាបានតុល្យភាព ដែលបន្តគាំទ្រដោយការបន្តនិន្នាការល្អនៃវិស័យគាំទ្រចំណូលប្រជាជន, តួយ៉ាងដូចជា វិស័យឧស្សាហកម្ម និងទេសចរណ៍ ជាដើម, និងវិស័យសំណង់-អចលនទ្រព្យ ក៏រំពឹងថានឹងបន្តងើបមកវិញសន្សឹមៗ ស្របគ្នាទៅនឹងការបន្តកើនឡើងវិញនៃប្រាក់ចំណូលរបស់ប្រជាជន និងសកម្មភាពសេដ្ឋកិច្ច ជារួម ។ កំណើននេះ នឹងបន្តនិន្នាការល្អក្នុងឆ្នាំ ២០២៦ ក្នុងអត្រា ៦,៣% ផងដែរ ។

យ៉ាងណាមិញ, ដូចគ្នាទៅនឹងការធ្វើបច្ចុប្បន្នភាពនៃកំណើនសេដ្ឋកិច្ចសកលដែរ, កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានវាយតម្លៃជាថ្មីថានឹងថមថយបន្តិចវិញ ក្រោយគោលនយោបាយពន្ធគយបដិការរបស់សហរដ្ឋអាមេរិកមកត្រឹម ៥,២% សម្រាប់ឆ្នាំ ២០២៥ និង ៥% សម្រាប់ឆ្នាំ ២០២៦ ស្របពេលកម្ពុជាកំពុងស្ថិតក្នុងអន្តរកាលនៃស្ថានភាពមិនប្រាកដប្រជាខ្ពស់ ។ ប្រសិនបើស្ថានភាពកត្តាខាងក្រៅវិវត្តទៅកាន់តែអាក្រក់ជាងបច្ចុប្បន្ន ហើយការចរចារវាងកម្ពុជា និងសហរដ្ឋអាមេរិក មិនទទួលបានលទ្ធផលល្អដូចការរំពឹងទុក, នោះកំណើននេះនឹងកាន់តែថមថយបន្ថែមទៀត **(សេណារីយ៉ូទាប មានលម្អិតក្នុងផ្នែកហានិភ័យ)** ។

### ក. សមិទ្ធផលសេដ្ឋកិច្ចឆ្នាំ ២០២៤ និងទស្សនវិស័យ ឆ្នាំ ២០២៥

សេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ ២០២៤ អាចសម្រេចបានកំណើនក្នុងអត្រា ៦,០% ដែលត្រូវបានទ្រទ្រង់យ៉ាងសំខាន់ដោយការងើបវិញលឿនជាងការរំពឹងទុកនៃវិស័យកាត់ដេរ និងការបន្តរក្សាបាននូវនិន្នាការល្អនៃវិស័យកសិកម្ម និងបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ (ទេសចរណ៍) ដែលបន្តគាំពារដល់វិស័យគាំទ្រ ពោលគឺវិស័យដឹកជញ្ជូន និងស្តុក ។ បើទោះបីវិស័យកម្មន្តសាលមិនមែនកាត់ដេរ មានសន្ទុះថមថយបន្តិច, ក៏វិស័យនេះជារួម បន្តទ្រទ្រង់យ៉ាងសំខាន់ដោយឧស្សាហកម្មយុទ្ធសាស្ត្របម្រើការនាំចេញចម្បងៗ (គ្រឿងបង្គុំអេឡិចត្រូនិក, សំបកកង់រថយន្ត និងគ្រឿងសង្ហារិម) និងឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុក តួយ៉ាងដូចជាឧស្សាហកម្មដំឡើងរថយន្ត ជាដើម ។ ជាមួយគ្នានេះ, ការបន្តអនុវត្តវិធានការអន្តរាគមន៍សង្គម-សេដ្ឋកិច្ច

ទាំងទៅលើការរក្សាលំនឹងជីវភាពប្រជាជន និងស្ថិរភាពអាជីវកម្ម (ឧទាហរណ៍ ក្នុងវិស័យសំណង់-អចលនទ្រព្យ និងវិស័យទេសចរណ៍) ក៏បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការគាំពារកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ ២០២៤ ។

ទោះជាយ៉ាងនេះក្តី, ការដាក់ចេញនូវគោលនយោបាយពន្ធគយបដិការ អាចនឹងបង្កឱ្យមានផលប៉ះពាល់ដោយផ្ទាល់លើការនាំចេញរបស់កម្ពុជា, ជាពិសេសវិស័យកាត់ដេរ និងវិស័យមិនមែនកាត់ដេរ, ជាមួយនឹងផលប៉ះ-ពាល់ដោយប្រយោល លើវិស័យសំខាន់ៗមួយចំនួន ត្បយ៉ាងដូចជា វិស័យដឹកជញ្ជូន និងស្តុក, វិស័យលក់ដុំ-រាយ (សកម្មភាពចាយវាយក្នុងស្រុក) និងសេវាកម្មរួមផ្សំផ្សេងទៀត, ព្រមទាំងបង្កជាផលជះជាអវិជ្ជមានដល់លំហូរវិនិយោគ ដែលក៏នឹងមានផលប៉ះពាល់ដល់វិស័យសំណង់-អចលនទ្រព្យផងដែរ ។ វិស័យផ្សេងៗទៀត ក៏មាននិន្នាការថមថយបន្តិចបន្តួចផងដែរ ដោយសារជវភាពនៃផលប៉ះពាល់ (Shock Dynamics) នៃការនាំចេញមកលើវិស័យផ្សេងៗនៃចន្លេសេដ្ឋកិច្ច ។ ប៉ុន្តែ, ស្ថានភាពនៃគោលនយោបាយពន្ធគយបដិការនៅតែបន្តមានភាព-មិនប្រាកដប្រជាខ្ពស់ ហើយការវាយតម្លៃកម្មវិបាក គឺអាស្រ័យលើកត្តាជាច្រើន ត្បយ៉ាងដូចជា លទ្ធផលនៃការ-ចរចាដាក់ស្តែងរវាងកម្ពុជា និងសហរដ្ឋអាមេរិក និង រយៈពេលនៃការអនុវត្តគោលនយោបាយពន្ធគយបដិការនេះ ។ យ៉ាងណាមិញ, ជាមួយនឹងការពន្យារការអនុវត្តអត្រា ៤៩% ពេលចំនួន ៩០ ថ្ងៃ និងការរំពឹងទុកល្អនៃការចរចា, ទស្សនវិស័យសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០២៥ និងរយៈពេលមធ្យម ត្រូវបានរៀបចំឡើងដោយឈរលើគោលគំនិតនៃការគិតគូរដែលមានសុទិដ្ឋិនិយមប្រយ័ត្នប្រយែង និងមិនទុទ្ទិដ្ឋិនិយមជ្រុល ខណៈដែលស្ថាន-ភាពអាចវិវត្តលឿនរហ័ស និងពិបាកប៉ាន់ស្មានទុកបាន ដែលទាមទារការតាមដានជាប់ជាប្រចាំ ។

ឈរលើមូលដ្ឋាននេះ, សម្រាប់ឆ្នាំ ២០២៥ សេដ្ឋកិច្ចកម្ពុជារំពឹងថានឹងសម្រេចបាននូវអត្រាកំណើន ៥,២% ដែលថមថយពីប្រមាណ ៦,០% ក្នុងឆ្នាំ ២០២៤ កន្លងទៅ ដោយសារការរំពឹងទុកនៃផលប៉ះពាល់នៃគោលនយោបាយពន្ធគយបដិការមកលើវិស័យចន្ទល់កំណើនសំខាន់ៗ ត្បយ៉ាងដូចជា វិស័យបម្រើការនាំចេញរួមមានវិស័យកាត់ដេរ និងវិស័យកម្មន្តសាលមិនមែនកាត់ដេរ និងវិស័យគាំទ្រផ្សេងទៀត ដូចជា វិស័យដឹកជញ្ជូន និងស្តុក និងវិស័យលក់ដុំ-រាយ និងសេវាកម្មគាំទ្រ ។ យ៉ាងណាមិញ, វិស័យដែលរំពឹងថានឹងទទួលរងផលជះ និងកម្មវិបាកទាំងផ្ទាល់ និងប្រយោលទាំងនេះ នៅតែអាចបន្តរក្សាបាននូវនិន្នាការកំណើនវិជ្ជមាន ដែលអាចជួយរក្សាកំណើនជារួម ឱ្យនៅតែមានចលនការ បើទោះបីក្នុងល្បឿនយឺតយ៉ាងណាក្តី ។

## ក្រាហ្វិកទី ១៖ កំណើន ផ.ស.ស. ឆ្នាំ ២០១៨-២០២៨




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (២០១៨-២០២៣) និងការព្យាករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២៤-២០២៨)*

## ■ វិស័យឧស្សាហកម្ម

**វិស័យឧស្សាហកម្ម** ត្រូវបានវាយតម្លៃថាងើបវិញលឿនជាងការរំពឹងទុកពីអត្រា ៥,៤% ក្នុងឆ្នាំ ២០២៣ មកប្រមាណ ៩,២% ក្នុងឆ្នាំ ២០២៤ ដោយសារកំណើនល្អនៃអនុវិស័យកាត់ដេរ ដែលបានប៉ះប៉ូវមួយផ្នែកធំលើកំណើនថមថយនៃអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ, ផលិតកម្មម្ហូបអាហារ និងផលិតកម្មភេសជ្ជៈ, និងថ្នាំជក់ ខណៈដែលអនុវិស័យសំណង់នៅបន្តមានកំណើនទាប ។ សម្រាប់ឆ្នាំ ២០២៥, វិស័យឧស្សាហកម្ម មានកំណើនថមថយ ប៉ុន្តែនៅក្បាបានកំណើនវិជ្ជមាន ក្នុងអត្រា ៧,៨% ដែលបន្តគាំទ្រដោយវិស័យកាត់ដេរ, កម្មន្ត-សាលមិនមែនកាត់ដេរ, បើទោះបីទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីគោលនយោបាយពន្ធគយបដិការយ៉ាង-ណាក្តី, ស្របពេលដែលវិស័យសំណង់បន្តមានកំណើនយឺត ។



**អនុវិស័យកាត់ដេរ** ត្រូវបានវាយតម្លៃថាមានកំណើនល្អ ក្នុងអត្រា ១៦,៩% ក្នុងឆ្នាំ ២០២៤ ដោយសារការងើបឡើងវិញលឿនជាងការរំពឹងទុកនៃតម្រូវការសកល ជាពិសេសប្រទេសដែលជាដៃគូពាណិជ្ជកម្មចម្បងៗរបស់កម្ពុជា ដូចជា៖ សហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប ជាដើម គួបផ្សំនឹងការបង្វែរការបញ្ជាទិញ (shifting of order) ពីប្រទេសដៃគូប្រកួតប្រជែងដែលកំពុងមានវិបត្តិផ្ទៃក្នុង ផងដែរ ។ ជាក់ស្តែង, ក្នុងឆ្នាំ ២០២៤ ការនាំចេញផលិតផលកាត់-ដេរបានកើនឡើងក្នុងអត្រា ២៣,៥% ខណៈការនាំចូលវត្ថុធាតុដើមកាត់ដេរ ក៏មានកំណើនអត្រា ២២,១% ហើយវំហូរវិនិយោគក្នុងវិស័យកាត់ដេរ បានកើនឡើងខ្ពស់ក្នុងអត្រា ៧៦,៦% ឆ្លុះបញ្ចាំងពីភាពរឹងមាំនៃសកម្មភាពផលិតកម្ម និងការនាំចេញក្នុងឆ្នាំខាងមុខ ។ ដូចនេះ សម្រាប់ឆ្នាំ ២០២៥, អនុវិស័យនេះ ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនថមថយ ក្នុងអត្រា ១០,៤% ដោយសារផលជះដោយផ្ទាល់ នៃការអនុវត្តពន្ធគយបដិការមកលើការនាំចេញផលិតផលកាត់ដេរ ទៅសហរដ្ឋអាម៉េរិក ដែលនឹងធ្វើឱ្យការបញ្ជាទិញពីទីផ្សារសហរដ្ឋអាម៉េរិកមាននិន្នាការថមថយជាងការរំពឹងទុក ។ ប៉ុន្តែ, កំណើននៃអនុវិស័យនេះជារួម ក៏នៅរក្សាបាននិន្នាការវិជ្ជមាន ដែលនឹងបន្តគាំទ្រដោយសកម្មភាពផលិតកម្ម ដើម្បីបម្រើដល់ការនាំចេញទៅទីផ្សារសំខាន់ៗផ្សេងទៀត តួយ៉ាងដូចជា សហភាពអឺរ៉ុប ជាដើម ។



**អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ** ត្រូវបានវាយតម្លៃថាមានកំណើនថមថយ មកនៅត្រឹមអត្រាប្រមាណ ៧,១% ក្នុងឆ្នាំ ២០២៤ ដោយសារការធ្លាក់ចុះនៃការនាំចេញបន្ទះសូឡាដែលជាបច្ច័យនៃការស៊ើបអង្កេតរបស់សហរដ្ឋអាម៉េរិក បណ្តាលឱ្យមានការបញ្ឈប់ការបញ្ជាទិញភ្លាមៗ និងការផ្អាកបណ្តោះអាសន្ននូវរោងចក្រផលិតសូឡាមួយចំនួននៅកម្ពុជា ។ ការ-នាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរជារួម មានកំណើនត្រឹម ៥,៧% ប៉ុន្តែការបន្តនិន្នាការរឹងមាំនៃការនាំចេញផលិតផលសក្តានុពលផ្សេងទៀត តួយ៉ាងដូចជា គ្រឿងបង្គុំអេឡិច-ត្រូនិក, សំបកកង់រថយន្ត និងគ្រឿងសង្ហារិម និងភាពល្អប្រសើរនៃឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុក ពោលគឺឧស្សាហកម្មដំឡើងរថយន្ត បានចូលរួមទ្រទ្រង់ដល់កំណើននៃអនុវិស័យនេះ ជារួម ។ ក្នុងឆ្នាំ ២០២៥, អនុវិស័យនេះ រំពឹងថានឹងងើបមកវិញ ប៉ុន្តែក្នុងអត្រាកំណើនយឺត ក្នុងរង្វង់ ៨,៧% ដែលជំរុញយ៉ាងសំខាន់ដោយការនាំចេញផលិតផលនៃឧស្សាហកម្មគន្លឹះផ្សេងទៀត (សំបកកង់រថយន្ត, គ្រឿងបង្គុំអេឡិចត្រូនិក និងគ្រឿងសង្ហារិម ជាដើម)

ទៅទីផ្សារសំខាន់ៗក្នុងតំបន់ ខណៈដែលការនាំចេញទៅទីផ្សារសហរដ្ឋអាម៉េរិក រំពឹងថានឹងមាននិន្នាការថមថយ ដោយសារឥទ្ធិពលនៃការអនុវត្តពន្ធគយបដិការ ។ យ៉ាងណាមិញ, អនុវិស័យនេះ ជារួមនៅបន្តរក្សាបាននិន្នាការកំណើនវិជ្ជមាន បើទោះបីមានល្បឿនទាប បើធៀបនឹងកំណើនក្នុងនិន្នាការធម្មតាយ៉ាងណាក្តី ។ បើផ្អែកតាមការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និងវិស័យឯកជន ពោលគឺតំបន់សេដ្ឋកិច្ចពិសេសសំខាន់ៗ (RGPPSEZ និង SHVSEZ) គម្រោងអនុម័តដែលសម្រេចបានជាប្រវត្តិសាស្ត្រ ក្នុងឆ្នាំ ២០២៤ ប្រមាណ ៤១៤ គម្រោងកន្លងទៅដែលមួយផ្នែកធំក៏សុទ្ធសឹងជាការវិនិយោគក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរ (គ្រឿងសង្ហារិម, វេចខ្ចប់, បង្គុំអគ្គិសនី, ផលិតចំណីសត្វ, កែច្នៃកសិ-ឧស្សាហកម្ម និងកែច្នៃឈើ) ជាដើម មួយចំនួននឹងក្លាយជាគម្រោងវិនិយោគជាក់ស្តែងក្នុងឆ្នាំ ២០២៥ ដែលនឹងចូលរួមបង្កើនតម្លៃបន្ថែមដល់វិស័យនេះ ។ ជាក់ស្តែង, បើផ្អែកតាមតំបន់សេដ្ឋកិច្ចពិសេសទាំងពីរ, ផលិតកម្មថ្មីៗក្នុងវិស័យឧស្សាហកម្មគន្លឹះៗដែលបានរៀបរាប់ខាងលើ នឹងចាប់ផ្តើមមានសកម្មភាពផលិតកម្មរបស់ខ្លួន ក្នុងឆមាសទី ២ ឆ្នាំ ២០២៥ នេះផងដែរ ។



**អនុវិស័យសំណង់** ត្រូវបានវាយតម្លៃថាបន្តងើបក្នុងល្បឿនទាប ជាមួយនឹងអត្រាកំណើន ក្នុងរង្វង់ ១,១% ក្នុងឆ្នាំ ២០២៤ ត្បិតវិស័យនេះនៅបន្តស្ថិតក្នុងដំណាក់កាលនៃការកែតម្រូវទីផ្សារ (Market correction) បានសេចក្តីថាសកម្មភាពសំណង់មួយចំនួនធំ ជាពិសេសសំណង់លំនៅឋានថ្លៃសមរម្យ (ថ្លៃក្រោម ១០ ម៉ឺនដុល្លារអាម៉េរិក) បន្តមានដំណើរការក្នុងទ្រង់ទ្រាយតូច សម្រាប់ផ្គត់ផ្គង់ដល់តម្រូវការក្នុងស្រុក ។ សម្រាប់ឆ្នាំ ២០២៤, សំណង់បម្រើឱ្យលំនៅឋាន ពោលគឺលំនៅឋានមានលក្ខណៈជាបុរី នៅតែចូលរួមយ៉ាងសំខាន់ក្នុងការជួយទ្រទ្រង់ដល់កំណើននៃអនុវិស័យនេះ ស្របពេលដែលការបន្តអនុវត្តវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល តួយ៉ាងដូចជា **វិធានការ ៨ ចំណុច** ក៏នៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយរក្សាលំនឹងអាជីវកម្មរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ ដើម្បីជានានូវដំណើរការសាងសង់ ក្នុងកាលៈទេសៈកែតម្រូវទីផ្សារ និងឆ្លើយតបទៅនឹងតម្រូវការក្នុងស្រុក ។ ជាមួយគ្នានេះ, វិស័យសំណង់បម្រើឱ្យឧស្សាហកម្ម ដូចជា រោងចក្រ និងឃ្លាំង ជាដើម ក៏មានការកើនគួរឱ្យកត់សម្គាល់ផងដែរ ឆ្លុះបញ្ចាំងពីនិន្នាការរឹងមាំនៃវិស័យកម្មន្តសាល ។ ក្នុងឆ្នាំ ២០២៥, វិស័យសំណង់ត្រូវបានប៉ាន់ស្មានថានឹងបន្តងើបយឺត ក្នុងអត្រាកំណើន ២,៤% ដែលនឹងបន្តទ្រទ្រង់ដោយសំណង់លំនៅឋានថ្លៃសមរម្យ ស្របពេលដែលសំណង់បម្រើឱ្យវិស័យឧស្សាហកម្មរំពឹងថានឹងបន្តកើន ហើយត្រូវបានសម្លឹងឃើញថានឹងក្លាយជាចន្ទល់កំណើនសក្តានុពលមួយយ៉ាងសំខាន់ ដែលចូលរួមគាំទ្រកំណើនដល់អនុវិស័យសំណង់ជារួម ខណៈការវិនិយោគលើសំណង់ថ្លៃខ្ពស់ នៅមិនទាន់ងើបឡើងវិញគួរឱ្យកត់សម្គាល់នៅឡើយ គួបផ្សំនឹងភាព-មិនប្រាកដប្រជាខ្ពស់នៃកត្តាសេដ្ឋកិច្ច និងទំនុកចិត្តវិនិយោគ ។ គួរបញ្ជាក់ថា, ការបន្តអនុវត្តវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ទាំងការរក្សាលំនឹងអាជីវកម្មរបស់ក្រុមហ៊ុនអភិ-

វឌ្ឍន៍ និងការជំរុញចរន្តទិញ-លក់ តាមរយៈការលើកលែងពន្ធប្រថាប់ត្រា និងវិធានការផ្សេងទៀត ក៏នឹងបន្តចូលរួមចំណែកយ៉ាងសំខាន់ក្នុងការគាំពារដល់អនុវិស័យនេះផងដែរ ។



**អនុវិស័យផលិតកម្មម្ហូបអាហារ** និង **អនុវិស័យផលិតកម្មភេសជ្ជៈ និងថ្នាំជក់** ត្រូវបានវាយ-តម្លៃថាសម្រេចបានកំណើន ៦,១% និង ៣,៣% រៀងគ្នា ក្នុងឆ្នាំ ២០២៤ ដែលឆ្លុះបញ្ចាំងពីការបន្តរក្សាស្ថិរភាពនៃសកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក គួបផ្សំនឹងការបន្តកើនឡើងនៃភ្ញៀវទេសចរ និងព្រឹត្តិការណ៍ទេសចរផ្សេងៗ ដែលក៏បានជួយជំរុញដល់សកម្មភាពទិញ-លក់ និងលើកកម្ពស់ដល់ផលិតកម្ម ជារួម ។ សម្រាប់ឆ្នាំ ២០២៥, អនុវិស័យផលិតកម្មម្ហូបអាហារ និង អនុវិស័យផលិតកម្មភេសជ្ជៈ និងថ្នាំជក់ ត្រូវបានប៉ាន់ស្មានថានឹងសម្រេចបានអត្រាកំណើនក្នុងល្បឿនទាបបន្តិច ប៉ុន្តែក្នុងនិន្នាការវិជ្ជមាន ក្នុងរង្វង់ ៥,៤% និង ៤,០% រៀងគ្នា ដែលនៅបន្តគាំទ្រដោយការបន្តនិន្នាការល្អនៃសកម្មភាពផលិត បម្រើដល់តម្រូវការក្នុងស្រុក បើទោះបីស្ថានភាពសេដ្ឋកិច្ច និងការប្រើប្រាស់ក្នុងស្រុក ក៏ដូចជាសកម្មភាពចាយ-វាយ អាចទទួលរងបច្ច័យអវិជ្ជមានដោយប្រយោលពីគោលនយោបាយពន្ធគយបដិការយ៉ាងណាក្តី ។ លើសពីនេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រ និងគោលនយោបាយនានា ក្នុងការគាំទ្រឧស្សាហកម្មធុនតូច និងមធ្យម ជាពិសេសការបន្តអនុវត្តនូវ **«យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ ២០២៣-២០២៨»** និងការបន្តធ្វើឱ្យប្រសើរនៃប្រព័ន្ធអេកូឡូស៊ីរបស់សហគ្រាសធុនតូច និងមធ្យម នឹងកាន់តែចូលរួមកសាងមូលដ្ឋានគ្រឹះ និងពង្រឹងការរីកលូតលាស់ ជាពិសេសសហគ្រាសធុនតូច និងមធ្យមក្នុងអនុវិស័យនេះ ។ ទន្ទឹមនេះ, ការផ្តល់ហិរញ្ញប្បទានក្នុងលក្ខខណ្ឌអនុគ្រោះ និងអត្រាការប្រាក់ទាបដល់សហ-គ្រាសក្នុងវិស័យអាទិភាព តាមរយៈធនាគារសហគ្រាសធុនតូច និងមធ្យម ក៏នឹងជួយជំរុញការវិនិយោគបន្ថែមលើការកែច្នៃកសិ-ឧស្សាហកម្ម ជាពិសេសផ្នែកម្ហូបអាហារ, ស្របពេលដែល **«មូលនិធិអភិវឌ្ឍន៍ជំនាញ»** និង **«មូលនិធិសហគ្រិនភាព»** ក៏នឹងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការបន្តពង្រឹងការបណ្តុះបណ្តាលជំនាញ និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងគម្លាតនៃជំនាញ និងតម្រូវការកម្លាំងពលកម្មលើទីផ្សារ ផងដែរ ។

## ■ វិស័យសេវាកម្ម

**វិស័យសេវាកម្ម** ត្រូវបានវាយតម្លៃថាសម្រេចបានកំណើន ក្នុងរង្វង់ ៤,៥% ក្នុងឆ្នាំ ២០២៤ ដែលបន្តទ្រទ្រង់ដោយអនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ, អនុវិស័យលក់ដុំ-រាយ និងការងើបវិញជាសន្សឹមៗនៃអនុវិស័យអចលនទ្រព្យ ស្របពេលដែលវិស័យដឹកជញ្ជូន និងស្តុក មានកំណើនល្អ ប៉ុន្តែអនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង នៅបន្តថមថយ ។ សម្រាប់ឆ្នាំ ២០២៥, វិស័យសេវាកម្មមានកំណើនថមថយបន្តិចក្នុងអត្រា ៣,៨% ដោយសារការថមថយជាងការរំពឹងទុកនៃអនុវិស័យលក់ដុំ-រាយ ពោលគឺសកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក ក្រោមការរំពឹងទុកផលប៉ះពាល់ដោយប្រយោល នៃគោលនយោបាយពន្ធគយបដិការលើចំណូលរបស់ប្រជាជន ស្របពេលដែលអនុវិស័យដឹកជញ្ជូន និងស្តុក ក៏មាននិន្នាការថមថយដោយសារកំណើនយឺតជាងការរំពឹងទុកនៃអនុវិស័យគាំទ្រ តួយ៉ាងដូចជាវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ។

**អនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ** ត្រូវបានវាយតម្លៃថាបន្តស្ទុះឡើងវិញពីមូលដ្ឋានទាប ក្នុងអត្រាកំណើនប្រមាណ ១២,៩% ក្នុងឆ្នាំ ២០២៤ ការបន្តនិន្នាការកើននៃលំហូរទេសចរអន្តរជាតិ និងទេសចរជាតិ ។ ជាក់ស្តែង, ក្នុងឆ្នាំ ២០២៤ នេះ, ចំនួនទេសចរអន្តរជាតិ គឺកើនឡើងលើសកម្រិតមុនវិបត្តិជំងឺកូវីដ-១៩ (ប្រមាណ ៦,៧ លាននាក់) ស្របពេលដែលទេសចរជាតិក៏កើនឡើងគួរឱ្យកត់សម្គាល់ (ប្រមាណ ២២,៥ លាននាក់) ។ ទោះជាយ៉ាងនេះក្តី, ការកើនខ្ពស់នៃទេសចរពុំបានផ្តល់តម្លៃបន្ថែមខ្ពស់ដល់កម្រិតសក្តានុពលសម្រាប់អនុវិស័យនេះនៅឡើយទេ ត្បិតចំនួនទេសចរភាគច្រើនគឺជាទេសចរក្នុងតំបន់ ដែលមានរយៈពេលស្នាក់នៅខ្លី និងចំណាយទាប ខណៈដែលឥរិយាបថនៃការធ្វើដំណើរកម្សាន្តនាបច្ចុប្បន្ន គឺជាដំណើរកម្សាន្តបែបបុគ្គល ខុសពីនិន្នាការមុនវិបត្តិជំងឺកូវីដ-១៩ ដែលជាដំណើរកម្សាន្តបែបទូរ (Tour Group) ។ សម្រាប់ឆ្នាំ ២០២៥, អនុវិស័យនេះត្រូវបានប៉ាន់ស្មាននឹងកើនឡើងក្នុងអត្រា ៨,៦% គាំទ្រដោយការបន្តនិន្នាការកើនឡើងនៃលំហូរទេសចរអន្តរជាតិ ដែលរំពឹងថានឹងអាចកើនឡើងដល់ប្រមាណជាង ៧ លាននាក់ ស្របពេលដែលទេសចរជាតិក៏នៅបន្តនិន្នាការប្រសើរ ។ វិធានការគោលនយោបាយបន្តធ្វើឱ្យប្រសើរឡើងនូវផ្នែកផ្គត់ផ្គង់ (Supply side factor) ក៏នឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរ និងលើកកម្ពស់កំណើន ដែលក្នុងនោះរួមមាន ការបន្តជំរុញជើងហោះហើរត្រង់, ការបន្តលើកកម្ពស់គោលដៅទេសចរណ៍កម្ពុជាបន្ថែមទៀត, ការបន្តផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍, ការដាក់ឱ្យដំណើរការនូវអាកាសយានដ្ឋាន **«អាកាសយានដ្ឋានអន្តរជាតិតេជោតាខ្មៅ»**, ការបន្តកាត់បន្ថយថ្លៃសេវាផ្សេងៗ និងការពង្រឹងប្រវាក់តម្លៃនៃវិស័យទេសចរណ៍ ដើម្បីជំរុញការប្រកួតប្រជែង រួមមាន ការលុបចោលនូវសេវាថ្លៃសន្តិសុខក្នុងអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ និងការបញ្ចុះថ្លៃទិដ្ឋាការ ជាដើម ក៏ដូចជាការបន្តអនុវត្តផែនការមេអភិវឌ្ឍន៍ទេសចរណ៍នៅតាមបណ្តាខេត្តសំខាន់ៗ និងការរៀបចំព្រឹត្តិការណ៍ជាតិធំៗ ក្នុងប្រទេស ។

**អនុវិស័យអចលនទ្រព្យ** ត្រូវបានវាយតម្លៃថាងើបឡើងក្នុងអត្រាកំណើន ១,២% ក្នុងឆ្នាំ ២០២៤ គាំទ្រដោយការកើនឡើងនៃចរន្តទិញ-លក់លំនៅឋាន ពោលគឺខុនដូ និងលំនៅឋានមានលក្ខណៈជាបុរី ស្របពេលដែលការជួលឃ្លាំង និងដី តួយ៉ាងដូចជា ការផ្គត់ផ្គង់ និងការជួលដី ក្នុងតំបន់សេដ្ឋកិច្ចពិសេស បម្រើឱ្យវិស័យឧស្សាហកម្ម ក៏មាននិន្នាការកើនគួរឱ្យកត់សម្គាល់ក្នុងឆ្នាំ ២០២៤ ។ សម្រាប់ឆ្នាំ ២០២៥, អនុវិស័យនេះត្រូវបានប៉ាន់ស្មានថានឹងបន្តកើនឡើងក្នុងរង្វង់ ២,៧% បន្តគាំទ្រដោយចរន្តទិញ-លក់លំនៅឋាន ជំរុញដោយតម្រូវការក្នុងស្រុក ស្របពេលដែលសកម្មភាពអចលនវត្ថុបម្រើឱ្យវិស័យឧស្សាហកម្ម នៅតែបន្តរក្សាបានចលនការរឹងមាំ ហើយចូលរួមគាំទ្រដល់អនុវិស័យនេះ ។ ការបន្តអនុវត្តវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ជាពិសេសការលើកលែងពន្ធប្រថាប់ត្រាចំពោះលំនៅឋានថ្លៃក្រោម ៧ ម៉ឺនដុល្លារអាម៉េរិក និងការលើកលែងពន្ធប្រថាប់ត្រាចំពោះការទិញ-លក់ និង/ឬ ផ្ទេរកម្មសិទ្ធិលើកដំបូង (First-time home buyer) ចំពោះលំនៅឋានថ្លៃក្រោម ២១ ម៉ឺនដុល្លារ

អាម៉េរិក ដែលសុទ្ធសឹងជាវិធានការគាំទ្រផ្នែកតម្រូវការ ក៏នឹងបន្តជំរុញសកម្មភាពទិញ-លក់អចលនវត្ថុ ក្នុងឆ្នាំ ២០២៥ នេះ ។

**អនុវិស័យលក់ដុំ-រាយ** ត្រូវបានវាយតម្លៃថាសម្រេចបាននូវកំណើន ៣,៩% ក្នុងឆ្នាំ ២០២៤ គាំទ្រយ៉ាងសំខាន់ ដោយការបន្តរក្សាបានស្ថិរភាពនៃសកម្មភាពចាយវាយក្នុងស្រុកលើទំនិញចាំបាច់ ជាពិសេស ផ្នែកម្ហូបអាហារ (Food items) ខណៈដែលការប្រើប្រាស់ទំនិញមិនមែនម្ហូបអាហារ និងទំនិញប្រណិត (Non-food and luxury goods) ដូចជាគ្រឿងអេឡិចត្រូនិក និងរថយន្ត ជាដើម មានការថមថយបន្តិច ។ សម្រាប់ឆ្នាំ ២០២៥, អនុវិស័យនេះ ត្រូវបានប៉ាន់ស្មានថាមានកំណើនថមថយបន្តិច ក្នុងអត្រា ៣,៤% ដោយសារការរំពឹងទុកផលប៉ះពាល់ដោយប្រយោលនៃគោលនយោបាយពន្ធគយបដិការ មកលើសកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក ដោយសារការថមថយនៃវិស័យប្រភពចំណូល ជាពិសេសវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ។ ទោះជាយ៉ាងណា, សកម្មភាពចាយវាយជារួម នៅបន្តរក្សាបាននិន្នាការវិជ្ជមាន ដែលបន្តគាំទ្រដោយការប្រើប្រាស់លើទំនិញចាំបាច់ជាមួយគ្នានេះ ការផ្លាស់ប្តូរឥរិយាបថអាជីវកម្មពីបែបប្រពៃណី ទៅជាថ្នាលអនឡាញ ដូចជា ពាណិជ្ជកម្មអេឡិចត្រូនិក (E-commerce) គួបផ្សំនឹងការបន្តធ្វើទំនើបកម្ម និងសាមញ្ញកម្មនៃប្រព័ន្ធទូទាត់ ក៏នឹងផ្តល់ភាពងាយស្រួលបន្ថែមទៀតដល់ប្រតិបត្តិការទិញ-លក់ ។

**អនុវិស័យដឹកជញ្ជូន និងស្តុក** ត្រូវបានវាយតម្លៃថាមានកំណើនល្អ ក្នុងអត្រា ៧,២% ក្នុងឆ្នាំ ២០២៤ គាំទ្រដោយនិន្នាការប្រសើរនៃវិស័យគាំទ្រ ដូចជា វិស័យកាត់ដេរ និងទេសចរណ៍ និងការបន្តនិន្នាការរឹងមាំនៃការដឹកជញ្ជូនបញ្ញើរហ័ស (Express service) ។ ជាក់ស្តែង, ក្នុងឆ្នាំ ២០២៤, ការដឹកជញ្ជូនតាមកំពង់ផែមានការមមាញឹកខ្លាំង ហើយក្នុងនោះបរិមាណកុងតឺន័រឆ្លងកាត់តាមកំពង់ផែស្វយ័តព្រះសីហនុ មានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយសម្រេចបានដល់ ១ លានកុងតឺន័រ (TEU) ។ សម្រាប់ឆ្នាំ ២០២៥, អនុវិស័យនេះ ក៏ត្រូវបានប៉ាន់ស្មានថានឹងមានកំណើនថមថយបន្តិច ក្នុងរង្វង់ ៥,៤% ដោយសារការថមថយអនុវិស័យគាំទ្រ ដូចជា វិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ជាដើម។ ប៉ុន្តែ, រនុវិស័យនេះនៅបន្តរក្សាបាននិន្នាការវិជ្ជមាន ដែលបន្តទ្រទ្រង់ដោយការដឹកជញ្ជូនបែបរហ័ស (Express services) និងសកម្មភាពដឹកជញ្ជូនក្នុងវិស័យទេសចរណ៍ គួបផ្សំនឹងការបន្តវិនិយោគហេដ្ឋារចនាសម្ព័ន្ធគាំទ្រ តួយ៉ាងដូចជា ការដាក់ឱ្យប្រើប្រាស់អាកាសយានដ្ឋានថ្មី និងការបន្តពង្រីកសមត្ថភាពផ្ទុករបស់កំពង់ផែទាំងពីរ ក៏ដូចជាការបន្តអនុវត្តនូវ «ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធ ដឹកជញ្ជូនអន្តរមធ្យោបាយកម្ពុជា ២០២២-២០៣០» ។

**អនុវិស័យបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍** ត្រូវបានវាយតម្លៃថាបន្តមានកំណើនល្អ ក្នុងរង្វង់ ៧,០% ក្នុងឆ្នាំ ២០២៤ ដែលបន្តគាំទ្រដោយការកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិតពោលទាំងចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិត និងទំហំអ៊ីនធឺណិត គួបផ្សំនឹងការបន្តបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ តួយ៉ាងដូចជា ការវិនិយោគលើបង្គោលសេវាទូរស័ព្ទជាដើម ។ ក្នុងឆ្នាំ ២០២៥, អនុវិស័យនេះត្រូវបានប៉ាន់ស្មានថានឹងបន្តកើនឡើង ក្នុងអត្រា

កំណើន ៧,១% គាំទ្រដោយការបន្តនិន្នាការកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិតស្ទើរតែលើគ្រប់វិស័យ និងគ្រប់ប្រភេទអាជីវកម្ម គួបផ្សំនឹងការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដូចមានក្នុងគោលនយោបាយសំខាន់ៗ តួយ៉ាងដូចជា **«គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨»**, **«គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥»** និង **«ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥»** ជាដើម ។

**អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង** ត្រូវបានវាយតម្លៃថានឹងបន្តមានកំណើនអវិជ្ជមាន ក្នុងរង្វង់ -០,៦% ក្នុងឆ្នាំ ២០២៤ ដោយសារការបន្តស្ថិតក្នុងកម្រិតខ្ពស់នៃចំណាយការប្រាក់ និងចំណាយប្រតិបត្តិការ ដែលធ្វើឱ្យចំណូលសុទ្ធធ្លាក់ចុះ គួបផ្សំនឹងកំណើនទាបនៃឥណទានថ្មី ខណៈដែលកម្រិតអត្រាការប្រាក់គោលនៅបន្តកម្រិតខ្ពស់នៅឡើយ បើទោះបីគោលនយោបាយរឹតបន្តឹងរូបិយវត្ថុបន្តត្រូវបានបន្ធូរបន្ថយយ៉ាងណាក្តី ។ យ៉ាងណាមិញ, អនុវិស័យធានារ៉ាប់រងនៅបន្តមាននិន្នាការកើនឡើង ដែលបន្តជំរុញដោយការធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងសុខភាព ។ ក្នុងឆ្នាំ ២០២៥, អនុវិស័យនេះត្រូវបានប៉ាន់ស្មានថានឹងងើបវិញក្នុងល្បឿនយឺត ក្នុងអត្រាប្រមាណ ០,៩% ដោយសារការរំពឹងទុកនៃបច្ច័យពីការបន្ធូរបន្ថយនូវអត្រាការប្រាក់គោល ដែលធ្វើឱ្យសម្ពាធនៃចំណាយការប្រាក់មានការថមថយ គួបផ្សំនឹងការបន្តងើបវិញសន្សឹមៗនៃការផ្តល់ឥណទានថ្មី ។ យ៉ាងណាមិញ, ភាពមិនប្រាកដប្រជានៃបរិការណ៍ខាងក្រៅ ដែលនាំឱ្យល្បឿននៃការបន្ធូរបន្ថយគោលនយោបាយរឹតបន្តឹងរូបិយវត្ថុយឺត ឬ ការរឹតបន្តឹងឡើងវិញ នឹងបង្កជាផលរំខានដល់ការងើបឡើងវិញនៃអនុវិស័យផងដែរ ។

## ■ វិស័យកសិកម្ម

**វិស័យកសិកម្ម** ក្នុងឆ្នាំ ២០២៤ ត្រូវបានវាយតម្លៃថានៅបន្តរក្សាបានស្ថិរភាព ក្នុងអត្រាកំណើន ០,៩% គាំទ្រដោយភាពប្រសើរនៃអនុវិស័យដំណាំ និងអនុវិស័យផលផល ខណៈដែលអនុវិស័យចិញ្ចឹមសត្វមានការធ្លាក់ចុះ ។ ក្នុងឆ្នាំ ២០២៥, វិស័យកសិកម្ម ក៏នៅរក្សាបានកំណើនក្នុងរង្វង់ ០,៩% ដែលបន្តគាំទ្រដោយអនុវិស័យដំណាំ និងនេសាទ ស្របពេលដែលអនុវិស័យចិញ្ចឹមសត្វ រំពឹងថានឹងងើបឡើងវិញសន្សឹមៗ ។

**អនុវិស័យដំណាំ** ត្រូវបានវាយតម្លៃថាបន្តសម្រេចបានកំណើនរឹងមាំ ក្នុងអត្រា ១,៦% ក្នុងឆ្នាំ ២០២៤ ដោយសារការបន្តកំណើនល្អនៃផលិតកម្មស្រូវ ក៏ដូចជាដំណាំសាកវប្បកម្ម និងឧស្សាហកម្ម តួយ៉ាងដូចជា ស្វាយចន្ទី, ដំឡូងមី និងកៅស៊ូ ដោយសារកត្តាថ្លៃល្អ ខណៈបញ្ហាគ្រោះធម្មជាតិ និងសត្វល្អិតចង្រៃមានផលប៉ះពាល់តិចតួចប៉ុណ្ណោះដល់ផលិតកម្ម ។ សម្រាប់ឆ្នាំ ២០២៥, អនុវិស័យដំណាំត្រូវបានប៉ាន់ស្មានថានៅបន្តរក្សាស្ថិរភាពកំណើន ប៉ុន្តែក្នុងល្បឿនថមថយបន្តិច ក្នុងរង្វង់ ១,៤% ដោយសារការរំពឹងទុកការថមថយផលិតកម្មស្រូវ បណ្តាលមកពីការប្រែប្រួលថ្លៃលើទីផ្សារអន្តរជាតិ ត្បិតឥណ្ឌាចាប់ផ្តើមធ្វើការនាំចេញវិញ គួបផ្សំនឹងការរំពឹងទុកនៃការថមថយតម្រូវការពីទីផ្សារសហភាពអឺរ៉ុប ពាក់ព័ន្ធនឹងបញ្ហាបទដ្ឋានបច្ចេកទេសប្រើប្រាស់សារធាតុគីមី ។ យ៉ាងណាមិញ, ដំណាំសាកវប្បកម្ម និងឧស្សាហកម្មចម្បង

ផ្សេងទៀតនៅបន្តមានកំណើនល្អ ហើយទ្រទ្រង់ដល់កំណើននៃអនុវិស័យដំណាំ ជារួម ។ ជាមួយគ្នានេះ, អនុវិស័យនេះ ក៏ត្រូវបានគាំទ្រយ៉ាងសំខាន់ដោយវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាលដូចជា ការដាក់ចេញ និងអនុវត្តនូវ **«កម្មវិធីធានាស្ថិរភាពថ្លៃកសិផល», «កម្មវិធីហិរញ្ញប្បទានក្រោមធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម»** និង **«ការពង្រាយមន្ត្រីកសិកម្មនៅតាមឃុំ-សង្កាត់នៃគ្រប់បណ្តាខេត្ត»** ជាដើម ។

**អនុវិស័យចិញ្ចឹមសត្វ** ត្រូវបានវាយតម្លៃថាមានកំណើនអវិជ្ជមាន ក្នុងអត្រា -១,៩% ក្នុងឆ្នាំ ២០២៤ ដោយសារការកាត់បន្ថយផលិតកម្មក្នុងស្រុក ឆ្លើយតបទៅនឹងការប្រែប្រួលក្នុងនិន្នាការអវិជ្ជមាននៃថ្លៃ ជាពិសេសថ្លៃសាច់ជ្រូកលើទីផ្សារ ។ ក្នុងឆ្នាំ ២០២៥, អនុវិស័យនេះ ត្រូវបានប៉ាន់ស្មានថានឹងងើបវិញសន្សឹមៗ ក្នុងអត្រា ០,២% ដោយសារការរំពឹងទុកការចាប់ផ្តើមងើបឡើងវិញនៃទំនុកចិត្តវិនិយោគ ស្របពេលរាជរដ្ឋាភិបាលនៅតែបន្តផ្តល់ការយកចិត្តទុកដាក់ខ្ពស់លើវិធានការអន្តរាគមន៍ និងបទប្បញ្ញត្តិ ទាំងឡាយពាក់ព័ន្ធនឹងការនាំចូលសាច់បង្កក ដើម្បីគាំពារដល់ផលិតកម្មក្នុងស្រុក ។

**អនុវិស័យនេសាទ** ត្រូវបានវាយតម្លៃថាបន្តមានកំណើនក្នុងរង្វង់ ០,៩% ក្នុងឆ្នាំ ២០២៤ ជំរុញដោយកំណើនខ្ពស់នៃផលចាប់ទឹកសាប ដោយសារការស្តារឡើងវិញនៃជម្រកធម្មជាតិ ក្រោម កិច្ចខិតខំបង្ក្រាបបទល្មើសនេសាទក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ។ ក្នុងឆ្នាំ ២០២៥, អនុវិស័យនេសាទត្រូវបានប៉ាន់ស្មានថានឹងបន្តមានកំណើនវិជ្ជមានក្នុងរង្វង់ ០,២% ដែលបន្តគាំទ្រដោយនិន្នាការល្អនៃផលចាប់ទឹកសាប ខណៈផលិតកម្មវារីវប្បកម្មនៅបន្តប្រឈមនឹងបញ្ហាទីផ្សារផ្គត់ផ្គង់ ។

## ■ អតិផរណា និងអត្រាប្តូរប្រាក់

អត្រាអតិផរណា (មធ្យមប្រចាំឆ្នាំ) បន្តថមថយមកត្រឹម ០,៨% ប៉ុណ្ណោះ ក្នុងឆ្នាំ ២០២៤ ដោយសារការបន្តធ្លាក់ចុះនៃថ្លៃប្រេងលើទីផ្សារអន្តរជាតិ, ខណៈកំណើននៃថ្លៃម្ហូបអាហារបន្តមានស្ថិរភាព, ប៉ុន្តែងើបឡើងវិញបន្តិចក្នុងត្រីមាសទី ៤ ដោយសារការកើនឡើងនូវសកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក ។ ក្នុងឆ្នាំ ២០២៤, អត្រាប្តូរប្រាក់ផ្លូវការ (រៀល/ដុល្លារអាម៉េរិក) បន្តវិលត្រលប់ទៅប្រក្រតីភាពវិញ ក្នុងរង្វង់ប្រមាណ ៤ ០៧០ រៀល/ដុល្លារអាម៉េរិក ដោយសារការបន្ធូរបន្ថយជាសន្សឹមៗ នៃគោលនយោបាយរឹតបន្តឹងរូបិយវត្ថុរបស់សហរដ្ឋអាម៉េរិក គួបផ្សំនឹងការបន្តអន្តរាគមន៍របស់ធនាគារជាតិក្នុងការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ។ ក្នុងឆ្នាំ ២០២៥ កំណើននៃអត្រាអតិផរណា ត្រូវបានប៉ាន់ស្មានថានឹងងើប ក្នុងរង្វង់ ៣,០%, មួយផ្នែក ឆ្លុះបញ្ចាំងពីមូលដ្ឋានទាបនៃឆ្នាំចាស់, និងមួយផ្នែកទៀត, ដោយសារការបន្តកើនឡើងនៃសកម្មភាពចាយវាយក្នុងស្រុក ស្របនឹងនិន្នាការសេដ្ឋកិច្ច ខណៈពេលដែលថ្លៃទំនិញអន្តរជាតិនៅបន្តមានស្ថិរភាព ។ អត្រាប្តូរប្រាក់ផ្លូវការ (រៀល/ដុល្លារអាម៉េរិក) រំពឹងថានឹងស្ថិតក្នុងរង្វង់ប្រមាណ ៤ ០៥៤ រៀល/ដុល្លារអាម៉េរិក ដោយសារការបន្តបន្ធូរបន្ថយសម្ពាធនៃគោលនយោបាយរឹតបន្តឹងរូបិយវត្ថុរបស់សហរដ្ឋអាម៉េរិក គួបផ្សំនឹងការបន្តអនុវត្តវិធានការអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា ក្នុងការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ។

## ■ វិស័យខាងក្រៅ

សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) បន្តមានអតិរេកក្នុងកម្រិតទាប ក្នុងអត្រាប្រមាណ ០,៥% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៤ ធៀបនឹងប្រមាណ ១,៣% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៣ ដោយសារភាពរឹងមាំនៃចំណូលវិស័យទេសចរណ៍ ខណៈឱនភាពពាណិជ្ជកម្ម មានការរីកធំបន្តិច ។ ក្នុងនោះ, ការនាំចូលបន្តកើនឡើងខ្ពស់ ដែលជំរុញដោយការនាំចូលវត្ថុធាតុដើមផលិតកម្ម សម្ភារសំណង់ យានយន្ត និងទំនិញប្រើប្រាស់ផ្សេងទៀត ស្របពេលដែលការនាំចេញក៏បន្តរក្សាបានចលនការរឹងមាំ ជំរុញដោយការនាំចេញផលិតផលកម្មន្តសាល និងការនាំចេញកសិផល ។ ជាមួយគ្នានេះ, ចំណូលពីវិស័យទេសចរណ៍ ក៏បន្តងើបឡើង ឆ្លុះបញ្ចាំងពីនិន្នាការល្អប្រសើរនៃលំហូរភ្ញៀវទេសចរអន្តរជាតិ ក៏ដូចជាការបន្តងើបឡើងវិញនៃវិស័យទេសចរណ៍ ជារួម ។ លំហូរវិនិយោគផ្ទាល់ពីបរទេស កើនឡើងក្នុងអត្រាកំណើន ១១,០% ឬប្រមាណ ៩,៣% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៤ ជំរុញដោយលំហូរវិនិយោគទៅក្នុងវិស័យកម្មន្តសាល គួយ៉ាងដូចជា វិស័យកាត់ដេរ, ផលិតកម្មសំបកកង់រថយន្ត, វេចខ្ចប់កែច្នៃចំណីអាហារ និងលោហធាតុ ជាដើម ខណៈដែលការវិនិយោគក្នុងវិស័យហិរញ្ញវត្ថុ, សំណង់ និងអចលនទ្រព្យ មានការថមថយ ។ ការណ៍នេះ ធ្វើឱ្យទុនបម្រុងអន្តរជាតិបន្តពូនគរ ក្នុងទំហំប្រមាណ ២២ ៥១១ លានដុល្លារអាម៉េរិក ឬ ប្រមាណ ៩,៦ ខែ នៃការនាំចូល ។

ដោយឡែក, ក្នុងឆ្នាំ ២០២៥ សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) រំពឹងថានឹងមានឱនភាព ក្នុងរង្វង់ -១,០% នៃ ផ.ស.ស. ឆ្លុះបញ្ចាំងពីការវិលត្រលប់ទៅរកប្រក្រតីភាពវិញជាសន្សឹមៗនៃឱនភាពគណនីចរន្ត ស្របពេលចំណូលពីវិស័យទេសចរណ៍នឹងបន្តនិន្នាការកើនឡើង ។ ក្នុងនោះ បើទោះបីការនាំចេញអាចនឹងមានសន្ទុះកំណើនថមថយជាងឆ្នាំ ២០២៤ ក៏ការនាំចេញជារួមនៅបន្តមាននិន្នាការវិជ្ជមាន ដែលបន្តគាំទ្រដោយការនាំចេញផលិតផលកាត់ដេរ ផលិតផលកម្មន្តសាលមិនមែនកាត់ដេរ និងការនាំចេញផលិតផលកសិផល ។ ជាមួយគ្នានេះ, ការនាំចូល ជារួម ក៏នៅបន្តគាំទ្រដោយការនាំចូលវត្ថុដើមផលិតកម្ម និងទំនិញប្រើប្រាស់ បើទោះបីក្នុងល្បឿនទាបជាងការរំពឹងទុកយ៉ាងណាក្តី ។ លើសពីនេះ, ចំណូលពីវិស័យទេសចរណ៍ ក៏នឹងបន្តនិន្នាការកំណើនរឹងមាំ ដោយសារការរំពឹងទុកការបន្តកើនឡើងនៃភ្ញៀវទេសចរអន្តរជាតិ ស្របពេលដែលរាជរដ្ឋាភិបាល ក៏បាននិងកំពុងដាក់ចេញនូវវិធានការគោលនយោបាយគាំទ្រ ដើម្បីបន្តលើកកម្ពស់វិស័យទេសចរណ៍ ជារួម ។ ទន្ទឹមនេះ, លំហូរវិនិយោគផ្ទាល់ពីបរទេសរំពឹងថានឹងបន្តមាននិន្នាការរឹងមាំ ជាមួយនឹងអត្រាកំណើន ក្នុងរង្វង់ប្រមាណ ៨,៦% ឬ ប្រមាណ ៩,៤% នៃ ផ.ស.ស. ដែលក្នុងនោះលំហូរវិនិយោគទៅក្នុងវិស័យកម្មន្តសាលទាំងកាត់ដេរ និងមិនមែនកាត់ដេរ ។ ក្នុងន័យនេះ, ទុនបម្រុងអន្តរជាតិ ក៏រំពឹងថានឹងបន្តកើន ដែលអាចធានាដល់ការនាំចូលប្រមាណ ៧,៦ ខែ ស្មើនឹងប្រមាណ ២៤ ៤៥០ លានដុល្លារអាម៉េរិក ។

## ខ. ទស្សនវិស័យសេដ្ឋកិច្ចរយៈពេលមធ្យម ឆ្នាំ ២០២៦-២០២៨

សម្រាប់ឆ្នាំ ២០២៦, សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងបន្តសម្រេចបានកំណើន **ក្នុងរង្វង់ ៥,០%** ដោយសារការរំពឹងទុកផលប៉ះពាល់យ៉ាងពេញទំហឹង នៃគោលនយោបាយពន្ធគយបដិការលើវិស័យបម្រើការនាំចេញ គួយ៉ាងវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ និងផលជះមកលើវិស័យគាំទ្រកំណើនផ្សេងទៀត ដូចជា វិស័យដឹកជញ្ជូន និងស្តុក និងលក់ដុំ-រាយ ។ ក្នុងរយៈពេលមធ្យមខាងមុខ (២០២៧-២០២៨), សេដ្ឋកិច្ចកម្ពុជា ត្រូវបានព្យាករថានឹងងើបឡើងវិញជាសន្សឹម ក្នុងអត្រាកំណើនជាមធ្យម **ប្រមាណ ៥,៦%** ដោយសារការរំពឹងទុកការងើបឡើងវិញជាបណ្តើរៗនៃវិស័យបម្រើការនាំចេញ គួបផ្សំនឹងការកែតម្រូវជាបន្តបន្ទាប់ (Adjustment) នៃទីផ្សារ, ទាំងការនាំចេញរបស់កម្ពុជា ក្នុងវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ជាពិសេសការពង្រីក

ទីផ្សារថ្មីក្រៅពីទីផ្សារសហរដ្ឋអាម៉េរិក, ក៏ដូចជាការបន្សាំខ្លួនបានទៅនឹងវិបត្តិ/ផលប៉ះពាល់នៃបណ្ដាវិស័យសេដ្ឋកិច្ច ក៏ដូចជាអាជីវកម្មទូទៅ ។ គួរឱ្យកត់សម្គាល់ថា, សន្ទុះកំណើនក្នុងរយៈពេលមធ្យមទៅខាងមុខ (ក្នុងបរិការណ៍នៃការអនុវត្តពន្ធគយបដិការ) របស់កម្ពុជា គឺមានសភាពយឺតបើធៀបនឹងការគិតគូរក្នុងបរិការណ៍មុនគោលនយោបាយពន្ធគយបដិការ (ជាមធ្យមប្រមាណ ៦,៥%) សបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ពីទំហំនៃផលប៉ះពាល់ និងស្លាកស្នាមយ៉ាងជ្រៅលើការនាំចេញ និងវិស័យចន្ទល់កំណើនរបស់សេដ្ឋកិច្ចជាតិ ខណៈដែលល្បឿននៃការធ្វើពិពិធកម្ម និងសមត្ថភាពនៃការបង្វែរទីផ្សារនាំចេញរបស់កម្ពុជា ក្នុងរយៈពេលខ្លីខាងមុខ អាចនៅមានកម្រិត ។ ក្នុងន័យនេះ, ការពន្លឿនការអនុវត្តវិធានការ និងគោលនយោបាយជំរុញភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់នៃសង្គម-សេដ្ឋកិច្ច ជាពិសេសការពង្រឹងការអនុវត្តនូវ **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** និងការដាក់ឱ្យអនុវត្តនូវ **«កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និង ពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច នៅក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ ឆ្នាំ ២០២៥-២០២៨»** និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀត នឹងកាន់តែមានសារសំខាន់ជាចលករក្នុងការជំរុញល្បឿន និងគាំពារកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម និងវែងខាងមុខ ។



**វិស័យឧស្សាហកម្ម** ត្រូវបានព្យាករថានឹងមានកំណើនជាមធ្យមប្រមាណ ៧,៤% សម្រាប់រយៈពេលមធ្យម ២០២៦-២០២៨ ។ **ក្នុងនោះ, សម្រាប់ឆ្នាំ ២០២៦, វិស័យនេះត្រូវបានព្យាករថាមានកំណើន ៧,១%** ដែលជាកំណើនយឺត បើធៀបនឹងឆ្នាំ ២០២៥ ដោយសារការបន្ថយថយនៃសន្ទុះកំណើនវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ជាបច្ច័យនៃការប៉ះទង្គិចដោយផ្ទាល់នៃគោលនយោបាយពន្ធគយបដិការមកលើការនាំចេញរបស់កម្ពុជា ខណៈដែលវិស័យផលិតកម្មម្ហូបអាហារ និងផលិតកម្មភេសជ្ជៈបន្តរក្សាបានចលនការ ហើយអនុវិស័យសំណង់បន្តងើបឡើង ប៉ុន្តែក្នុងល្បឿនទាប ។ ប៉ុន្តែ, អនុវិស័យគាំទ្រទាំងឡាយ នៅបន្តរក្សាបាននិន្នាការវិជ្ជមាន ដែលគាំពារដល់វិស័យឧស្សាហកម្ម ជារួមក្នុងរយៈពេលមធ្យម បើទោះបីក្នុងសភាពយឺតជាងការរំពឹងទុកយ៉ាងណាក្ដី ។ ក្នុងនោះ, វិស័យកាត់ដេរនៅបន្តមានចលនការកំណើន បើទោះបីក្នុងកម្រិតទាបជាងមុនវិបត្តិជំងឺកូវីដ-១៩ ដែលបន្តគាំទ្រដោយការបន្តនិន្នាការក្នុងទិសដៅវិជ្ជមាននៃទីផ្សារនាំចេញរបស់កម្ពុជា (ផ្នែកតម្រូវការ) ដូចជាសហភាពអឺរ៉ុប និងអាស៊ាន ជាដើម បើទោះបីការនាំចេញទៅទីផ្សារសហរដ្ឋអាម៉េរិកអាចនឹងមិនមានភាពល្អប្រសើរដូចការរំពឹងទុក គួបផ្សំនឹងការពង្រឹងការអនុវត្ត **«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧»** ដែលនឹងលើកកម្ពស់បរិយាកាសវិនិយោគ និងបង្កើនភាពប្រកួតប្រជែង (ផ្នែកផ្គត់ផ្គង់) ក៏ដូចជាចូលរួមបង្កើនតម្លៃបន្ថែមក្នុងអនុវិស័យនេះ ជារួម ។ ជាទិសដៅគោលនយោបាយនាពេលខាងមុខ, ការគិតគូររៀបចំ **«យុទ្ធសាស្ត្រអន្តរកាលដោយរលូន (Smooth transition strategy)»** ដើម្បីត្រៀមការចាកចេញពីក្រុមបណ្ដាប្រទេសអភិវឌ្ឍន៍តិចតួច (LDC) ជាពិសេសឆ្លើយតបទៅនឹងលក្ខខណ្ឌផ្លាស់ប្ដូរពីរដំណាក់កាល (Double transformation) ក៏នឹងក្លាយជាយុទ្ធសាស្ត្រគោលនយោបាយដ៏សំខាន់ សម្រាប់ការពង្រឹងច្រវាក់តម្លៃនៃអនុវិស័យកាត់ដេរ ផងដែរ បើទោះបីអនុវិស័យនេះ ត្រូវប្រឈមនឹងបញ្ហាទីផ្សារ ក៏ដូចជាការប្រកួតប្រជែងដ៏ខ្លាំងក្លាក្នុងតំបន់យ៉ាងណាក្ដី ។ អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ បើទោះបីមានកំណើនថមថយ

ក្នុងឆ្នាំ ២០២៦ ក៏និន្នាការកំណើននៃអនុវិស័យនេះនាពេលខាងមុខ បន្តងើបឡើងជាលំដាប់ ដែលនឹងបន្តជំរុញដោយការនាំចេញផលិតផលឧស្សាហកម្មយុទ្ធសាស្ត្រសំខាន់ៗ គួបផ្សំនឹងនិន្នាការនៃការផ្លាស់ប្តូរច្រវាក់ផលិតកម្ម ស្របពេលដែលឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុកនៅបន្តមានភាពប្រសើរ ។ ជាមួយគ្នានេះ, អនុវិស័យផលិតកម្មម្ហូបអាហារ និងភេសជ្ជៈ ក៏នៅបន្តនិន្នាការកើនឡើង ដែលបន្តជំរុញដោយការបន្តបង្កើនសកម្មភាពវិនិយោគ និងផលិតកម្ម ដើម្បីឆ្លើយតបទៅនឹងការបន្តកើនឡើងនៃតម្រូវការក្នុងស្រុក ។ គួរបញ្ជាក់ថា, ក្របខ័ណ្ឌលើកទឹកចិត្តតាមរយៈច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងការបន្តអនុវត្តនូវ **«យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ ២០២៣-២០២៨»** និងវិធានការគោលនយោបាយ ក៏ដូចជាយន្តការគាំទ្រសហគ្រាសធុនតូច និងមធ្យម ផ្សេងទៀត នឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការទាក់ទាញវិនិយោគពីបរទេស និងលើកកម្ពស់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីរបស់សហគ្រាសធុនតូច និងមធ្យម ដែលជាចលនករសំខាន់ក្នុងការជំរុញកំណើននៃអនុវិស័យនេះក្នុងរយៈពេលមធ្យម និងវែងខាងមុខ ។ ជាមួយគ្នានេះ, ការរៀបចំ និងដាក់ឱ្យអនុវត្តនូវ **«ក្របខ័ណ្ឌអភិវឌ្ឍន៍សួនកសិ-ឧស្សាហកម្មនៅកម្ពុជា»** និង **«កម្មវិធីពិសេសជំរុញការវិនិយោគ ក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ២០២៥-២០២៨»** ក៏នឹងក្លាយជាវិធានការគោលនយោបាយដែលមានការគិតគូរជាលក្ខណៈយុទ្ធសាស្ត្រ ក្នុងការបន្តកសាងមូលដ្ឋាន នៃវិស័យឧស្សាហកម្ម ពោលទាំងការជំរុញពិពិធកម្ម និងការបង្កើនច្រវាក់តម្លៃក្នុងអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ជារួម ។ ដោយឡែក, អនុ-វិស័យសំណង់បន្តងើបឡើង, ប៉ុន្តែក្នុងល្បឿនយឺត, ហើយនៅមានកំណើនទាបជាងនិន្នាការមុនវិបត្តិជំងឺកូវីដ-១៩ ដែលបន្តទ្រទ្រង់ដោយសកម្មភាពសង់លំនៅឋាន ឆ្លើយតបទៅនឹងតម្រូវការពិតក្នុងស្រុក (real domestic demand) គួបផ្សំនឹងការបន្តនិន្នាការកើនឡើងនៃសកម្មភាពសំណង់បម្រើឱ្យវិស័យឧស្សាហកម្ម តួយ៉ាងដូចជា រោងចក្រ និងឃ្លាំង ជាដើម ដែលនឹងក្លាយជានិន្នាការថ្មីជួយគាំពារកំណើននៃអនុវិស័យនេះក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ ខណៈការបន្តតាមដាន និងពង្រឹងការអនុវត្តវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាលនាពេលកន្លងមក ក៏នឹងជួយរក្សាលំនឹងអាជីវកម្មអចលនវត្ថុ និងក៏ដូចជាលើកកម្ពស់ចរន្តទិញ-លក់ និងសកម្មភាពសាងសង់ជារួម ផងដែរ ។



**វិស័យសេវាកម្ម** ត្រូវបានព្យាករថានឹងមានកំណើនជាមធ្យមប្រមាណ ៤,៤% សម្រាប់រយៈ-ពេលមធ្យម ២០២៦-២០២៨ **ក្នុងនោះឆ្នាំ ២០២៦ ព្យាករថាមានកំណើន ៣,៨%** ដូចគ្នាទៅនឹងឆ្នាំ ២០២៥ ដោយសារការបន្តងើបនៃវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ និងសេវាកម្មទេសចរណ៍គាំទ្រផ្សេងទៀត ខណៈដែលអនុវិស័យអចលនទ្រព្យនៅបន្តមានកំណើនទាប ។ អនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ រំពឹងថានឹងបន្តកើនឡើងគាំទ្រដោយការបន្តនិន្នាការកើនឡើងនៃលំហូរទេសចរអន្តរជាតិ ស្របពេលដែលទេសចរជាតិនៅបន្តមានសក្តានុពល ។ ការបន្តធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មគាំទ្រទេសចរណ៍, ការជំរុញភាពប្រកួតប្រជែងក្នុងវិស័យទេសចរណ៍ តាមរយៈការពង្រឹងច្រវាក់តម្លៃទេសចរណ៍, ការបន្តផ្សព្វផ្សាយ, ការលើកកម្ពស់កិត្តិនាមរបស់កម្ពុជាលើឆាកអន្តរជាតិ និង

ការរៀបចំព្រឹត្តិការណ៍សំខាន់ៗក្នុងប្រទេស គួបផ្សំនឹងការបន្តអនុវត្តផែនការមេអភិវឌ្ឍន៍ទេសចរណ៍តាមបណ្ដាខេត្តដែលជាប៉ូលទេសចរណ៍សំខាន់ៗ នឹងក្លាយជាចលករដ៏សំខាន់ក្នុងការបន្តជួយទ្រទ្រង់អនុវិស័យនេះ ។ ដោយឡែក, អនុវិស័យអចលនទ្រព្យ ដូចគ្នាទៅនឹងអនុវិស័យសំណង់ ក៏ងើបវិញយឺត ដែលបន្តគាំទ្រដោយចរន្តទិញ-លក់លំនៅឋានថ្លៃសមរម្យ សកម្មភាពទិញ-លក់/ជួលឃ្លាំង និងរោងចក្រ បម្រើឱ្យវិស័យឧស្សាហកម្ម និងអគារផ្សារលក់រាយ ។ អនុវិស័យលក់ដុំ-រាយ បើទោះបីមានកំណើនថមថយ ក្នុងឆ្នាំ ២០២៦ ដោយសារផលប៉ះពាល់ដោយប្រយោល នៃគោលនយោបាយពន្ធគយបដិការមកលើចំណូលរបស់ប្រជាជន និងសកម្មភាពចាយវាយ ដែលបណ្ដាលមកពីការថមថយសន្ទុះកំណើននៃវិស័យដែលជាប្រភពចំណូល (កាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ) ក៏និន្នាការទៅខាងមុខ នៅបន្តរក្សាបានកំណើនក្នុងទិសដៅវិជ្ជមាន ដែលគាំទ្រដោយសកម្មភាពចាយវាយ និងប្រើប្រាស់ដែលស្របទៅនឹងនិន្នាការសេដ្ឋកិច្ច ។ ទន្ទឹមនេះ, ការបន្តរីកចម្រើននៃអាជីវកម្មអនឡាញ និងប្រព័ន្ធទូទាត់ ក៏នឹងផ្ដល់ភាពងាយស្រួលបន្ថែមទៀតដល់ប្រតិបត្តិការសេដ្ឋកិច្ច ផងដែរ ។ ដូចគ្នាដែរ, អនុវិស័យដឹកជញ្ជូន និងស្តុក បើទោះបីមានកំណើនថមថយបន្តិចក្នុងឆ្នាំ ២០២៦ ក៏កំណើននាពេលមធ្យមខាងមុខ នៅបន្តរក្សាបាននិន្នាការកើនឡើង ដោយសារការបន្តងើបវិញនៃអនុវិស័យគាំទ្រ, តួយ៉ាង អនុវិស័យកាត់ដេរ និងទេសចរណ៍ គួបផ្សំនឹងការកើនឡើងនៃការដឹកជញ្ជូនបញ្ញើរហ័ស ។ ការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រទាំងផ្លូវអាកាស, ផ្លូវទឹក និងផ្លូវគោក ក៏នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើននៃអនុវិស័យនេះ ។ អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង ក៏បន្តងើបឡើងវិញសន្សឹមៗ ក្រោមការរំពឹងទុកការបន្តរើបឡើងនៃការផ្ដល់ឥណទានថ្មីៗ ដើម្បីបម្រើដល់សកម្មភាពវិនិយោគ គួបផ្សំនឹងការបន្តធ្វើទំនើបកម្ម និងសាមញ្ញកម្មនៃប្រព័ន្ធហិរញ្ញវត្ថុ ជាពិសេសផលិតផល និងសេវាហិរញ្ញវត្ថុ ស្របតាម **«គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨»** ដែលនឹងចូលរួមបង្កើនតម្លៃបន្ថែមទៀតដល់អនុវិស័យនេះ ។ អនុវិស័យបច្ចេកវិទ្យា និងទូរគមនាគមន៍ រំពឹងថានឹងបន្តមានកំណើនរឹងមាំ ដោយសារការបន្តកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិត និងការបន្តធ្វើឌីជីថលូបនីយកម្មនៃផលិតផល និងសេវាកម្ម ក្នុងគ្រប់វិស័យ និងប្រភេទអាជីវកម្ម ជាមួយនឹងការបន្តពង្រឹងការអនុវត្តក្របខ័ណ្ឌគោលនយោបាយដែលមានស្រាប់ ។

**វិស័យកសិកម្ម** ត្រូវបានព្យាករថានឹងមានកំណើនជាមធ្យមប្រមាណ ១,២% សម្រាប់រយៈពេលមធ្យម ២០២៦-២០២៨ **ក្នុងនោះឆ្នាំ ២០២៦ ព្យាករថាមានកំណើន ១,០%** ដោយសារការរំពឹងទុកកំណើនប្រសើរនៃអនុវិស័យដំណាំ និងការបន្តរក្សាស្ថិរភាពកំណើននៃអនុវិស័យនេសាទ ស្របពេលដែលអនុវិស័យចិញ្ចឹមសត្វ ក៏បន្តនិន្នាការងើបឡើងវិញសន្សឹមៗ ។ អនុវិស័យដំណាំ រំពឹងថានៅបន្តមានកំណើនល្អ ដោយសារការបន្តលើកកម្ពស់ការវិនិយោគទាំងក្នុងស្រុក និងពីបរទេសលើការកែច្នៃផលិតផលកសិកម្ម ជាពិសេសលើទំនិញសក្ដានុពល ដូចជា ស្វាយចន្ទី ដំឡូងមី និងកៅស៊ូ ជាដើម ដែលនឹងជំរុញការដាំដុះដំណាំសំខាន់ៗ ទាំងនេះ សម្រាប់បម្រើដល់ការកែច្នៃ ។ វិធានការគាំទ្រដែលមានស្រាប់ ដូចជា **«កម្មវិធីធានាស្ថិរភាពថ្លៃកសិផល»**, **«កម្មវិធីហិរញ្ញប្បទានក្រោមធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម»**, **«ការពង្រាយ**

មន្ត្រីកសិកម្មនៅតាមឃុំ-សង្កាត់នៃគ្រប់បណ្តាខេត្ត» និង «សហគមន៍កសិកម្មទំនើប» ក៏នឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការគាំទ្រដល់អនុវិស័យដំណាំផងដែរ ជាពិសេសការជំរុញសហថាមពលកើតចេញពីការប្រមូលផ្តុំ ដោយផ្អែកលើអភិក្រម **«កំណត់ទីផ្សាររួច បានទៅដាំដុះ»** ។ អនុវិស័យចិញ្ចឹមសត្វ រំពឹងថានឹងងើបវិញសន្សឹមៗ ដោយសារបច្ច័យនៃវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល លើការនាំចូលសាច់បង្កក និងបទប្បញ្ញត្តិពាក់ព័ន្ធ ដែលនឹងលើកទឹកចិត្តការចិញ្ចឹមក្នុងស្រុក គួបផ្សំនឹងការកើនឡើងនៃតម្រូវការក្នុងស្រុក ។ អនុវិស័យនេសាទ ក៏រំពឹងថានឹងបន្តមានកំណើនល្អ ក្រោមការរំពឹងទុកនូវកំណើនផលចាប់ទឹកសាប ដោយសារការបន្តអនុវត្តគោលនយោបាយបង្ក្រាបបទល្មើសនេសាទ ស្របពេលដែលការវិនិយោគក្នុងវារីវប្បកម្ម រំពឹងថានឹងងើបសន្សឹមៗ ដោយសារការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ តាមរយៈការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ ការគាំទ្រផ្នែកហិរញ្ញប្បទាន ការផ្សព្វផ្សាយបច្ចេកទេស និងការប្រើប្រាស់ពូជត្រីប្រកបដោយប្រសិទ្ធភាពខ្ពស់ និងគុណភាព ។

ក្នុងរយៈពេលមធ្យមខាងមុខ (២០២៦-២០២៨), **អត្រាអតិផរណា** ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ ២,៤% ស្របគ្នាទៅនឹងនិន្នាការរឹងមាំនៃសកម្មភាពសេដ្ឋកិច្ច ខណៈដែលថ្លៃទំនិញអន្តរជាតិនៅបន្តមានប្រក្រតីភាព ។ ជាមួយគ្នានេះ, **អត្រាប្តូរប្រាក់ផ្លូវការ (រៀល/ដុល្លារអាម៉េរិក)** រំពឹងថារក្សាបានក្នុងរង្វង់ជាមធ្យម ៤ ០៥០ រៀល/ដុល្លារអាម៉េរិក ក្រោមការរំពឹងទុកការវិលត្រលប់ទៅរកប្រក្រតីភាពវិញនៃរូបិយប័ណ្ណដុល្លារ គួបផ្សំនឹងជំហរគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ។

### តារាងទី ២៖ ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជាតាមវិស័យ ឆ្នាំ ២០១៩-២០២៨

| កំណើន (%) | 2019 | 2020 | 2021 | 2022 | 2023 | 2024ប. | 2025ប. | 2026ព្យ. | 2027ព្យ. | 2028ព្យ. |
|---|---|---|---|---|---|---|---|---|---|---|
| **ផ.ស.ស.** | **7.9** | **-3.6** | **3.1** | **5.1** | **5.0** | **6.0** | **5.2** | **5.0** | **5.5** | **5.8** |
| **វិស័យកសិកម្ម** | **-0.4** | **0.6** | **1.5** | **0.6** | **1.1** | **0.9** | **0.9** | **1.0** | **1.2** | **1.2** |
| ដំណាំ | 0.6 | 0.6 | 2.2 | 1.1 | 1.2 | 1.6 | 1.4 | 1.5 | 1.6 | 1.7 |
| នេសាទ | -1.5 | 0.7 | -1.0 | -1.3 | 1.3 | 0.9 | 0.2 | 0.4 | 0.6 | 0.7 |
| ចិញ្ចឹមសត្វ | -2.6 | 0.9 | 2.3 | 1.2 | 1.1 | -1.9 | 0.2 | 0.3 | 0.4 | 0.5 |
| **វិស័យឧស្សាហកម្ម** | **13.0** | **-2.2** | **8.4** | **8.2** | **5.4** | **9.2** | **7.8** | **7.1** | **7.5** | **7.6** |
| កាត់ដេរ | 12.9 | -7.7 | 15.9 | 11.3 | -4.5 | 16.9 | 10.4 | 8.4 | 7.3 | 6.5 |
| សំណង់ | 18.7 | -7.6 | -8.0 | 0.9 | 0.8 | 1.1 | 2.4 | 3.1 | 5.0 | 5.7 |
| ផលិតកម្មម្ហូបអាហារ | 7.8 | 3.4 | 4.2 | 7.6 | 9.3 | 6.1 | 5.4 | 5.0 | 6.1 | 6.8 |
| ផលិតកម្មភេសជ្ជៈ និងថ្នាំជក់ | 7.7 | 4.4 | 7.9 | 5.6 | 5.8 | 3.3 | 4.0 | 3.9 | 4.5 | 6.1 |
| កម្មន្តសាលមិនមែនកាត់ដេរ | 8.4 | 11.9 | 16.8 | 10.3 | 21.7 | 7.1 | 8.7 | 8.3 | 9.6 | 10.2 |
| **សេវាកម្ម** | **6.6** | **-6.7** | **-1.8** | **3.6** | **6.0** | **4.5** | **3.8** | **3.8** | **4.3** | **5.0** |
| បដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ | 5.5 | -34.2 | -39.5 | 22.0 | 49.1 | 12.9 | 8.6 | 6.0 | 5.8 | 4.1 |
| លក់ដុំ-រាយ | 5.7 | -6.3 | 2.5 | 4.5 | 2.1 | 3.9 | 3.4 | 2.9 | 4.0 | 5.2 |
| ដឹកជញ្ជូន និងស្តុក | 8.4 | -2.7 | 3.8 | 4.7 | 4.8 | 7.2 | 5.4 | 5.2 | 5.9 | 6.2 |
| បច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ | 9.8 | 11.5 | 12.0 | 9.0 | 8.6 | 7.0 | 7.1 | 7.1 | 7.4 | 7.6 |
| ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 7.9 | 4.3 | 3.2 | -1.0 | -0.1 | -0.6 | 0.9 | 2.0 | 2.6 | 3.1 |
| អចលនទ្រព្យ | 8.7 | -8.3 | -8.5 | 0.5 | -1.6 | 1.2 | 2.7 | 3.1 | 4.6 | 5.0 |
| **អតិផរណា** | 1.8 | 2.9 | 2.9 | 5.3 | **2.1** | **0.8** | **3.0** | **2.1** | **2.5** | **2.5** |
| **អត្រាប្តូរប្រាក់** | 4,052 | 4,077 | 4,068 | 4,087 | 4,110 | 4,070 | 4,054 | 4,052 | 4,050 | 4,050 |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (២០១៩-២០២៣) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២៤-២០២៨)*

**ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ)** ត្រូវបានព្យាករថានឹងស្ថិតក្នុងរង្វង់ប្រមាណ -២,៨% នៃ ផ.ស.ស. ដោយសារការរំពឹងទុកការបន្តរក្សាបាននូវសមតុល្យពាណិជ្ជកម្ម ស្របពេលដែលចំណូលពីវិស័យទេសចរណ៍ក៏បន្តនិន្នាការកើនឡើងជាលំដាប់ ។ ការនាំចេញ រំពឹងថានឹងបន្តនិន្នាការកើនឡើងក្នុងរយៈពេលមធ្យម បើទោះបីមានការថមថយបន្តិចក្នុងឆ្នាំ ២០២៦ ដែលបន្តជំរុញដោយការនាំចេញផលិតផលកម្មន្តសាល (កាត់ដេរ និងមិនមែនកាត់ដេរ) និងកសិផល ។ គួរបញ្ជាក់ថា, ក្នុងរយៈពេលមធ្យមខាងមុខ, ការនាំចេញកម្ពុជានឹងកាន់តែមានពិពិធភាព, ទាំងទីផ្សារ និងផលិតផល, តួយ៉ាងផលិតផលកម្មន្តសាលមិនមែនកាត់ដេរ, ជាពិសេសលើមុខទំនិញឧស្សាហកម្មយុទ្ធសាស្ត្រ, នឹងមានសក្តានុពល តួយ៉ាងដូចជា គ្រឿងបង្គុំអេឡិចត្រូនិក, សំបកកង់រថយន្ត, គ្រឿងសង្ហារិម និងផលិតផលកសិ-ឧស្សាហកម្មកែច្នៃ ជាដើម ។ ទន្ទឹមនេះ, ការនាំចូលក៏មាននិន្នាការដូចគ្នាទៅនឹងការនាំចេញ ពោលគឺមានកំណើនថមថយបន្តិច ក្នុងឆ្នាំ ២០២៦ ប៉ុន្តែមាននិន្នាការកើនឡើង ក្នុងរយៈពេលមធ្យមខាងមុខ ដែលគាំទ្រដោយការនាំចូលវត្ថុធាតុដើមសម្រាប់ផលិតកម្ម និងទំនិញប្រើប្រាស់ ដើម្បីបម្រើដល់សកម្មភាពផលិតកម្ម និងឆ្លើយតបទៅនឹងការបន្តកើនឡើងនៃតម្រូវការក្នុងស្រុក ។ រំហូរវិនិយោគផ្ទាល់ពីបរទេស ត្រូវបានព្យាករថានឹងបន្តកើនឡើងជាលំដាប់ ក្នុងរង្វង់ជាមធ្យម ប្រមាណ ៩,៣% នៃ ផ.ស.ស. ដោយសារកើនឡើងនូវទំនុកចិត្តវិនិយោគ ដែលជាបច្ច័យនៃការបន្តអនុវត្តច្បាប់ និងកម្មវិធីជំរុញវិនិយោគ គួបផ្សំនឹងកិច្ចខិតខំប្រឹងប្រែងក្នុងការបន្តកែលម្អបរិយាកាសវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម ។ ក្នុងរយៈពេលមធ្យមខាងមុខ, កម្ពុជារំពឹងថានឹងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបន្តទាក់ទាញវិនិយោគ ទៅក្នុងវិស័យឧស្សាហកម្មយុទ្ធសាស្ត្រ ដែលមានតម្លៃបន្ថែមខ្ពស់ក្នុងសេដ្ឋកិច្ច ស្របតាមគោលដៅរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុង **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាល ទី១»** ។ លើសពីនេះ, ទុនបម្រុងអន្តរជាតិ ត្រូវបានព្យាករថានឹងបន្តក្នុងកម្រិតអំណោយផល ដែលមានទំហំសមាមាត្រទៅនឹងការនាំចូល ប្រមាណ ៦,៩ ខែ ជាមធ្យម ។

### តារាងទី ៣៖ ទស្សនវិស័យនៃស្ថានភាពវិស័យខាងក្រៅកម្ពុជា ២០១៩-២០២៨

| សូចនាករ | 2019 | 2020 | 2021 | 2022 | 2023 | 2024ប. | 2025ប. | 2026ព្យ. | 2027ព្យ. | 2028ព្យ. |
|---|---|---|---|---|---|---|---|---|---|---|
| ការនាំចេញ (លានដុល្លារអាម៉េរិក) | 14,986 | 18,522 | 19,521 | 23,179 | 23,564 | 26,752 | 30,024 | 33,486 | 37,729 | 42,889 |
| ការនាំចូល (លានដុល្លារអាម៉េរិក) | 22,242 | 21,066 | 30,726 | 32,005 | 26,551 | 31,247 | 35,530 | 39,738 | 45,323 | 51,911 |
| សមតុល្យពាណិជ្ជកម្ម (លានដុល្លារអាម៉េរិក) | -7,255 | -2,544 | -11,257 | -8,826 | -2,986 | -4,496 | -5,506 | -6,253 | -7,594 | -9,021 |
| សមតុល្យគណនីចរន្ត (លានដុល្លារអាម៉េរិក) | -2,931 | -881 | -10,893 | -7,582 | 553 | 222 | -524 | -878 | -1,683 | -2,504 |
| រំហូរវិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាម៉េរិក) | 3,663 | 3,625 | 3,486 | 3,579 | 3,959 | 4,395 | 4,772 | 5,149 | 5,529 | 5,909 |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាម៉េរិក) | 18,763 | 21,334 | 20,265 | 17,805 | 19,998 | 22,511 | 24,450 | 26,336 | 28,299 | 30,125 |
| ការនាំចេញ (ភាគរយនៃ ផ.ស.ស.) | 40.8% | 53.0% | 52.7% | 57.7% | 54.6% | 56.8% | 59.0% | 61.2% | 63.9% | 67.1% |
| ការនាំចូល (ភាគរយនៃ ផ.ស.ស.) | 60.5% | 60.3% | 82.9% | 79.7% | -61.5% | -66.3% | -69.8% | -72.6% | -76.7% | -81.2% |
| សមតុល្យពាណិជ្ជកម្ម (ភាគរយនៃ ផ.ស.ស.) | -19.7% | -7.3% | -30.4% | -22.0% | -6.9% | -9.5% | -10.8% | -11.4% | -12.9% | -14.1% |
| សមតុល្យគណនីចរន្ត (ភាគរយនៃ ផ.ស.ស.) | -8.0% | -2.5% | -29.4% | -18.9% | 1.3% | 0.5% | -1.0% | -1.6% | -2.8% | -3.9% |
| រំហូរវិនិយោគផ្ទាល់ពីបរទេស (ភាគរយនៃ ផ.ស.ស.) | 10.0% | 10.4% | 9.4% | 8.9% | 9.2% | 9.3% | 9.4% | 9.4% | 9.4% | 9.2% |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | 8.8 | 13.4 | 7.4 | 6.1 | 10.1 | 9.6 | 7.6 | 7.3 | 6.9 | 6.4 |

*ប្រភព៖ ធនាគារជាតិនៃកម្ពុជា (២០១៩-២០២៤) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២៤-២០២៨)*

## គ. ហានិភ័យ និងទិសដៅគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ភាពមិនប្រាកដប្រជាពីកត្តាខាងក្រៅអាចនឹងមានកម្មវិបាកជាអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជា ដោយផ្ទាល់ និងប្រយោល ត្បិតកម្ពុជាមានសេដ្ឋកិច្ចតូច ហើយបើកចំហរ និងកាន់តែផ្សារភ្ជាប់ខ្លាំងជាមួយច្រវាក់ផលិតកម្មក្នុងតំបន់ និងសកល ។ ក្នុងរយៈពេលមធ្យមខាងមុខ, សេដ្ឋកិច្ចកម្ពុជា អាចនឹងជួបប្រទះនឹងហានិភ័យ និងភាព-មិនប្រាកដប្រជាចម្បងៗ ដែលបង្កឡើងដោយកត្តាខាងក្រៅ និងកត្តាខាងក្នុង រួមមានៈ

- **កត្តាខាងក្រៅ**
  - ១). ការបន្តកើនឡើងនូវចរន្តគាំពារនិយម (Protectionism) ជាពិសេសប្រទេសជាមហាអំណាចនានា ជាពិសេសគោលនយោបាយសេដ្ឋកិច្ច និងពាណិជ្ជកម្ម ឧទាហរណ៍ ការបន្តដំឡើងពន្ធគយ (Tariffs) ខ្ពស់ជាងការរំពឹងទុក និងភ្លាមៗ;
  - ២). ភាពតានតឹងនៃកត្តាភូមិសាស្ត្រសេដ្ឋកិច្ចដែលអាចបន្ទប់បង្អាក់ដល់ច្រវាក់ផ្គត់ផ្គង់សកល និងនាំ-ទៅដល់ការកើនថ្លៃទំនិញជាអន្តរជាតិ;
  - ៣). លទ្ធភាពនៃការថមថយនៃសន្ទុះកំណើនសេដ្ឋកិច្ចប្រទេសជាដៃគូពាណិជ្ជកម្ម និងប្រភពវិនិយោគ ជាពិសេស ចិន;
  - ៤). ការកើនឡើងសម្ពាធបំណុលសាធារណៈ;
  - ៥). ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច និងពាណិជ្ជកម្ម; និង
  - ៦). ផលប៉ះពាល់កាន់តែធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ។
- **កត្តាខាងក្នុង**
  - ១). ការចរចាពាណិជ្ជកម្មជាមួយសហរដ្ឋអាម៉េរិក អាចនឹងមិនទទួលបានលទ្ធផលល្អដូចការរំពឹងទុក ដែលនាំទៅរកការធ្លាក់ចុះយ៉ាងគំហុកនៃការនាំចេញ និងអាចឈានទៅដល់ការបិទរោងចក្រ;
  - ២). កំណើនយឺតជាងការរំពឹងទុកនៃវិស័យមួយចំនួន តួយ៉ាងដូចជា វិស័យសំណង់ និងអចលនទ្រព្យ ដែលធ្វើឱ្យកំណើន ជារួមនៅមានកម្រិតទាប;
  - ៣). បំណុលឯកជនស្ថិតក្នុងកម្រិតខ្ពស់ និងការបន្តកើនឡើងខ្ពស់នៃឥណទានមិនដំណើរការ (NPL) ដែលអាចប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ;
  - ៤). ការកៀរគរចំណូលបន្តមានកំណើនទាប និងការថមថយនៃហិរញ្ញប្បទានក្រៅប្រទេស ដែលកម្រិតដល់លទ្ធភាពក្នុងការធ្វើអន្តរាគមន៍ក្នុងពេលមានវិបត្តិ; និង
  - ៥). ហានិភ័យផ្នែកអាកាសធាតុអាចធ្វើឱ្យវិស័យកសិកម្មទាប និងការខូចខាតលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។

ទន្ទឹមនឹងការកើននៃហានិភ័យខាងក្រៅ និងខាងក្នុង, កម្ពុជា ក៏នៅតែបន្តប្រឈមបញ្ហាជារចនាសម្ព័ន្ធផ្ទៃក្នុងមួយចំនួន ដែលទាមទារការពង្រឹងការដ្ឋានកែទម្រង់ស៊ីជម្រៅ ដូចជា ៖ (១). ល្បឿនយឺតនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច; (២). ថ្លៃដើមធ្វើធុរកិច្ចនៅមានកម្រិតខ្ពស់; (៣). ភាពមានកម្រិតនៃកិច្ចសម្របសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច; (៤). បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញ មិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ; (៥). ភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម; និង (៦). ភាពមានកម្រិតនៃចំណេះ-ដឹង និងជំនាញក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល ។

ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយអាទិភាព, រាជរដ្ឋាភិបាលនៅតែបន្តប្រកាន់ខ្ជាប់នូវអភិក្រម ចំនួន ២ នោះគឺ ៖ (១). វិធានការគោលនយោបាយឆ្លើយតបទៅនឹងបញ្ហាបន្ទាន់ចំពោះមុខ និងក្នុងរយៈពេលខ្លីដោយផ្តោតលើការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការធានាលំនឹងជីវភាពរបស់ប្រជាជន; និង (២). ទិសដៅវិធានការគោលនយោបាយរយៈពេលមធ្យម និងវែងខាងមុខ ដែលនឹងផ្តោតលើការដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ ក្នុងការជំរុញការធ្វើពិពិធកម្ម ការលើកកម្ពស់ភាពប្រកួតប្រជែង និងការកសាងភាពធន់សម្រាប់សង្គម-សេដ្ឋកិច្ចកម្ពុជា ។ ក្នុងនោះ, កម្ពុជាត្រូវយកចិត្តទុកដាក់លើឧបករណ៍វិធានការគោលនយោបាយដូចខាងក្រោម ៖

១). **វិធានការគោលនយោបាយដោះស្រាយបញ្ហាចំពោះមុខ** ដោយផ្តោតលើបន្តតាមដានការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច និងរបបពាណិជ្ជកម្មសកល និងតំបន់ ព្រមទាំងក្តាប់ជីពចរសេដ្ឋកិច្ចក្នុងស្រុកឱ្យបានជាប្រចាំ, ខិតខំក្នុងការចរចាជាមួយភាគីសហរដ្ឋអាម៉េរិក ដើម្បីរកដំណោះស្រាយសមស្រប និងបន្តជំរុញការប្រើប្រាស់ឱ្យអស់សក្តានុពលនូវទីផ្សារមានស្រាប់ និងខិតខំបើកទីផ្សារថ្មី, ទាំងក្នុងក្របខ័ណ្ឌពហុភាគី និងទ្វេភាគី, តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការ, ទាំងក្នុងតំបន់ និងក្រៅតំបន់, ក្នុងគោលដៅធ្វើពិពិធកម្មនៃការនាំចេញ និងពង្រឹងមូលដ្ឋានសេដ្ឋកិច្ច ។

២). **វិធានការគោលនយោបាយហិរញ្ញវត្ថុសាធារណៈ** ដោយផ្តោតលើការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលមានភាពប្រយ័ត្នប្រយែង និងធានាឱ្យបាននូវភាពបត់បែនខ្ពស់ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃសភាពការណ៍ ហើយអាចធ្វើអន្តរាគមន៍បានភ្លាមៗ និងចំគោលដៅ ក្នុងករណីមានវិបត្តិ ។ កិច្ចអន្តរាគមន៍ តាមរយៈវិធានការចំណាយថវិកា និងចំណាយសារពើពន្ធ នឹងត្រូវផ្តោតលើវិស័យដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ និងក្រុមដែលងាយរងគ្រោះ ដើម្បីធានានូវការរក្សាលំនឹងសង្គម-សេដ្ឋកិច្ច ដែលមិនបង្កផលប៉ះពាល់ដល់ចីរភាពហិរញ្ញវត្ថុសាធារណៈ ខណៈបន្តពង្រឹងកិច្ចប្រឹងប្រែងកៀរគរចំណូល និងពង្រឹងការផ្សារភ្ជាប់រវាងគោលនយោបាយ និងថវិកា ជាមួយនឹងការបន្តលើកកម្ពស់ប្រសិទ្ធភាពចំណាយ, ម្ខាង, ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍, និងម្ខាងទៀត, ក៏ធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ ។

៣). **វិធានការគោលនយោបាយរូបិយវត្ថុ និងហិរញ្ញវត្ថុ** ដោយផ្តោតលើគោលនយោបាយរូបិយវត្ថុ ដើម្បីទ្រទ្រង់កំណើន (Accommodative monetary policy) តាមរយៈការជំរុញកំណើនឥណទានក្នុងវិស័យដែលមានផលិតភាព (Productive sectors) ស្របជាមួយនឹងការបន្តតាមដាន និងវាយតម្លៃជាប្រចាំលើស្ថានភាពឥណទាន និងការរៀបចំឥណទានឡើងវិញ និងការបន្តតាមដាន និងគ្រប់គ្រងជាប្រចាំនូវស្ថានភាពថ្លៃ, អត្រាប្តូរប្រាក់ និងសុខុមាលភាពវិស័យហិរញ្ញវត្ថុជារួម, ពោលគឺទាំងផ្នែកធនាគារ និងមិនមែនធនាគារ ក្នុងគោលដៅរក្សាស្ថិរភាពហិរញ្ញវត្ថុ និងបញ្ចៀសហានិភ័យជាប្រព័ន្ធ (Systemic risks) ។

៤). **វិធានការគោលនយោបាយដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ** តាមរយៈការពង្រឹងគ្រប់ការដ្ឋានកែទម្រង់គន្លឹះ ការបន្តពង្រឹងយន្តការអនុវត្ត និងតាមដាន និងវាយតម្លៃ **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១»** រួមជាមួយការដាក់ចេញ និងអនុវត្តនូវ **«កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និង ពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច នៅក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ ឆ្នាំ ២០២៥-២០២៨»** និងគោលនយោបាយតាមវិស័យអាទិភាព ។

## ៣. យុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈ

**«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៦-២០២៨»** ឬហៅខ្លីថា **«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨»** នេះ ដាក់ចេញនូវយុទ្ធសាស្ត្រហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល សម្រាប់រយៈពេលមធ្យម ដោយកំណត់នូវ **ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ** (Fiscal Policy Stance), **វិធានហិរញ្ញវត្ថុសាធារណៈ** (Fiscal Rules), និង **អាទិភាពគោលនយោបាយ** (Policy Priorities) ។

### ៣.១. ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ផ្អែកលើមូលដ្ឋានក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងការវិវត្តជាក់ស្តែងនៃស្ថានភាពហិរញ្ញវត្ថុសាធារណៈ ក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាកាន់តែខ្ពស់, **គោលនយោបាយហិរញ្ញវត្ថុសាធារណៈ** សម្រាប់រយៈពេលមធ្យមខាងមុខ នឹងត្រូវបានបន្តរៀបចំឡើងដោយប្រកាន់យកនូវ **«ជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន (Gradual Fiscal Consolidation Stance)»** ដើម្បីធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម តាមរយៈការបន្តរក្សានូវតុល្យភាពថវិកា រវាងធនធានថវិការបស់រដ្ឋ និងបន្ទុកថវិការបស់រដ្ឋ និងចាប់ផ្តើមកសាងទ្រនាប់ថវិកាជាតិឡើងវិញ នៅពេលកាលៈទេសៈអនុញ្ញាត ។

ឈរលើស្មារតីនេះ, រាជរដ្ឋាភិបាលក៏នឹងបន្តពង្រឹងការកៀរគរចំណូល តាមរយៈការជំរុញការអនុវត្ត **«យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា»** ដែលមានការកែទម្រង់ស៊ីជម្រៅទៅលើផ្នែករដ្ឋបាល និងទំនើបកាវូបនីយកម្មប្រព័ន្ធរដ្ឋបាលប្រមូលចំណូលសារពើពន្ធ និងចំណូលមិនមែនសារ-ពើពន្ធ ។ បន្ថែមលើនេះ, រាជរដ្ឋាភិបាល នឹងបន្តពង្រីកមូលដ្ឋានចំណូល ប្រកបដោយភាពហ្មត់ចត់ ព្រមទាំងបន្តអនុវត្តវិធានការលើកទឹកចិត្តនានាដែលមានស្រាប់ របស់រាជរដ្ឋាភិបាល ខណៈដែលសម្រាប់រយៈពេលមធ្យម រាជរដ្ឋាភិបាល នឹងប្រកាន់ខ្ជាប់នូវភាពប្រយ័ត្នប្រយែងខ្ពស់ ចំពោះករណីនៃការអនុគ្រោះពន្ធថ្មីណាមួយ ដោយខិតខំបញ្ចៀសនូវការធ្វើឱ្យចំណាយសារពើពន្ធកើនឡើងជាគំហុកបន្ថែមទៀត ។ ទន្ទឹមនឹងការត្បិតត្បៀតផ្នែកចំណាយសារពើពន្ធនេះ, ការផ្តល់នូវការលើកទឹកចិត្តពន្ធមានស្រាប់ដែលខានពុំបាន គឺត្រូវតែប្រើឱ្យចំគោលដៅ និងមានប្រសិទ្ធភាពខ្ពស់ ខណៈរាជរដ្ឋាភិបាលក៏នឹងរៀបចំការសិក្សា និងការវាយតម្លៃលើប្រសិទ្ធភាពនៃវិធានការលើកទឹកចិត្តទាំងឡាយ ហើយលើមូលដ្ឋាននៃការសិក្សា និងវាយតម្លៃនេះ, រៀបចំដាក់ចេញនូវវិធាន-ការធ្វើវិចារណកម្មតាមការចាំបាច់ ។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលនឹងបន្តផ្តោតជាសំខាន់លើការបន្តពង្រឹងប្រសិទ្ធភាពថវិកា, ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ, តាមរយៈការបន្តធ្វើអាទិភាវូបនីយកម្មចំណាយ ដោយក្នុងនោះ, ក្របខ័ណ្ឌចំណាយសា-ធារណៈ នឹងត្រូវរៀបចំឡើងដើម្បីតម្រង់ទិសធនធានទៅកាន់មុខសញ្ញាដែលជាអាទិភាពសំខាន់ៗចំពោះមុខ, ជាពិសេសដើម្បីធានាលំនឹងជីវភាពប្រជាជន, លើកកម្ពស់សមធម៌សង្គម, បន្តទ្រទ្រង់ដំណើរការនៃកិច្ចអភិវឌ្ឍសង្គម ព្រមទាំងធានានិរន្តរភាពប្រតិបត្តិការការងាររបស់រាជរដ្ឋាភិបាល ស្របតាមទិសដៅជាយុទ្ធសាស្ត្រដែលបានដាក់ចេញនៅក្នុង**«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** របស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ។

ឈរលើមូលដ្ឋាននៃការបន្តអនុវត្ត **«ជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន»** នេះ ឱន-ភាពថវិកា ក្នុងរយៈពេលមធ្យម នឹងមានការរួមតូច ធៀបនឹងឆ្នាំ ២០២៥ **ដោយរាជរដ្ឋាភិបាល នឹងខិតខំប្រឹង-ប្រែង មិនដកប្រាក់សន្សំមកប្រើប្រាស់ ដើម្បីកុំឱ្យស្រកស្រុតបន្ថែមទៀត, លើកលែងតែក្នុងករណីចាំបាច់បំផុតដែលសភាពការណ៍តម្រូវឱ្យប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាល, ហើយនឹងចាប់ផ្តើមកសាងទ្រនាប់ថវិកាឡើងវិញ នៅពេលកាលៈទេសៈអនុញ្ញាត** ។

## ៣.២. វិធានហិរញ្ញវត្ថុសាធារណៈ

**វិធានហិរញ្ញវត្ថុសាធារណៈ** គឺជាផ្នែកមួយដ៏សំខាន់ ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំក្របខ័ណ្ឌថវិកា, ពង្រឹងប្រសិទ្ធភាព និងវិន័យក្នុងការអនុវត្តថវិកា, និងជាពិសេស ធានានូវចីរភាពហិរញ្ញវត្ថុសាធារណៈសម្រាប់រយៈពេលមធ្យម ។ បន្តលើគោលការណ៍ដូចឆ្នាំមុនដែរ, **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨** ត្រូវគោរពឱ្យបាននូវលក្ខខណ្ឌនៃ **វិធានហិរញ្ញវត្ថុសាធារណៈ** ដែលត្រូវបានកំណត់លើសូចនាករហិរញ្ញវត្ថុសាធារណៈសំខាន់ៗ ។ ទោះជាយ៉ាងនេះក្តី, ការអនុវត្ត **វិធានហិរញ្ញវត្ថុសាធារណៈ** អាចមានភាពទន់ភ្លន់ជាងការកំណត់ ក្នុងករណីប្រធានសក្តិ ដូចជា គ្រោះធម្មជាតិ, ការរីករាលដាលនៃជំងឺឆ្លងជាសកល, គ្រោះអាសន្នដែលមានកម្រិតធ្ងន់ធ្ងរ និងពុំអាចប៉ាន់ស្មានទុកជាមុន ឬ ជាភាពចាំបាច់ជាបន្ទាន់សម្រាប់បម្រើដល់ប្រយោជន៍ជាតិជាដើម ដើម្បីផ្តល់លទ្ធភាពគ្រប់គ្រាន់ដល់រាជរដ្ឋាភិបាលក្នុងការធ្វើអន្តរាគមន៍ និងដោះស្រាយបញ្ហាប្រឈមបានទាន់ពេល ។

ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ, **វិធានហិរញ្ញវត្ថុសាធារណៈ** ដែលត្រូវបានដាក់ចេញក្នុង **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨** នេះ ត្រូវបានបែងចែកជា ២ រួមមាន៖ (១). **យុថ្កាហិរញ្ញវត្ថុសាធារណៈ** (Fiscal Anchor); និង (២). **វិធានប្រតិបត្តិ** (Operational Rules) ។

### ក. យុថ្កាហិរញ្ញវត្ថុសាធារណៈ

**យុថ្កាហិរញ្ញវត្ថុសាធារណៈ** គឺជាវិធានហិរញ្ញវត្ថុសាធារណៈ ដែលកំណត់ពិតានលើសូចនាករបំណុលសាធារណៈ ក្នុងកម្រិតណាមួយ ដែលធានាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម ដោយប្រើប្រាស់សូចនាករក្នុងការវិភាគចីរភាពបំណុលសាធារណៈ (Debt Sustainability Analysis – DSA) របស់កម្ពុជាទាំង ៥ ដូចត្រូវបានគូសរំលេចក្នុងកថាខណ្ឌខាងក្រោម ។ បន្ថែមលើនេះ, ផ្អែកតាមអនុសាសន៍របស់ IMF ដែលជាការគិតគូរប្រកបដោយភាពប្រុងប្រយ័ត្នបន្ថែម, **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨** នឹងកំណត់យកសូចនាករយុថ្កាហិរញ្ញវត្ថុសាធារណៈបន្ថែមមួយទៀត គឺ **អនុបាតបំណុលសាធារណៈជាតម្លៃចារឹក** ធៀបនឹង ផ.ស.ស. ដែលមានកម្រិតទាបជាងការកំណត់ក្នុងការវិភាគចីរភាពបំណុលសាធារណៈ ។

ដូចនេះ, សម្រាប់រយៈពេលមធ្យម ឆ្នាំ ២០២៦-២០២៨, **យុថ្កាហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា** ត្រូវបានកំណត់ ជា**សូចនាករគន្លឹះ**ចំនួន **៥ + ១** រួមមាន៖

(១). **អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស.** ត្រឹមកម្រិត **៥៥%;**

(២). **អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផ.ស.ស.** ត្រឹមកម្រិត **៤០%;**

(៣). **អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងការនាំចេញ** ត្រឹមកម្រិត **១៨០%;**

(៤). **អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងការនាំចេញ** ត្រឹមកម្រិត **១៥%;**

(៥). **អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងចំណូលថវិកាជាតិ** ត្រឹមកម្រិត **១៨%;** និង សូចនាករគន្លឹះបន្ថែមមួយទៀតគឺ ៖

(៦). **អនុបាតតម្លៃចារឹកនៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស.** ត្រឹមកម្រិត **៤០%** ។

### ខ. វិធានប្រតិបត្តិ

បន្ថែមលើនេះ, **វិធានប្រតិបត្តិ** ក៏ត្រូវបានដាក់ចេញ ដោយប្រើប្រាស់វិធានតុល្យភាពថវិកា (Budget Balance Rule) ដែលជាវិធានសមស្របសម្រាប់បរិបទកម្ពុជា ក្នុងការរៀបចំក្របខ័ណ្ឌថវិកាប្រចាំឆ្នាំ ហើយមានភាពផ្សារភ្ជាប់ខ្ពស់ទៅនឹងយុទ្ធាហិរញ្ញវត្ថុសាធារណៈដែលបានដាក់ចេញខាងលើ ។ រាជរដ្ឋាភិបាលកំណត់យកពិតាន **ឱនភាពថវិកាសរុប មិនត្រូវលើសពីកម្រិត -៥,០% នៃ ផ.ស.ស.** ដែលត្រូវជាប្រមាណ **-៣,៥% នៃ ផ.ស.ស. បើគិតក្នុងទម្រង់ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS)** ។ ការកំណត់កម្រិតឱនភាពថវិកានេះ ធ្វើឡើងក្នុងន័យបន្តរក្សាចីរភាពបំណុលសាធារណៈ និងធានានូវចីរភាពហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ស្របតាមដំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន ខណៈនៅតែផ្តល់លទ្ធភាពសម្រាប់ការអនុវត្តគោលនយោបាយអាទិភាព សំដៅរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគាំទ្រការស្តារ និងការជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ ។

**តារាងទី ៤៖ វិធានហិរញ្ញវត្ថុសាធារណៈ**

| វិធានហិរញ្ញវត្ថុសាធារណៈ | |
|---|---|
| **យុទ្ធាហិរញ្ញវត្ថុសាធារណៈ** | (១). អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. **ត្រឹមកម្រិត ៥៥%;**<br>(២). អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផ.ស.ស. **ត្រឹមកម្រិត ៤០%;**<br>(៣). អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងការនាំចេញ **ត្រឹមកម្រិត ១៨០%;**<br>(៤). អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងការនាំចេញ **ត្រឹមកម្រិត ១៥%;**<br>(៥). អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹងចំណូលថវិកាជាតិ **ត្រឹមកម្រិត ១៨%;** និង<br>(៦). អនុបាតតម្លៃចារឹកនៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. **ត្រឹមកម្រិត ៤០%** ។ |
| **វិធានប្រតិបត្តិ** | ឱនភាពថវិកាសរុប មិនត្រូវលើសពី**កម្រិត -៥,០% នៃ ផ.ស.ស.** ឬ ត្រូវជា **-៣,៥% នៃ ផ.ស.ស. ក្នុងទម្រង់ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល** (GFS) ។ |

## ៣.៣. អាទិភាពគោលនយោបាយ

ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយ, ការជំរុញអនុវត្តឱ្យសម្រេចបានជោគជ័យនូវ **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១»** នៅតែជាអាទិភាពរបស់រាជរដ្ឋាភិបាល ខណៈត្រៀមដាក់ចេញ និងអនុវត្តនូវ **«កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និង ពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច នៅក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ ឆ្នាំ ២០២៥-២០២៨»** សំដៅរួមចំណែកដោះស្រាយបញ្ហាជារចនា-

សម្ព័ន្ធសំខាន់ៗ ។ ក្នុងន័យនេះ, **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨** នឹងចូលរួមគាំទ្រអាទិភាពគោលនយោបាយសំខាន់ៗ តាមរយៈការដាក់ចេញនូវវិធានការគោលនយោបាយ ដូចខាងក្រោម៖

- បន្តការពារសន្តិភាព, ស្ថិរភាពនយោបាយ, សមិទ្ធផលសង្គម និងជំរុញការដោះស្រាយបញ្ហាគ្រោះអាសន្ននានា ក្នុងសង្គម ដើម្បីរក្សាសុវត្ថិភាព និងសុខដុមរមនាប្រជាជន;
- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រក្សាលំនឹងជីវភាព, គាំពារ និងបង្កើតការងារជូនប្រជាជន, បង្កើនប្រសិទ្ធភាព និងវិសាលភាពនៃការគាំពារសង្គម និងការផ្តល់សេវាសង្គមចាំបាច់នានា;
- បន្តជំរុញពិពិធកម្មសេដ្ឋកិច្ចលើវិស័យគន្លឹះដែលមានស្រាប់ និងអភិវឌ្ឍប្រភពថ្មីនៃកំណើនតាមរយៈការគាំទ្រជាគោលនយោបាយដល់បរិយាកាសប្រកួតប្រជែង, ការជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់ប្រភេទ, ទាំងរឹង និងទន់, និងការអនុវត្តយន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ ដែលបង្កើនតម្លៃបន្ថែមខ្ពស់;
- ជំរុញការអភិវឌ្ឍមូលធនមនុស្ស ដោយការលើកកម្ពស់គុណភាពអប់រំ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាប័ន្ន និងភាពធន់, ការបណ្តុះបណ្តាល និងអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត ដើម្បីគាំទ្រផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់;
- លើកកម្ពស់ភាពជាពលរដ្ឋក្នុងសង្គម, លើកកម្ពស់វប្បធម៌ និងសុខុមាលភាពប្រជាជន សម្រាប់ការត្រៀមខ្លួនជាប្រជាជននៃប្រទេសចំណូលមធ្យមកម្រិតខ្ពស់;
- បន្តជំរុញការលើកកម្ពស់សុខុមាលភាពសង្គម, កសាងភាពធន់នៃសង្គមកម្ពុជា និងបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក៏ដូចជាផ្តល់សេវាសង្គម ជាពិសេសយកចិត្តទុកដាក់លើវិស័យដែលរងកម្មវិបាកពីការប្រែប្រួលរបបពាណិជ្ជកម្ម;
- បន្តជំរុញការធ្វើបរិវត្តកម្មឌីជីថល ដោយវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងជំរុញការអភិវឌ្ឍបៃតង ដើម្បីកសាងរដ្ឋាភិបាល និងពលរដ្ឋឌីជីថលប្រកបដោយចីរភាព;
- បន្តពង្រឹងអភិបាលកិច្ច និងស្ថាប័ន តាមរយៈការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌; និង
- បន្តលើកស្ទួយវិស័យឯកជន ក្នុងនោះរួមទាំងការគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការពង្រឹងការអនុវត្តច្បាប់វិនិយោគថ្មី, ការដាក់ចេញវិធានការលើកទឹក-ចិត្តជាក់លាក់ និងការកែលម្អបរិយាកាសធុរកិច្ចជាមួយនឹងភាពប្រកួតប្រជែង និងសមភាព ។

# ៤. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

## ៤.១. ការអនុវត្តថវិកា ឆ្នាំ ២០២៤ និង ២០២៥

### ក. ការអនុវត្តថវិកា ឆ្នាំ ២០២៤

សម្រាប់ឆ្នាំ ២០២៤, **លទ្ធផលនៃការប្រមូលចំណូលសរុបថវិការដ្ឋ** (តួលេខបណ្តោះអាសន្ន) សម្រេចបានប្រមាណ ១៥,១៩% នៃ ផ.ស.ស. ដែលមានការថមថយប្រមាណ -១៧,១% ធៀបនឹងលទ្ធផលឆ្នាំ ២០២៣ ។ ការធ្លាក់ចុះនេះ គឺជាចម្បងដោយសារការផ្លាស់ប្តូរការកត់ត្រាចំណូលផ្សេងៗ អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣ ។ ដោយឡែក, **ចំណូលចរន្ត** សម្រេចបានកំណើនវិជ្ជមាន ប៉ុន្តែក្នុងល្បឿនយឺត, ពោលគឺក្នុងអត្រា ៣,៥% ធៀបនឹងលទ្ធផលឆ្នាំ ២០២៣, សមមូលនឹង ១៤,៥៨% នៃ ផ.ស.ស. និង ៨៩,៤%

នៃច្បាប់ថវិកា ។ ការសម្រេចបានកំណើនចំណូលចរន្ត ទាបជាងកំណើនសេដ្ឋកិច្ចនេះ គឺដោយសារ វិស័យដែលជាចន្ទល់កំណើនសេដ្ឋកិច្ចជាតិឆ្នាំ ២០២៤ ត្រូវទទួលបានការអនុគ្រោះ និងលើកលែងពន្ធច្រើន រួមមាន វិស័យកសិកម្ម, វិស័យទេសចរណ៍, វិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈវិស័យដែលជាប្រភពចំណូលធំសម្រាប់ចំណូលសារពើពន្ធក្នុងស្រុក សម្រេចបានកំណើនទាប, ពិសេស វិស័យហិរញ្ញវត្ថុ, វិស័យអចលនទ្រព្យ និងវិស័យសំណង់ ។ ស្របពេលជាមួយគ្នានេះ, ចំណាយសារពើពន្ធ ក៏មាននិន្នាការកើនឡើង ស្របតាមការបន្តអនុវត្តនូវវិធានការលើកទឹកចិត្តដែលមានស្រាប់នានា និងការពង្រីកនូវវិសាលភាពក្នុងការលើកលែង ឬ បន្ធូរបន្ថយការបង់ពន្ធ ដើម្បីគោលដៅសម្រាលបន្ទុកជីវភាពរស់នៅរបស់ប្រជាជន ក៏ដូចជាដើម្បីសម្រួលបរិយាកាសធុរកិច្ច ក្នុងគ្រាសេដ្ឋកិច្ចជាតិកំពុងត្រូវបន្តជម្នះស្លាកស្នាមនៃពហុវិបត្តិ ដែលបានកើតមានជាបន្តបន្ទាប់ ។ ទោះជាយ៉ាងនេះក្តី, រដ្ឋបាលប្រមូលចំណូល បានបន្តពង្រឹងការអនុវត្តវិធានការមុតស្រួចនានា ដើម្បីកៀរគរចំណូលឱ្យអស់សក្តានុពល ដែលការណ៍នេះបានរួមចំណែកយ៉ាងសំខាន់ ដល់ការសម្រេចបានកំណើនចំណូលក្នុងអត្រាវិជ្ជមាននេះ ។

ក្នុងស្ថានភាពដែលការប្រមូលចំណូលមិនអាចសម្រេចបានតាមការរំពឹងទុក, រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការធ្វើវិចារណកម្មចំណាយថវិកា ដោយ, ម្ខាង, ខិតខំរក្សាចំណាយឱ្យស្ថិតនៅក្នុងកម្រិតសមរម្យ ដើម្បីទ្រទ្រង់ប្រតិបត្តិការចាំបាច់គ្រប់ផ្នែករបស់រាជរដ្ឋាភិបាល; និងម្ខាងទៀត, ផ្តោតអាទិភាពលើការពង្រឹងប្រសិទ្ធភាពចំណាយ, ទាំងក្នុងទិដ្ឋភាពនៃការរៀបចំថវិកា និងទាំងក្នុងទិដ្ឋភាពនៃប្រតិបត្តិការថវិកា, សំដៅធានាជោគជ័យក្នុងការអនុវត្តវិធានការគោលនយោបាយអាទិភាពនានា ដើម្បីស្តារ និងជំរុញកំណើន ព្រមទាំងធានាការពារលំនឹងជីវភាពប្រជាជន ។ លើមូលដ្ឋាននេះ, របៀបវារៈគោលនយោបាយសំខាន់ៗ ដែលត្រូវបានដាក់ចេញសម្រាប់ឆ្នាំ ២០២៤ ដូចជា ការជ្រើសរើសក្របខ័ណ្ឌថ្មី, ការដំឡើងប្រាក់បៀវត្ស និងប្រាក់សោធនជូនមន្ត្រីរាជការស៊ីវិល, កងកម្លាំងប្រដាប់អាវុធ និងនិវត្តជន, និងការអនុវត្តការងារអាទិភាព និងការងារកែទម្រង់សំខាន់ៗរបស់ក្រសួង-ស្ថាប័ន ព្រមទាំង **«កម្មវិធីគោលនយោបាយអាទិភាព ទាំង ៦»** និង **«វិធានការគន្លឹះ ទាំង ៥»** របស់រាជរដ្ឋាភិបាល ត្រូវបានដាក់ចេញ និងជំរុញអនុវត្តដោយជោគជ័យ តាមការគ្រោងទុក ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលបានអនុវត្តនូវកម្មវិធីគោលនយោបាយផ្សេងៗ ជាអាទិ៍ គោលនយោបាយគាំពារសង្គម ដែលគ្របដណ្តប់ប្រជាជនជាង ៧,៨ លាននាក់ តម្រង់ទៅរកការអភិវឌ្ឍមូលធនមនុស្សជារួម តាមរយៈកម្មវិធីលើកកម្ពស់ផលិតភាព ដូចជាការអភិវឌ្ឍជំនាញ និងកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ (Graduation-based social protection program), ការផ្តល់ការថែទាំសុខភាពឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា, ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជន មកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស, និងការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស ជាដើម ។ ជាលទ្ធផល, **ចំណាយក្នុងឆ្នាំ ២០២៤** ត្រូវបានប៉ាន់ស្មានថាអនុវត្ត ក្នុងទំហំប្រមាណ ១៨,០៩% នៃ ផ.ស.ស. (តួលេខបណ្តោះអាសន្ន) ទាបជាងការគ្រោងក្នុងច្បាប់ ពោលគឺស្មើនឹងប្រមាណ ៩៣,៥% នៃច្បាប់ថវិកា ហើយ **ឱនភាពថវិកាឆ្នាំ ២០២៤** ត្រូវបានប៉ាន់ស្មានថាស្ថិតក្នុងរង្វង់ -២,៨៩% នៃ ផ.ស.ស. ខ្ពស់ជាងច្បាប់ថវិកាប្រមាណ ០,៤៩ ពិន្ទុភាគរយ ។ ការវាយតម្លៃការអនុវត្តថវិកាឆ្នាំ ២០២៤ និងតួលេខចុងក្រោយ នឹងឆ្លុះបញ្ចាំងក្នុង**សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤** ក្នុងពេលខាងមុខ ។

## ខ. ការប៉ាន់ស្មានការអនុវត្តថវិកាឆ្នាំ ២០២៥

ក្នុងឆ្នាំ ២០២៥ នេះ, **ចំណូលសរុប** ត្រូវបានប៉ាន់ស្មានថានឹងសម្រេចបានកំណើន ក្នុងអត្រា ៥,៥% ធៀបនឹងលទ្ធផលអនុវត្ត (បណ្តោះអាសន្ន) ឆ្នាំ ២០២៤ សមមូលប្រមាណ ១៤,៩១% នៃ ផ.ស.ស. ។ ក្នុងនោះ **ចំណូលចរន្តឆ្នាំ ២០២៥** ត្រូវបានប៉ាន់ស្មានថានឹងសម្រេចបានកំណើនត្រឹមក្នុងអត្រា ៥,៦% ធៀបនឹងលទ្ធផលអនុវត្ត (បណ្តោះអាសន្ន) ឆ្នាំ ២០២៤, សមមូលប្រមាណ ១៤,៣២% នៃ ផ.ស.ស. និង ៩៧,៣% នៃច្បាប់ថវិកា ដោយសារការរំពឹងទុកការបន្តថមថយនៃចំណូលពន្ធសំខាន់ៗ ដូចជា ចំណូលពន្ធលើប្រាក់ចំណូល, ចំណូលពន្ធប្រយោល និងចំណូលពន្ធថ្នាក់ក្រោមជាតិ ខណៈចំណូលពីវិស័យមួយចំនួនទៀត រួមមាន វិស័យសាងសង់ និងអចលនទ្រព្យ ត្រូវបានរំពឹងទុកថានឹងបន្តមានកំណើនយឺត គួបផ្សំជាមួយនឹងការបន្តអនុវត្តគោលនយោបាយលើកទឹកចិត្តពន្ធនានា ។ រាជរដ្ឋាភិបាល ក៏នឹងបន្តកៀរគរប្រភពហិរញ្ញប្បទានទីផ្សារក្នុងស្រុកបន្ថែម តាមរយៈការបន្តបោះផ្សាយមូលបត្ររដ្ឋក្នុងឆ្នាំ ២០២៥ មានទំហំប្រមាណ ៥០០ ប៊ីលានរៀល សំដៅជួយទ្រទ្រង់ដល់ធនធានថវិកា ក្នុងបរិការណ៍ដែលកំណើនចំណូលមាននិន្នាការយឺត ។

**ចំណាយសរុបឆ្នាំ ២០២៥** ត្រូវបានកំណត់ក្នុងច្បាប់ថវិកា ក្នុងទំហំប្រមាណ ១៨,៣៩% នៃ ផ.ស.ស. ដែលក្នុងនោះ ចំណាយចរន្ត មានទំហំ ១២,៦២% នៃ ផ.ស.ស. និង ចំណាយមូលធន មានទំហំ ៥,៧៦% នៃ ផ.ស.ស. ។ សម្រាប់ក្របខ័ណ្ឌចំណាយនេះ, រាជរដ្ឋាភិបាល បានកំណត់លើចំណាយអាទិភាពមួយចំនួន ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយធំៗ ក្នុងគោលដៅដំឡើងបៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក៏ដូចជាបន្តពង្រឹងគុណភាព, ប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រី, និងបំពាក់បំប៉នគុណវុឌ្ឍិវិជ្ជាជីវៈជំនាញ ស្របតាមតម្រូវការចាំបាច់ជាមូលដ្ឋានរបស់ក្រសួង-ស្ថាប័ននានា ព្រមទាំងបន្តពង្រឹង និងពង្រីកចំណាយវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងមិនមែនរូបវន្តឱ្យមានគុណភាព, រឹងមាំ, ជឿនលឿន និងសម្បូរបែប ។ ជាលទ្ធផល, **ឱនភាពថវិកា ឆ្នាំ ២០២៥** ត្រូវបានប៉ាន់ស្មាននឹងស្ថិតក្នុងរង្វង់ប្រមាណ -៣,៤៨% នៃ ផ.ស.ស. ។

### តារាងទី ៥៖ លទ្ធផលការអនុវត្តថវិកាឆ្នាំ ២០២៣-២០២៥

| | កំណើនប្រចាំឆ្នាំ | | | ភាគរយនៃ ផ.ស.ស. | | |
|---|---|---|---|---|---|---|
| | 2023 | 2024ប. | 2025កែ. | 2023 | 2024ប. | 2025កែ. |
| **ចំណូលសរុប** | **0.8%** | **-17.1%** | **5.5%** | **19.84%** | **15.19%** | **14.91%** |
| **ចំណូលចរន្ត** | **-1.5%** | **3.5%** | **5.6%** | **15.24%** | **14.58%** | **14.32%** |
| **ចំណូលសារពើពន្ធ** | **-3.1%** | **2.7%** | **4.6%** | **14.99%** | **13.43%** | **12.75%** |
| អគ្គនាយកដ្ឋានពន្ធដារ | 7.1% | -4.0% | 3.3% | 8.23% | 7.31% | 7.02% |
| *ក្នុងនោះ៖ ថ្នាក់ក្រោមជាតិ* | *-3.5%* | *0.4%* | *-1.4%* | *1.09%* | *1.01%* | *0.93%* |
| អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | -15.9% | 13.3% | 6.3% | 5.20% | 5.45% | 5.38% |
| **ចំណូលមិនមែនសារពើពន្ធ** | **12.2%** | **9.3%** | **12.6%** | **1.81%** | **1.83%** | **1.92%** |
| *ក្នុងនោះ៖ ថ្នាក់ក្រោមជាតិ* | *-22.8%* | *-30.0%* | *-5.7%* | *0.26%* | *0.17%* | *0.15%* |
| **ចំណូលផ្សេងៗ** | **9.5%** | **-85.7%** | **3.5%** | **4.59%** | **0.61%** | **0.59%** |
| **ចំណាយសរុប** | **15.5%** | **-7.2%** | **9.4%** | **21.09%** | **18.09%** | **18.39%** |
| **ចំណាយចរន្ត** | 15.4% | 4.4% | 8.3% | 13.00% | 12.54% | 12.62% |
| **ចំណាយមូលធន** | 15.8% | -25.9% | 11.9% | 8.09% | 5.54% | 5.76% |
| **សមតុល្យថវិកា** | | | | -5.61% | -2.89% | -3.48% |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ទោះបីជាស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជាក្តី, ការអនុវត្តចំណូល និងចំណាយឆ្នាំ ២០២៥ នេះ នឹងត្រូវបានគ្រប់គ្រងឱ្យស្ថិតនៅក្នុងរង្វង់ **ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៥** ដោយមិនមានការប្រែប្រួលជាដុំកំភួននោះទេ ដែលក្នុងនោះ ផ្នែកចំណាយ គោលនយោបាយអាទិភាព និងវិធានការគន្លឹះ របស់រាជរដ្ឋាភិបាល អាចនឹងដាក់ឱ្យអនុវត្តបានតាមការគ្រោងទុក ។

### គ. លទ្ធផលអនុវត្តថវិកាធៀបទៅនឹងវិធានហិរញ្ញវត្ថុសាធារណៈ

ជារួម, ការអនុវត្តថវិកាក្នុងឆ្នាំ ២០២៤ និង ២០២៥ ត្រូវបានប្រកាន់ខ្ជាប់នូវវិធានហិរញ្ញវត្ថុសាធារណៈដែលត្រូវបានដាក់ចេញ ក្នុងនោះ រាល់សូចនាករទាំងអស់ ត្រូវបានស្ថិតនៅក្រោមពិតានដែលបានកំណត់ ។ ជាក់ស្តែង, **បំណុលសាធារណៈសរុបរបស់កម្ពុជា សម្រាប់ឆ្នាំ ២០២៥ ជាតម្លៃបច្ចុប្បន្ន** ត្រូវបានប៉ាន់ស្មានថានឹងស្ថិតក្នុងកម្រិតប្រមាណ ១៨,៧៩% នៃ ផ.ស.ស. និង**ជាតម្លៃចារឹក** ក្នុងកម្រិតប្រមាណ ២៦,៥៩% នៃ ផ.ស.ស. ខណៈសូចនាករចំនួន ៤ ផ្សេងទៀតរបស់យុថ្កាហិរញ្ញវត្ថុសាធារណៈ ក៏ស្ថិតក្នុងកម្រិតទាបជាងពិតានដែលបានកំណត់ ។ បន្ថែមលើនេះ, ឱនភាពថវិកា សម្រាប់ឆ្នាំ ២០២៥ ក៏ត្រូវបានប៉ាន់ស្មានថានឹងស្ថិតក្រោមកម្រិតនៃការកំណត់ដោយវិធានប្រតិបត្តិ ផងដែរ ។

**តារាងទី ៦៖ សូចនាករវិធានហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៣-២០២៥**

| សូចនាករ | ពិតាន | 2023 | 2024ប. | 2025ប៉ាន់. |
|---|---|---|---|---|
| **I. យុថ្កាហិរញ្ញវត្ថុសាធារណៈ** | | | | |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. | **55%** | 18.81% | 18.29% | 18.79% |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផ.ស.ស. | **40%** | 18.69% | 18.05% | 18.40% |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ | **180%** | 29.00% | 26.90% | 26.41% |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ | **15%** | 1.78% | 1.72% | 1.87% |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ចំណូលថវិកាជាតិ | **18%** | 7.50% | 7.60% | 8.75% |
| អនុបាតតម្លៃចារឹកនៃបំណុលសាធារណៈ សរុប ធៀបនឹង ផ.ស.ស. | **40%** | 25.79% | 25.60% | 26.59% |
| **II. វិធានប្រតិបត្តិ** | | | | |
| ឱនភាពថវិកាសរុប | **-5%** | -5.61% | -2.89% | -3.48% |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ៤.២. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៦-២០២៨

**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨** ត្រូវបានរៀបចំឡើង ស្របតាមជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ និងឆ្លើយតបទៅនឹងបរិការណ៍ក្នុងរយៈពេលមធ្យម ចំនួន ៣ ធំៗ រួមមាន៖ (១). ការប្រមូលចំណូលក្នុងរយៈពេលមធ្យម នឹងបន្តប្រឈមនឹងភាពមិនប្រាកដប្រជា ស្របពេលដែលកត្តាខាងក្រៅ

អាចប៉ះពាល់ជាអវិជ្ជមានលើវិស័យជាប្រភពចំណូលដែលកំពុងងើបឡើងវិញសន្សឹមៗ; (២). ការបន្តកើនឡើងឥតឈប់ឈរនូវតម្រូវការចំណាយចរន្ត និងការវិនិយោគ រួមមាន តម្រូវការសម្រាប់បន្តការងារកែទម្រង់ និងពង្រឹងសមត្ថភាពស្ថាប័ន, ការបន្តអនុវត្តគោលនយោបាយគាំពារសង្គម និងការអភិវឌ្ឍមូលធនមនុស្ស ព្រមទាំងការអនុវត្តគោលនយោបាយអាទិភាព និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ និងមានភាពធន់ សម្រាប់កិច្ចអភិវឌ្ឍ; និង (៣). ស្ថានភាពលម្ហថវិកាបច្ចុប្បន្នកំពុងមានការរួមតូច ដោយការអនុវត្តគោលនយោបាយវិត្តារកម្មថវិកា ក្នុងរយៈពេល ៤ ឆ្នាំ ពោលគឺ ពីឆ្នាំ ២០២០ ដល់ ២០២៣ និងលទ្ធភាពក្នុងការ-ទទួលបានឥណទានក្នុងកម្រិតសម្បទានខ្ពស់ កាន់តែមានកម្រិត ។

## ក. ក្របខ័ណ្ឌចំណូល

**ចំណូលសរុប ក្នុងឆ្នាំ ២០២៦ ត្រូវបានព្យាករថានឹងសម្រេចបានក្នុងទំហំប្រមាណ ១៤,៦៣% នៃ ផ.ស.ស. ដែលសមមូលនឹងកំណើនប្រមាណ ៥,៥% ធៀបនឹងលទ្ធផលប៉ាន់ស្មានក្នុងឆ្នាំ ២០២៥ ។ សម្រាប់រយៈពេលមធ្យមឆ្នាំ ២០២៧-២០២៨ ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យម ក្នុងអត្រា ៧,៣% និងស្ថិតក្នុងទំហំ ១៤,៨៣% នៃ ផ.ស.ស. នៅឆ្នាំ ២០២៨ ។** ជាមួយគ្នានេះ, ចាប់ពីឆ្នាំ ២០២៦ ទៅមុខ, ការកត់ត្រាចំណូល មានការផ្លាស់ប្តូរ ដោយបង្ហាញត្រឹមចំណូលសុទ្ធ (Net Amount) ដែលជាផលសងរវាង ចំណូលដុល (Gross Amount) និងការបង្វិលសងអាករលើតម្លៃបន្ថែម (VAT Refund) ដែលក្នុងនោះ សម្រាប់ឆ្នាំ ២០២៦ ដើម្បីគោលដៅនៃការបង្វិលសងអាករលើតម្លៃបន្ថែម ចំណូលចំនួន ៥% នៃចំណូលអាករលើតម្លៃបន្ថែមសរុប (Total VAT), សមមូលនឹង ០,២០% នៃ ផ.ស.ស., នឹងត្រូវបានកាត់ទុក ហើយសម្រាប់ឆ្នាំ ២០២៧-២០២៨ ចំណូលនេះនឹងត្រូវបានកាត់ទុក ១០% ដែលជាមធ្យមសមមូលនឹង ០,៤២% នៃ ផ.ស.ស. ។

**ចំណូលចរន្ត ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ១៤,១៣% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៦ សមមូលនឹងអត្រាកំណើនក្នុងរង្វង់ ៥,៩% ធៀបនឹងលទ្ធផលប៉ាន់ស្មានក្នុងឆ្នាំ ២០២៥ ។ សម្រាប់ឆ្នាំ ២០២៧-២០២៨, ចំណូលចរន្ត ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យម ក្នុងអត្រា ៧,៥% និងស្ថិតក្នុងរង្វង់ ១៣,៩៨% នៃ ផ.ស.ស. នៅឆ្នាំ ២០២៨,** ទាបជាងគោលដៅចំណូលចរន្តដាក់ចេញក្នុង **«យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិ-កាលទី៧នៃរដ្ឋសភា»** ដែលត្រូវសម្រេចឱ្យបានក្នុងរង្វង់ ១៦% នៃ ផ.ស.ស. ។ ការណ៍ដែលពុំអាចសម្រេចតាមគោលដៅ ដែលបានដាក់ចេញនេះ គឺដោយសារ ការកើនឡើងនៃភាពមិនប្រាកដប្រជា និងការកើនឡើងកម្តៅនៃសង្គ្រាមពាណិជ្ជកម្ម ដែលនាំមកនូវឥទ្ធិពលជាអវិជ្ជមាន មកលើទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចកម្ពុជា និងការរំពឹងទុកនៃលទ្ធភាពក្នុងការ-ប្រមូលចំណូលជារួម ។

**ចំណូលសារពើពន្ធប្រមូលដោយ អគ្គនាយកដ្ឋានពន្ធដារ** ត្រូវបានព្យាករថានឹងមាន កំណើនប្រមាណ ៦,០% ធៀបនឹងលទ្ធផលប៉ាន់ស្មានក្នុងឆ្នាំ ២០២៥ និង សម្រេចបានកំណើនជាមធ្យមក្នុងអត្រា ៧,២% សម្រាប់ឆ្នាំ ២០២៧-២០២៨ ។ ជារួម, លទ្ធផលខាងលើ ត្រូវបានព្យាករក្រោមមូលដ្ឋាន

សម្បត្តិកម្ម ដែលចំណូលពីវិស័យគាំទ្រមួយចំនួន ដូចជា វិស័យសកម្មភាពស្នាក់នៅ និងអាហារ, វិស័យកម្មន្តសាល ព្រមទាំងវិស័យដឹកជញ្ជូន និងស្តុក ក៏នឹងជួយរុញច្រានកំណើនចំណូល ប៉ុន្តែចំណូលពីវិស័យសាងសង់ និងអចលទ្រព្យ នឹងបន្តមានកំណើនយឺត ។ បន្ថែមលើនេះ, ការចាប់ផ្តើមឡើង-វិញ នូវកិច្ចការពង្រឹងអនុលោមភាពអ្នកជាប់ពន្ធ នឹងក្លាយជាចលករដ៏សំខាន់ ក្នុងការពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូល និងរក្សាស្ថិរភាពកំណើនចំណូលក្នុងរយៈពេលមធ្យម ។

**ចំណូលសារពើពន្ធប្រមូលដោយ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា** ត្រូវបានព្យាករថានឹងមាន កំណើនប្រមាណ ៤,៦% ធៀបនឹងលទ្ធផលប៉ាន់ស្មានក្នុងឆ្នាំ ២០២៥ និងសម្រេចបានកំណើនក្នុងរង្វង់ ៦,៥% សម្រាប់ឆ្នាំ ២០២៧-២០២៨ ស្របតាមការរំពឹងទុកនៃតម្រូវការប្រើប្រាស់របស់ប្រជាជន ក្នុងកំណើនសមគួរ ពិសេសលើតម្រូវការនាំចូលនៃទំនិញប្រណីត ដែលជាមូលដ្ឋាននៃចំណូលប្រមូលដោយ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ខណៈ ចំណាយសារពើពន្ធលើកម្មវិធីពិសេសរបស់រាជរដ្ឋាភិបាល និងការអនុគ្រោះផ្នែកសារពើពន្ធ អនុលោមតាមច្បាប់វិនិ-យោគ ត្រូវបានរំពឹងទុកថានឹងមាននិន្នាការកើនសន្សឹមៗ ។ ជាមួយគ្នានេះ, ចំណូលនេះ អាចនឹងសម្រេចបានខ្ពស់ ឬ ទាបជាងនេះ អាស្រ័យលើទំហំនៃការនាំចូលលើមុខទំនិញសំខាន់ៗ ដូចជា រថយន្ត, តេលសិលា, គ្រឿងសំណង់ និងទំនិញចម្រុះ ។

**ចំណូលមិនមែនសារពើពន្ធ** ត្រូវបានព្យាករថានឹងមានកំណើនប្រមាណ ៩,៥% ក្នុងឆ្នាំ ២០២៦ និងរំពឹងថាសម្រេចបានកំណើនជាមធ្យម ក្នុងរង្វង់ ១១,២% សម្រាប់ឆ្នាំ ២០២៧-២០២៨ ។ ក្នុងនោះ ចំណូលនេះក្នុងរយៈពេលមធ្យម ត្រូវបានរំពឹងទុកថានឹងគាំទ្រ ដោយការបន្តពង្រឹងការកៀរគរចំណូលពីប្រភពដែលនៅមានសក្តានុពល ស្របពេលដែលចំណូលពីសម្បទានរ៉ែ, វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍, ផលទុនសកម្មភាពទេសចរណ៍, អាករស្ថានទូត និងផលទុនរបស់អាកាសចរស៊ីវិល ត្រូវបានរំពឹងទុកថានឹងបន្តរើបឡើង ។

**តារាងទី ៧៖ ការព្យាករចំណូលរយៈពេលមធ្យម ឆ្នាំ ២០២៦-២០២៨**

| | កំណើនប្រចាំឆ្នាំ | | | ភាគរយនៃ ផ.ស.ស. | | |
|---|---|---|---|---|---|---|
| | 2026ព្យ. | 2027ព្យ. | 2028ព្យ. | 2026ព្យ. | 2027ព្យ. | 2028ព្យ. |
| **ចំណូលសរុប** | **5.5%** | **6.8%** | **7.8%** | **14.63%** | **14.48%** | **14.43%** |
| **ចំណូលចរន្ត** | **5.9%** | **7.0%** | **8.0%** | **14.13%** | **14.01%** | **13.98%** |
| **ចំណូលសារពើពន្ធ** | **5.4%** | **6.4%** | **7.5%** | **12.17%** | **12.00%** | **11.91%** |
| អគ្គនាយកដ្ឋានពន្ធដារ | 6.0% | 6.7% | 7.8% | 6.93% | 6.85% | 6.82% |
| *ក្នុងនោះ ថ្នាក់ក្រោមជាតិ* | *3.5%* | *7.0%* | *8.1%* | *0.90%* | *0.89%* | *0.89%* |
| អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | 4.6% | 5.9% | 7.0% | 5.24% | 5.15% | 5.09% |
| **ចំណូលមិនមែនសារពើពន្ធ** | **9.5%** | **10.9%** | **11.5%** | **1.95%** | **2.01%** | **2.07%** |
| *ក្នុងនោះ ថ្នាក់ក្រោមជាតិ* | *3.3%* | *3.9%* | *3.7%* | *0.14%* | *0.13%* | *0.13%* |
| **ចំណូលផ្សេងៗ** | **-6.7%** | **1.1%** | **1.4%** | **0.51%** | **0.48%** | **0.45%** |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ដើម្បីសម្រេចឱ្យបាននូវលទ្ធផលព្យាករណ៍ខាងលើ និងឆ្លើយតបទៅនឹងបញ្ហាប្រឈមលើការប្រមូលចំណូល ព្រមទាំងទ្រទ្រង់ចលនការនៃចីរភាពកំណើនសេដ្ឋកិច្ច, **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨** ដាក់ចេញនូវវិធានការគន្លឹះលើផ្នែកចំណូលបន្ថែម ដូចខាងក្រោម៖

### ■ វិធានការផ្នែកពន្ធដារ

- បង្កើនប្រសិទ្ធភាព និងយន្តការនៃការស៊ើបអង្កេតបទល្មើសពន្ធដារ តាមរយៈការអនុវត្តសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌពីពន្ធដារ និងបែបបទ និងនីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌស្តីពីពន្ធដារ (SOP on Investigation) ដើម្បីធានាឱ្យមាននូវតម្លាភាព និងធានានូវការប្រកួតប្រជែងស្មើភាពគ្នា និងបង្កើតឱ្យមានភាពជឿទុកចិត្តពីសាធារណជន ក៏ដូចជាពង្រឹងប្រសិទ្ធភាពនៃយន្តការ ឬ ប្រព័ន្ធផ្តល់មតិយោបល់ (Feedback Mechanism) ពីអ្នកជាប់ពន្ធ ដែលអាចធានាបាននូវភាពសម្ងាត់នៃឯកជនភាព ទំនុកចិត្តខ្ពស់ និងឆ្លើយតបដល់អ្នកជាប់ពន្ធ;
- បន្តជំរុញ និងលើកទឹកចិត្តអ្នកជាប់ពន្ធឱ្យមកចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត, ជាពិសេស សហគ្រាសធុនតូច និងមធ្យម;
- បន្តសិក្សា និងរៀបចំអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល ដើម្បីត្រៀមអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល;
- អនុវត្តសាកល្បងនូវប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក (E-invoicing system) ដោយ ៖ (១). សិក្សាស្វែងយល់ពីភាពជាដៃគូរជាមួយវិស័យឯកជន ដើម្បីអនុវត្តប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក ដែលសម្រួលដល់ការរាយការណ៍ និងសុពលភាពប្រតិបត្តិការទាន់ពេល; និង (២). រៀបចំលិខិតបទដ្ឋានគតិយុត្ត និងឯកសារណែនាំគ្រប់ជ្រុងជ្រោយ ដើម្បីដាក់ឱ្យដំណើរការសាកល្បងនូវវិក្កយបត្រអេឡិចត្រូនិក;

- ចូលរួមអនុវត្តវិធានការពាក់ព័ន្ធនឹងពន្ធដារ ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីជំរុញវិស័យទាំងនោះឱ្យចូលក្នុងប្រព័ន្ធ ព្រមទាំងលើកទឹកចិត្ត និងថែរក្សាឱ្យវិស័យទាំងនោះក្លាយជាមូលដ្ឋានចំណូលពន្ធបន្ថែម;
- ពង្រឹងយន្តការនៃការអនុវត្តប្រព័ន្ធបង្វិលសងអាករលើតម្លៃបន្ថែម ដើម្បីលើកកម្ពស់ និងធានានូវប្រសិទ្ធភាព ក្នុងការស្នើសុំជាតុចូលអាករលើតម្លៃបន្ថែមលើការកាត់បន្ថយរយៈពេល និងចៀសវាងការយោងឥណទានអាករលើតម្លៃបន្ថែមលើសលប់ក្នុងរយៈពេលយូរ;
- បន្តជំរុញលើការងាររៀបចំការចរចា និងពង្រីកវិសាលភាពនៃកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នា (DTA);
- ពង្រឹងការប្រមូលចំណូលពន្ធ ជាពិសេសអាករលើតម្លៃបន្ថែម លើការផ្គត់ផ្គង់ទំនិញឌីជីថល ឬ សេវាឌីជីថល ដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក;
- សិក្សាអំពីលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តប្រព័ន្ធ Self-service ជាមគ្គុទេសក៍សម្រាប់អ្នកជាប់ពន្ធ ដើម្បីអាចផ្តល់លទ្ធភាពដល់អ្នកជាប់ពន្ធ ដែលបានចុះបញ្ជីក្នុងប្រព័ន្ធពន្ធដារ អាចដឹងពីប្រភេទពន្ធអាករដែលខ្លួនត្រូវបង់ តាមដានទិន្នន័យបំណុលពន្ធ ដឹងពីស្ថានភាពនៃការចុះធ្វើសវនកម្ម និងទិន្នន័យផ្សេងៗទៀត;
- បន្តរៀបចំជាទៀងទាត់នូវការសិក្សាលើកម្រិតនៃការពេញចិត្តអ្នកជាប់ពន្ធ (Satisfaction survey) លើសេវាអ្នកជាប់ពន្ធ ដើម្បីកែលម្អសេវាកម្មអ្នកជាប់ពន្ធ;
- បន្តលើកកម្ពស់សេវាអ្នកជាប់ពន្ធ ជាពិសេសឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលដោយបន្តធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសមាហរណកម្មប្រព័ន្ធមុខងារស្នូល កាន់តែប្រទាក់ក្រឡាជាងមុន រួមមានការចុះបញ្ជីពន្ធដារ (E-registration), ការដាក់លិខិតប្រកាសពន្ធ (E-filling), និងការបង់ប្រាក់ពន្ធ (E-payment), និងបន្តបង្កើនប្រសិទ្ធភាពសវនកម្មពន្ធ និងកាត់បន្ថយការធ្វើសវនកម្មពន្ធត្រួតគ្នា និងច្រើនលើកច្រើនសារ តាមរយៈការអនុវត្តសៀវភៅណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ (SOP on Auditing); និង
- បន្តពង្រឹងការគ្រប់គ្រងបំណុលពន្ធ សំដៅកាត់បន្ថយជាអតិបរមានូវបំណុលពន្ធបច្ចុប្បន្ន និងចៀសវាងការកើនឡើងបំណុលពន្ធអនាគត ។

### ■ វិធានការផ្នែកគយ និងរដ្ឋាករ

- បន្តតាមដាន និងរៀបចំវិធានការឆ្លើយតប ទៅនឹងការដាក់ចេញនូវគោលនយោបាយពន្ធគយបដិការរបស់ប្រទេសជាដៃគូពាណិជ្ជកម្ម;
- បន្តអនុវត្តវិធានការកែទម្រង់គន្លឹះ និងមុតស្រួចទាំង ១៤ នៃផ្នែកកិច្ចសម្រួលពាណិជ្ជកម្មក្រោមដែនសមត្ថកិច្ចគយ ដែលបានដាក់ចេញក្នុង វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី ១៩;
- បង្កើនប្រសិទ្ធភាពការគ្រប់គ្រងការអនុវត្តអត្រាពន្ធអនុគ្រោះ ក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធ និងអាករក្រោមក្របខ័ណ្ឌផ្សេងៗ, ពិសេសគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ);

- ពង្រឹងអនុលោមភាព និងរៀបចំយន្តការគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-commerce platform) និងជំរុញឱ្យមានការប្រើប្រាស់មុខងារទូទាត់ប្រាក់តាមមធ្យោបាយអេឡិចត្រូនិក (E-Payment) ឱ្យបានជាអតិបរមា;
- កែលម្អគោលនយោបាយពន្ធ និងអាករ សម្រាប់វិស័យអាទិភាព និងពង្រឹងការអនុវត្តគោលការណ៍លើកទឹកចិត្តពន្ធ និងអាករស្របតាមច្បាប់ និងបទប្បញ្ញត្តិថ្មីៗ;
- ពង្រីកវិសាលភាពការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម បន្តធ្វើសាមញ្ញកម្មដោយប្រើប្រាស់ឯកសារទម្រង់អេឡិចត្រូនិក និងកាត់បន្ថយឯកសារជាក្រដាស និងប្រើប្រាស់បញ្ញាសិប្បនិម្មិតក្នុងប្រតិបត្តិការគយ;
- បន្តពង្រឹងយន្តការធុរជនល្អបំផុត (Best Trader Mechanism) កែលម្អប្រព្រឹត្តកម្មលើកទឹកចិត្ត និងពង្រីកបន្ថែមការយល់ដឹងជាសាធារណៈអំពីអត្ថប្រយោជន៍នៃយន្តការ ព្រមទាំងបន្តជំរុញការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត (Authorized Economic Operator Programme - AEO);
- ពង្រីកវិសាលភាពនៃប្រតិបត្តិការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ និងយកចិត្តទុកដាក់ប្រយុទ្ធប្រឆាំងទំនិញល្មើសកម្មសិទ្ធិបញ្ញា;
- លើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ម៉ាស៊ីនស្កេន ដោយត្រូវសិក្សា និងពិនិត្យលទ្ធភាពបំពាក់ម៉ាស៊ីនស្កេន នៅមាត់ច្រកសំខាន់ៗបន្ថែមទៀតដោយប្រើប្រាស់ថវិការដ្ឋ ដើម្បីគាំទ្រការពង្រឹងអនុលោមភាពដោយរក្សាបាននូវកិច្ចសម្រួលពាណិជ្ជកម្ម;
- ជំរុញការអនុវត្តពេញលេញនីតិវិធីបំពេញបែបបទគយមុនពេលទំនិញមកដល់ តាមប្រព័ន្ធអេឡិចត្រូនិកដើម្បីបង្កើនប្រសិទ្ធភាព នៃការងារគ្រប់គ្រងហានិភ័យគយ កាត់បន្ថយពេលឆ្លងកាត់ព្រំដែន និងចំណាយប្រតិបត្តិការផ្សេងៗ; និង
- បន្តពង្រឹងយន្តការភាពជាដៃគូរជាមួយវិស័យឯកជន ក្នុងការពិគ្រោះយោបល់ និងដោះស្រាយបញ្ហានានា ។

## ■ វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ

- ជំរុញការបញ្ចូលរាល់ប្រតិបត្តិការចំណូលមិនមែនសារពើពន្ធ នៅថ្នាក់រដ្ឋបាលកណ្តាលក្រសួង-ស្ថាប័ន និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រព័ន្ធ NRMIS និងការធ្វើសន្ធានកម្មទិន្នន័យជាមួយប្រព័ន្ធ FMIS ប្រព័ន្ធ SARMIS និងប្រព័ន្ធសំខាន់ៗដទៃទៀត;
- ពន្លឿនក្រសួង-ស្ថាប័នក្នុងការបំពេញឱ្យបានប្រតិបត្តិការជាប្រក្រតី តាមការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន លើរាល់ប្រតិបត្តិការទាក់ទងនឹងការប្រមូលចំណូលទ្រព្យសម្បត្តិរដ្ឋ;
- រៀបចំផែនការសកម្មភាពជាក់លាក់តាមក្រសួងស្ថាប័ន ដែលទទួលបន្ទុកការប្រមូលចំណូលមិនមែនសារពើពន្ធ សំដៅជំរុញការកៀរគរនិងប្រមូលចំណូលមិនមែនសារពើពន្ធ, ជាពិសេស លើមុខចំណូលធំៗសំខាន់ៗ, ឱ្យអស់សក្តានុពល និងបង់ចូលថវិការដ្ឋ ស្របតាម **យុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា**;
- បន្តជំរុញការប្រើប្រាស់ e-Payment ឱ្យបានពេញលេញ ប្រកបដោយសុខដុមនីយកម្ម និងមានភាពងាយស្រួលក្នុងការទូទាត់;

- ពិនិត្យ និងជំរុញក្រុមហ៊ុនដែលទទួលបានសិទ្ធិពីរដ្ឋសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនធ្វើការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មធនធានរ៉ែ, ឧស្ម័ន និងប្រេងកាត ជាដើម ឱ្យបន្តដំណើរការអនុវត្តតាមកិច្ចសន្យា ឬ ចាត់វិធានការសមស្របតាមការចាំបាច់ចំពោះករណីមិនមានអនុលោមភាព;
- បន្តជំរុញការបង់ និងការកត់ត្រាចំណូលពី សហគ្រាសសាធារណៈ;
- បន្តពង្រឹងយន្តការប្រមូលចំណូលពីឥណទានកាបូនឱ្យមានប្រសិទ្ធភាព ស្របតាមតម្លៃសេដ្ឋកិច្ច;
- បន្តពង្រឹងប្រសិទ្ធភាពនៃការធ្វើសវនកម្ម ដើម្បីជំរុញការបំពេញចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូប្រចាំខែឱ្យបានត្រឹមត្រូវ និងតាមដានប្រតិបត្តិការកាស៊ីណូដែលបង់ចំណូលកាតព្វកិច្ចពីល្បែងមិនសមាមាត្រទៅនឹងទំហំអាជីវកម្ម ព្រមទាំងបន្តតឹងទារបំណុលដែលនៅសល់; និង
- បន្តពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូលកាតព្វកិច្ចពីសកម្មភាពល្បែងគ្រប់ប្រភេទដែលកំពុងដំណើរការស្របច្បាប់ ឱ្យអស់លទ្ធភាព ។

## ខ. ក្របខ័ណ្ឌចំណាយសាធារណៈ

**ចំណាយសាធារណៈ សម្រាប់ឆ្នាំ ២០២៦-២០២៨** ត្រូវបានគ្រោងឡើង ស្របតាមជំហរគោលនយោបាយដែលបានដាក់ចេញខាងលើ ដោយរៀបចំលើមូលដ្ឋានតុល្យភាពនៃចំណូលនិងចំណាយ និងពុំមានការប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាល ។ ក្នុងន័យនេះ, ការគ្រោងចំណាយសាធារណៈសម្រាប់រយៈពេលមធ្យម ត្រូវបានរៀបចំប្រកបដោយភាពប្រុងប្រយ័ត្ន និងបុរេសកម្មខ្ពស់ ដោយឈរលើគោលការណ៍គោរពម៉ឺងម៉ាត់វិន័យថវិកា និងពង្រឹងប្រសិទ្ធភាពថវិកា តាមរយៈការបន្តខិតខំកែលម្អការវិភាជថវិកាឱ្យកាន់តែចំទិសដៅ និងចំតម្រូវការចាំបាច់ជាក់ស្តែង ។ ក្របខ័ណ្ឌចំណាយសាធារណៈរយៈពេលមធ្យមនេះ បានបន្តគិតគូរធ្វើអាទិភាពូបនីយកម្មចំណាយ ដោយផ្តោតចម្បងលើការរក្សាលំនឹងសង្គម-សេដ្ឋកិច្ច, ការបន្តអនុវត្តគោលនយោបាយគាំពារសង្គម, ការអភិវឌ្ឍមូលធនមនុស្ស, ការពង្រឹងសមត្ថភាពស្ថាប័ន, ការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ជារចនាសម្ព័ន្ធ ព្រមទាំង ការអនុវត្តគោលនយោបាយអាទិភាពគន្លឹះ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង, បង្កើនផលិតភាព និងជំរុញការធ្វើពិពិធកម្មឱ្យខ្លាំងក្លា សំដៅកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់កំណើន និងការបង្កើតការងារ និងការវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ និងមានភាពធន់ សម្រាប់កិច្ចអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច គាំទ្រដល់ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ច ។ ដោយស្ថានភាពចំណូលមិនទាន់មានភាពប្រសើរវិញដូចការរំពឹងទុក, ពិសេសដោយសារផលជះពីសង្គ្រាមពាណិជ្ជកម្មមកលើសកម្មភាពសេដ្ឋកិច្ចជារួម និងតម្រូវការក្នុងការអន្តរាគមន៍, រាជរដ្ឋាភិបាលសម្រេចពន្យារការអនុវត្ត **«មូលនិធិបម្រុងហិរញ្ញវត្ថុ»** ក្នុងឆ្នាំ ២០២៦ ទៀតសិន ហើយនឹងចាប់គ្រោងឱ្យមានមូលនិធិបម្រុងហិរញ្ញវត្ថុ ក្នុងឆ្នាំ ២០២៧ តទៅ ក្នុងអត្រា ២% នៃចំណូលចរន្តថ្នាក់ជាតិដែលប្រមូលបានឆ្នាំ N-2 ដើម្បីចាប់កសាងទ្រនាប់ថវិកាជាតិឡើងវិញ ។

**សម្រាប់ឆ្នាំ ២០២៦, ចំណាយសរុប ត្រូវបានគ្រោងក្នុងទំហំ ១៦,៨៣% នៃ ផ.ស.ស. ពោលគឺថមថយប្រមាណ -១,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៥ ។ សម្រាប់ឆ្នាំ ២០២៧-២០២៨ កញ្ចប់ចំណាយសរុប នឹងគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យមប្រមាណ ៧,៨% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១៦,៧៤% នៃ ផ.ស.ស. នៅឆ្នាំ ២០២៨ ។**



**ចំណាយចរន្ត ត្រូវបានគ្រោងក្នុងទំហំ ១២,០៥% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៦ ដែលមានកំណើនប្រមាណ ២,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៥ ។ សម្រាប់ឆ្នាំ ២០២៧-២០២៨**

**ចំណាយចរន្ត ត្រូវបានគ្រោងឱ្យមានកំណើន ក្នុងអត្រាជាមធ្យមប្រមាណ ៥,៥% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១១,៤៧% នៃ ផ.ស.ស. នៅឆ្នាំ ២០២៨ ។**

**ចំណាយបន្ទុកបុគ្គលិក ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រា ២,៤% ក្នុងឆ្នាំ ២០២៦ ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៥** សម្រាប់ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ និងការត្រៀមថវិកាសម្រាប់ចំណាយលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ក្នុងរដ្ឋបាលសាធារណៈ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹងការផ្តល់សេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព ។ សម្រាប់ឆ្នាំ ២០២៧-២០២៨, ចំណាយបន្ទុកបុគ្គលិក ត្រូវបានគ្រោងឱ្យកើនជាមធ្យមក្នុងអត្រា ៤,២% ។ ដោយឡែក, **ចំណាយមិនមែនបន្ទុកបុគ្គលិក ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រា ២,៦% ក្នុងឆ្នាំ ២០២៦ ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៥ និងកើនជាមធ្យមក្នុងអត្រា ៦,៥% សម្រាប់ឆ្នាំ ២០២៧-២០២៨** ស្របតាមស្មារតីនៃការពង្រឹងប្រសិទ្ធភាពវិភាជថវិកា តាមរយៈការខិតខំតម្រង់ការវិភាជថវិកាឱ្យបានត្រឹមត្រូវ និងចំគោលដៅ ពិសេសសម្រាប់បម្រើដល់វិស័យសង្គមកិច្ច ហើយត្បិតត្បៀតលើមុខសញ្ញាចំណាយមិនចាំបាច់ និងមិនសូវចាំបាច់ ព្រមទាំងរក្សាឱ្យបាននូវនិរន្តរភាពប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ន, ការលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តគោលនយោបាយគាំពារសង្គម សំដៅលើកកម្ពស់សមធម៌ និងភាពសុខដុម ក្នុងសង្គម ។ **ជាក់ស្តែង, រាជរដ្ឋាភិបាល ក៏បានត្រៀមកញ្ចប់ថវិកា ក្នុងកញ្ចប់ចំណាយត្រៀមបម្រុងមានមុខសញ្ញា សម្រាប់អនុវត្តនូវកម្មវិធីអន្តរាគមន៍ ដើម្បីរក្សាលំនឹងជីវភាពប្រជាជន និងលើកកម្ពស់សមធម៌សង្គម ផងដែរ ។**

**ចំណាយមូលធន ត្រូវបានគ្រោងក្នុងទំហំ ៤,៧៨% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៦ ដែលមានកំណើនអវិជ្ជមានក្នុងអត្រា -១០,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៥ ។** កំណើនអវិជ្ជមាននេះ បណ្តាលមកពីការថមថយនូវមូលនិធិទ្រទ្រង់ថវិកា ដែលជាប្រភពហិរញ្ញប្បទានក្រៅប្រទេស និងការបាត់បង់លក្ខខណ្ឌអនុគ្រោះពីប្រភពហិរញ្ញប្បទានប្រពៃណីដែលមានទម្រង់ជាហិរញ្ញប្បទានឥតសំណង និងឥណទានមានកម្រិតសម្បទានខ្ពស់ បន្ទាប់ពីការចាកចេញពីចំណាត់ថ្នាក់ប្រទេសមានចំណូលទាប ។ យ៉ាងណាមិញ, ចំណាយមូលធនក្នុងឆ្នាំ ២០២៦ នៅតែបន្តផ្តល់ការគិតគូរដល់គម្រោងវិនិយោគសាធារណៈអាទិភាព ស្របតាមគោលដៅអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល និងតាមលទ្ធភាពដែលអាចទ្រទ្រង់បាន ខណៈចំណាយវិនិយោគសាធារណៈ ដោយប្រភពហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានរក្សាក្នុងកម្រិតស្មើច្បាប់ថវិកាឆ្នាំ ២០២៥ ។ **សម្រាប់ឆ្នាំ ២០២៧-២០២៨ ចំណាយមូលធន ត្រូវបានគ្រោងឱ្យមានកំណើនឡើងវិញ ក្នុងអត្រាជាមធ្យមប្រមាណ ១៣,៧% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ៥,២៧% នៃ ផ.ស.ស. នៅឆ្នាំ ២០២៨ ។** កំណើននេះ បានគិតគូរពីតម្រូវការចំណាយចាំបាច់សម្រាប់ការអភិវឌ្ឍ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន, ការរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច, ការលើកកម្ពស់ភាពប្រកួតប្រជែង និងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច ពោលគឺ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពខ្ពស់ទៅលើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ជាពិសេស តាមរយៈការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានគុណភាពខ្ពស់ និងការបង្កើនបរិមាណ និងគុណភាពនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ

ឌីជីថល និងបៃតង ដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់ការធ្វើបរិវត្តកម្មឌីជីថល និងការបន្តជួសជុល, ស្ពាន និងកែលម្អហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា ។

**ជារួម, ចំណាយសរុបថ្នាក់ជាតិ ក្នុងឆ្នាំ ២០២៦ ត្រូវបានគ្រោងក្នុងទំហំ ១៥,៧៩% នៃ ផ.ស.ស. ថមថយប្រមាណ -១,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៥ ។ សម្រាប់ឆ្នាំ ២០២៧-២០២៨, ចំណាយសរុបថ្នាក់ជាតិ នឹងគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យមប្រមាណ ៧,៩% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១៥,៧៣% នៃ ផ.ស.ស. នៅឆ្នាំ ២០២៨** ។ ចំណាយថ្នាក់ជាតិ ដែលរួមបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធនសម្រាប់ឆ្នាំ ២០២៦-២០២៨ ត្រូវបានគ្រោងវិភាជន៍ទៅតាមវិស័យ ដូចខាងក្រោម៖

**ចំណាយវិស័យរដ្ឋបាលទូទៅ ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ១,៥៣% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ (ឆ្នាំ ២០២៦-២០២៨), សមមូលនឹងកំណើនប្រចាំឆ្នាំជាមធ្យមក្នុងអត្រា ៥,៣%** សំដៅបន្តគាំទ្រការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការងារការទូតសេដ្ឋកិច្ច, បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, ការងារទាក់ទាញ និងការគ្រប់គ្រងវិនិយោគឯកជន និងការពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍ, ការធ្វើទំនើបកម្ម និងប្រព័ន្ធស្វ័យប្រវត្តិកម្មរដ្ឋបាលសារពើពន្ធ, ការធ្វើទំនើបកម្មការគ្រប់គ្រងចំណាយសាធារណៈ និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, ការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ចធុរកិច្ច និងសង្គមឌីជីថល, ព្រមទាំងការបន្តត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** ។

**ចំណាយវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ២,៦១% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ (ឆ្នាំ ២០២៦-២០២៨), សមមូលនឹងកំណើនប្រចាំឆ្នាំជាមធ្យមក្នុងអត្រា ៣,៦%** សំដៅបន្តគាំទ្រដល់ការអនុវត្តកិច្ចការពារអធិបតេយ្យជាតិ, ការអនុវត្តកិច្ចការសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ, ការពង្រឹងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ សង្កាត់មានសុវត្ថិភាព», ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យព្រំដែន, ការអភិវឌ្ឍចំណេះដឹង និងជំនាញវិជ្ជាជីវៈជូនកងកម្លាំងនគរបាលជាតិ, ការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ, និងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ ។

**ចំណាយវិស័យសង្គមកិច្ច ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ៤,៩៥% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ (ឆ្នាំ ២០២៦-២០២៨), សមមូលនឹងកំណើនប្រចាំឆ្នាំជាមធ្យមក្នុងអត្រា ៦,១%** ពោលគឺនៅតែត្រូវបានចាត់ទុកជាវិស័យអាទិភាពទី ១ ដោយសំដៅបន្តរក្សាលំនឹងជីវភាពប្រជាជន ព្រមទាំងលើកកម្ពស់សមធម៌សង្គម, បន្តលើកកម្ពស់គុណភាពអប់រំ និងគាំទ្រដល់ការពង្រឹង និងពង្រីកការទទួលបានសេវាអប់រំ និងការអភិវឌ្ឍជំនាញ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ, លើកកម្ពស់គុណភាពសេវាសុខាភិបាល និងការពង្រីកការទទួលបានសេវាថែទាំសុខភាព ឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកល

នៅកម្ពុជា, ជំរុញការអនុវត្តគោលនយោបាយជាតិគាំពារសង្គម, ការបន្តផ្តល់របបសន្តិសុខសង្គម, ការលើកកម្ពស់សមភាពយេនឌ័រ, និងការបន្តគាំទ្រដល់គោលនយោបាយអាទិភាពផ្សេងទៀត ក្នុងផ្នែកសង្គមកិច្ច, សាសនា, វប្បធម៌ និងបរិស្ថាន ។

**ចំណាយវិស័យសេដ្ឋកិច្ច ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ៣,៧១% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ (ឆ្នាំ ២០២៦-២០២៨), សមមូលនឹងកំណើនប្រចាំឆ្នាំជាមធ្យមក្នុងអត្រា ៧,២%** ដោយផ្តោតសំខាន់លើការលើកកម្ពស់ផលិតភាពស្របតាមស្តង់ដា និងតម្រូវការទីផ្សារ; ការបន្តដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្ម ទៅគ្រប់ឃុំ-សង្កាត់ទូទាំងប្រទេស ដើម្បីជំរុញការលើកកម្ពស់ផលិតភាពកសិកម្ម និងការរៀបចំឱ្យមានសមាគមកសិកម្មនៅតាមទីជនបទ; ការគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម; និងការអនុវត្ត **យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ ២០២៣-២០២៨, គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ ២០២០-២០៣០, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល កម្ពុជាឆ្នាំ ២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ ២០២២-២០៣៥** និង **គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០២១-២០៣០** ។ល។

**ចំណាយផ្សេងៗ ត្រូវបានគ្រោងជាមធ្យមឱ្យស្ថិតក្នុងរង្វង់ប្រមាណ ២,៩៩% នៃ ផ.ស.ស. សម្រាប់រយៈពេលមធ្យមខាងមុខ (ឆ្នាំ ២០២៦-២០២៨), សមមូលនឹងកំណើនប្រចាំឆ្នាំជាមធ្យមក្នុងអត្រា ១,៨%** ដែលជាទំហំមួយសមស្រប ក្នុងការផ្តល់លទ្ធភាព និងភាពបត់បែនខ្ពស់ដល់រាជរដ្ឋាភិបាល ដើម្បីបំពេញតម្រូវការចំណាយមានមុខសញ្ញា និងចំណាយត្រៀមបម្រុង និងមិនបានគ្រោងទុកតាមមុខសញ្ញា សំដៅឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាយថាហេតុ របស់រាជរដ្ឋាភិបាល និងក្រសួង-ស្ថាប័ន បានទាន់ពេល ក្នុងការដោះស្រាយបញ្ហាសង្គម-សេដ្ឋកិច្ច និងការអនុវត្តគោលនយោបាយអាទិភាព និងវិធានការគន្លឹះនានា, ការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, ការវិភាជកញ្ចប់ថវិកាការរៀបចំព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ និងកិច្ចការបន្ទាន់ចំពោះមុខផ្សេងទៀត ដូចជា ការត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយធម្មជាតិ និងស្បៀងបម្រុង ជាដើម ។ ដោយឡែក, សម្រាប់ការអនុវត្តជាក់ស្តែង, ចំណាយថវិកាដែលបានគ្រោងក្នុងផ្នែកចំណាយផ្សេងៗនេះ នឹងត្រូវវិភាជទៅតាមវិស័យទាំង ៤ ខាងលើស្របតាមគោលដៅនៃមុខចំណាយនីមួយៗ ។

**ចំណាយសរុបថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ ២០២៦ ត្រូវបានគ្រោងក្នុងទំហំ ១,៨០% នៃ ផ.ស.ស. ដែលរួមបញ្ចូលការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងទំហំ ០,៧៧% នៃ ផ.ស.ស. ។ សម្រាប់ឆ្នាំ ២០២៧-២០២៨ ចំណាយសរុបថ្នាក់ក្រោមជាតិ ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យមប្រមាណ ៦,៤% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១,៧៥% នៃ ផ.ស.ស. នៅឆ្នាំ ២០២៨** ។ ជារួម, កញ្ចប់ថវិកាថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ ២០២៦-២០២៨ នេះ ត្រូវបានគ្រោង សំដៅគាំទ្រដល់ការអភិវឌ្ឍ និងការលើកកម្ពស់គុណភាពនៃសេវាសាធារណៈនៅមូលដ្ឋាន ព្រមទាំងការផ្តល់ប្រាក់ឧបត្ថម្ភលំហែមាតុភាពដល់សមាជិកក្រុមប្រឹក្សាជាស្ត្រី

សម្រាប់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទាំង ៣ ថ្នាក់ និងការបន្តពង្រឹងសមត្ថភាពផ្នែករដ្ឋបាល, បច្ចេក-ទេស និងការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីជានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការផ្ទេរសិទ្ធិអំណាច, ការទទួលខុសត្រូវមុខងារ និងធនធានពីថ្នាក់ជាតិ តាមរយៈការអនុវត្ត **កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី ២ ឆ្នាំ ២០២១-២០៣០** ។

ដើម្បីសម្រេចបាននូវគោលដៅរក្សាស្ថិរភាពសង្គម និងការងើបវិញនូវកំណើនសេដ្ឋកិច្ច, រាជរដ្ឋាភិបាលចាំបាច់ត្រូវពង្រឹងប្រសិទ្ធភាពថវិកា, ទាំងផ្នែកវិភាជន៍ និងផ្នែកប្រតិបត្តិការ, ដោយឈរលើគោលការណ៍គោរពវិន័យថវិកា ប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ និងឆ្លើយតបទៅនឹងទិសដៅគោលនយោបាយ និងកម្មវិធីកែទម្រង់នានា តាមរយៈវិធានការសំខាន់ៗក្នុងការអនុវត្តចំណាយ ២០២៦-២០២៨ ដូចខាងក្រោម ៖

- បន្តពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធលើកទឹកចិត្ត ចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ, សមិទ្ធកម្មការងារ, បង្កើនផលិតភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ក៏ដូចជាពិនិត្យលទ្ធភាពដំឡើងកាំប្រាក់ផ្អែកលើអត្រាអតិផរណា ក្នុងគោលដៅរក្សាលំនឹងជីវភាពរស់នៅរបស់មន្ត្រីគ្រប់ថ្នាក់;
- កំណត់គោលការណ៍ក្នុងការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី, ទាំងមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ, ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងអាទិភាព;
- បន្តអភិវឌ្ឍប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត ស្របតាមតម្រូវការទីផ្សារការងារ និងឌីជីថលភាវូបនីយកម្ម និងគាំទ្រដល់ផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់;
- បន្តពង្រឹងប្រព័ន្ធសុខាភិបាល ឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា និងបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីកសាងភាពធន់ និងលើកកម្ពស់សុខុមាលភាពសង្គម;
- បន្តតម្រង់ធនធានថវិកាលើវិស័យគន្លឹះ ដែលនឹងធានាឱ្យបានភាពធន់ បរិយាប័ន្ន និងចីរភាព តាមរយៈការផ្តល់អាទិភាពទៅលើការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់រចនាសម្ព័ន្ធ, ការអភិវឌ្ឍមូលធនមនុស្ស, និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តឌីជីថល ការជំរុញការធ្វើបរិវត្តកម្មឌីជីថល និងការអភិវឌ្ឍបៃតង;
- បន្តជំរុញពិពិធកម្មសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍវិស័យដែលជាប្រភពថ្មីនៃកំណើន និងបន្តកៀរគរធនធានពីគ្រប់ប្រភពឱ្យអស់សក្តានុពល ដើម្បីលើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពប្រកួតប្រជែង និងការអនុវត្តយន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការវិនិយោគដែលបង្កើនតម្លៃបន្ថែមខ្ពស់;
- ផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធភាពចំណូល ដែលមានប្រភពពីការប្រមូលចំណូលក្នុងប្រទេសដោយខិតខំមិនប្រើប្រាក់សន្សំរបស់រាជរដ្ឋាភិបាល លើកលែងតែករណីចាំបាច់បំផុត ដើម្បីរក្សាតុល្យភាព និងចីរភាពថវិកា តាមរយៈការធ្វើអាទិភាវូបនីយកម្មចំណាយ និងពង្រឹងប្រសិទ្ធភាពថវិកា, ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ;
- ពង្រឹងនីតិវិធីនៃការគ្រប់គ្រង, រៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ និងការជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ;

- កសាង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតាមបណ្តោយព្រំដែន ពិសេសផ្លូវក្រវាត់ព្រំដែន និងអភិវឌ្ឍតំបន់ភូមិភាគឦសាន ដែលមានសក្តានុពលសេដ្ឋកិច្ច ដោយផ្តោតលើវិស័យកសិ-ឧស្សាហកម្ម;
- កែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ ដែលជាមូលដ្ឋានក្នុងការរៀបចំ ការវាយ-តម្លៃការជ្រើសរើសគម្រោង និងការប្រៀបធៀបតម្លៃគម្រោង;
- ពិនិត្យ និងវាយតម្លៃហានិភ័យឱ្យបានហ្មត់ចត់ លើការអនុវត្តគម្រោងវិនិយោគសាធារណៈនីមួយៗ ដើម្បីអាចគ្រប់គ្រងលើហានិភ័យដែលអាចកើតមានឡើង និងកាត់បន្ថយចំណាយប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព;
- ពង្រឹងការតាមដាន និងវាយតម្លៃលើការអនុវត្តថវិកា ឱ្យកាន់តែហ្មត់ចត់លើភាពសមស្របនៃថ្លៃ, បរិមាណ និងគុណភាព ក្នុងគោលដៅបន្តលើកកម្ពស់បន្ថែមនូវប្រសិទ្ធភាពនៃការវិភាជថវិកា និងបង្កើនគុណភាពនៃការកំណត់សូចនាករគន្លឹះឱ្យបានសមស្រប;
- បន្តរក្សាចីរភាពបំណុលរយៈពេលមធ្យម និងវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប តាមរយៈការកំណត់ពិតាននៃការខ្ចីប្រចាំឆ្នាំ និងការធានារបស់រដ្ឋ, ការកំណត់សូចនាករបំណុលគន្លឹះសំខាន់ៗ, ការកំណត់គោលដៅនៃការប្រើប្រាស់ហិរញ្ញប្បទាន និងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំ-ទូលាយ; និង
- បន្តពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព និងគណនេយ្យភាពនូវ **យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ឆ្នាំ២០២៤-២០២៨** សំដៅធានាចីរភាពហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតសំខាន់លើការវិនិយោគចំពោះវិស័យអាទិភាព ជាពិសេស វិស័យបង្កើនផលិតភាព និងតម្លៃបន្ថែម, ជំរុញការតភ្ជាប់, និងពង្រឹងភាពប្រកួត-ប្រជែង និងពិពិធកម្មសេដ្ឋកិច្ច ។

## គ. ឱនភាពថវិកា និងហិរញ្ញប្បទាន

**ឱនភាពថវិកាសរុបសម្រាប់រយៈពេលមធ្យម** ត្រូវបានរំពឹងទុកថានឹងរួមតូចពីច្បាប់ថវិកាឆ្នាំ ២០២៥ ដែលឆ្លុះបញ្ចាំងអំពី ការបន្តដាក់ចេញនូវ **គោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន** និងការអនុលោមតាមវិធានហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញ សំដៅរក្សាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុសាធារណៈ និងចីរភាពបំណុលសាធារណៈរបស់កម្ពុជានាពេលខាងមុខ ។ **ក្នុងន័យនេះ, ឱនភាពថវិកាក្នុងឆ្នាំ ២០២៦ នឹងស្ថិតក្នុងកម្រិត -២,១៩% នៃ ផ.ស.ស. និងសម្រាប់ឆ្នាំ ២០២៧-២០២៨ នឹងស្ថិតក្នុងរង្វង់ជាមធ្យមប្រមាណ -២,២១% នៃ ផ.ស.ស. ដែលជាកម្រិតទាបជាង រយៈពេល ៤ឆ្នាំ កន្លង (២០២១-២០២៤)** ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាល អាចមានលទ្ធភាពរៀបចំមូលនិធិបម្រុងហិរញ្ញវត្ថុរបស់រដ្ឋ ក្នុងទំហំសរុបប្រមាណ ១ ១២៧ ប៊ីលានរៀល សម្រាប់ឆ្នាំ ២០២៧-២០២៨ ។ ជារួម, ហិរញ្ញប្បទានដើម្បីទ្រទ្រង់ឱនភាពថវិកាក្នុងរយៈពេលមធ្យមខាងមុខ នឹងបន្តទទួលបានមកពីប្រភព ៣ សំខាន់ៗ រួមមាន៖ **១)**. ហិរញ្ញប្បទានផ្ទាល់ពីក្រៅប្រទេសសម្រាប់គម្រោងវិនិយោគសាធារណៈ; **២)**. មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ; និង **៣)**. ការបោះផ្សាយមូលបត្ររដ្ឋ ។

### តារាងទី ៨៖ តារាងសង្ខេបក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៦-២០២៨

| ភាគរយនៃ ផ.ស.ស. | 2025ច្បា. | 2025 កែ. | 2026ព្យ. | 2027ព្យ. | 2028ព្យ. |
|---|---|---|---|---|---|
| **ចំណូលសរុប** | **15.31%** | **14.91%** | **14.63%** | **14.48%** | **14.43%** |
| ចំណូលចរន្ត | 14.72% | 14.32% | 14.13% | 14.01% | 13.98% |
| **ចំណាយសរុប** | **18.39%** | **18.39%** | **16.83%** | **16.57%** | **16.74%** |
| ចំណាយចរន្ត | 12.62% | 12.62% | 12.05% | 11.84% | 11.47% |
| ចំណាយមូលធន | 5.76% | 5.76% | 4.78% | 4.73% | 5.27% |
| **អតិរេកចរន្ត** | **2.10%** | **1.70%** | **2.08%** | **2.16%** | **2.51%** |
| **សមតុល្យថវិកា** | **-3.08%** | **-3.48%** | **-2.19%** | **-2.09%** | **-2.32%** |
| ***តម្រូវការហិរញ្ញប្បទាន*** | ***4.25%*** | ***4.66%*** | ***3.60%*** | ***3.76%*** | ***3.88%*** |
| *ឱនភាពថវិកា* | 3.08% | 3.48% | 2.19% | 2.09% | 2.32% |
| *ការខូចខាតការខ្ចី* | 1.18% | 1.18% | 1.20% | 1.25% | 1.14% |
| *ការបង្វិលសងអាករលើតម្លៃបន្ថែម* | 0.00% | 0.00% | 0.20% | 0.42% | 0.42% |
| ***ប្រភពហិរញ្ញប្បទាន*** | ***4.25%*** | ***4.66%*** | ***3.60%*** | ***3.76%*** | ***3.88%*** |
| *ហិរញ្ញប្បទានក្រៅប្រទេស* | 3.06% | 3.06% | 2.95% | 2.83% | 3.04% |
| *មូលនិធិទ្រទ្រង់ថវិកា* | 0.96% | 0.96% | 0.22% | 0.24% | 0.16% |
| *ការបោះផ្សាយមូលបត្ររដ្ឋ* | 0.24% | 0.24% | 0.23% | 0.28% | 0.26% |
| *ប្រាក់បញ្ញើរាជរដ្ឋាភិបាល* | 0.00% | 0.40% | 0.00% | 0.00% | 0.00% |
| *ការបង្វិលសងអាករលើតម្លៃបន្ថែម* | 0.00% | 0.00% | 0.20% | 0.42% | 0.42% |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

### ឃ. លទ្ធផលក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមធៀបទៅនឹងវិធានហិរញ្ញវត្ថុសាធារណៈ

ជារួម, **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨** ត្រូវបានរៀបចំដោយប្រកាន់ខ្ជាប់នូវវិធានហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញ ។ ជាក់ស្តែង, **បំណុលសាធារណៈសរុបរបស់កម្ពុជាសម្រាប់ឆ្នាំ ២០២៦-២០២៨ ជាតម្លៃបច្ចុប្បន្ន** ត្រូវបានប៉ាន់ស្មានថានឹងស្ថិតក្នុងកម្រិតជាមធ្យម ១៩,៤១% នៃ ផ.ស.ស. និង**ជាតម្លៃចារឹក** ក្នុងកម្រិតជាមធ្យម ២៧,៧៧% នៃ ផ.ស.ស. ខណៈសូចនាករចំនួន ៤ ផ្សេងទៀតរបស់យុថ្កាហិរញ្ញវត្ថុសាធារណៈ ក៏ស្ថិតក្នុងកម្រិតទាបជាងពិតានដែលបានកំណត់ ។ បន្ថែមលើនេះ, ឱនភាពថវិកាសម្រាប់ឆ្នាំ ២០២៥ ក៏ត្រូវបានប៉ាន់ស្មានថានឹងស្ថិតក្រោមកម្រិតក្រោមការកំណត់ដោយវិធានប្រតិបត្តិ ផងដែរ ។

**តារាងទី ៩៖ ការព្យាករសូចនាករវិធានហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៥-២០២៨**

| សូចនាករ | អនុបាតគោល | 2025ប៉ាន់. | 2026ព្យ. | 2027ព្យ. | 2028ព្យ. |
|---|---|---|---|---|---|
| **១. យុថ្កាហិរញ្ញវត្ថុសាធារណៈ** | | | | | |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. | **55%** | 18.79% | 19.02% | 19.46% | 19.74% |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ផ.ស.ស. | **40%** | 18.40% | 18.47% | 18.89% | 19.09% |
| អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ | **180%** | 26.41% | 25.53% | 25.00% | 24.08% |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ការនាំចេញ | **15%** | 1.87% | 1.98% | 1.88% | 1.76% |
| អនុបាតសេវាបំណុលសាធារណៈក្រៅប្រទេស ធៀបនឹង ចំណូលថវិកាជាតិ | **18%** | 8.75% | 9.82% | 9.85% | 9.73% |
| អនុបាតតម្លៃចារឹកនៃបំណុលសាធារណៈសរុប ធៀបនឹង ផ.ស.ស. | **40%** | 26.59% | 27.19% | 27.91% | 28.22% |
| **២. វិធានប្រតិបត្តិ** | | | | | |
| ឱនភាពថវិកាសរុប | **-5%** | -3.48% | -2.19% | -2.09% | -2.32% |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ៥. ហានិភ័យហិរញ្ញវត្ថុសាធារណៈ

**ហានិភ័យហិរញ្ញវត្ថុសាធារណៈ** សំដៅដល់ព្រឹត្តិការណ៍ ឬ ការប៉ះទង្គិចណាមួយ ដែលធ្វើឱ្យការប្រមូលចំណូល សម្រេចបានទាបជាងការគ្រោងទុក និង/ឬ ធ្វើឱ្យទំហំនៃចំណាយសរុបច្រើនជាងការកំណត់ ដែលជាលទ្ធផលធ្វើឱ្យឱនភាពថវិការីកធំ ។ ការវាយតម្លៃហានិភ័យហិរញ្ញវត្ថុសាធារណៈ រួមមាន ការវិភាគអំពីមូលដ្ឋាននៃហានិភ័យ, ការប៉ាន់ប្រមាណនូវភាពអាចកើតមានឡើងនៃផលប៉ះពាល់ ព្រមទាំងការរៀបចំ និងអនុវត្តយន្តការចាំបាច់នានា ដើម្បីទប់ស្កាត់, បញ្ចៀស និងកាត់បន្ថយផលប៉ះទង្គិច ដែលអាចកើតចេញពីបណ្តាហានិភ័យទាំងនេះ ។

**តារាងទី ១០៖ សេចក្តីសង្ខេបទំហំផលប៉ះពាល់ និងលទ្ធភាពកើតមានឡើងនៃហានិភ័យហិរញ្ញវត្ថុសាធារណៈ**

| ទំហំផលប៉ះពាល់លើហិរញ្ញវត្ថុសាធារណៈ | ទាប | មធ្យម | ខ្ពស់ |
|---|---|---|---|
| ខ្ពស់ | | • ហានិភ័យពីវិស័យហិរញ្ញវត្ថុ | |
| មធ្យម | | • ភាពជឿទុកចិត្តបាននៃក្របខ័ណ្ឌ | • ហានិភ័យម៉ាក្រូសេដ្ឋកិច្ច |
| ទាប | • ហានិភ័យពីសហគ្រាសសាធារណៈ និងការវិនិយោគសាធារណៈ<br>• ភាពជាដៃគូរវាងរដ្ឋ និងឯកជន (ការធានារបស់រដ្ឋ) | • ហានិភ័យបំណុលរបស់រដ្ឋាភិបាល | |
| | **លទ្ធភាពកើតមានឡើង** | | |

## ក. ហានិភ័យម៉ាក្រូសេដ្ឋកិច្ច

**ហានិភ័យម៉ាក្រូសេដ្ឋកិច្ច** សំដៅដល់ព្រឹត្តិការណ៍ណាមួយ ដែលបង្កជាផលអវិជ្ជមានដោយផ្ទាល់ និងប្រយោល ដល់កំណើនសេដ្ឋកិច្ចជាតិ ។ ក្នុងនោះ ភាគច្រើននៃហានិភ័យម៉ាក្រូសេដ្ឋកិច្ច មានប្រភពពីកត្តាខាងក្រៅដែលអាចសាយភាយជាផលអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជា ដែលធ្វើឱ្យការព្យាករ ក៏ដូចជាក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចកម្ពុជាជារួមមានការផ្លាស់ប្តូរ និងបង្កជាផលប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាក្នុងកម្រិតមធ្យម ។ ហានិភ័យនេះមានលទ្ធភាពកើតមានឡើងក្នុងកម្រិតខ្ពស់ បង្កដោយកត្តាចម្បងៗចំនួន ៥ រួមមាន៖ (១). ការកើនឡើងកាន់តែខ្លាំងនៃចរន្តគាំពារនិយម ដែលនាំឱ្យមានការដំឡើងអត្រាពន្ធគយខ្ពស់ជាងការរំពឹងទុក និង/ឬ ការចរចារវាងកម្ពុជាសហរដ្ឋអាមេរិក ពុំទទួលបានលទ្ធផលគាប់ប្រសើរ; (២). ការហក់ឡើងវិញនៃថ្លៃទំនិញអន្តរជាតិ ដែលនាំឱ្យមានការកើនឡើងនូវសម្ពាធអតិផរណា; (៣). ការរឹតបន្តឹងឡើងវិញនៃគោលនយោបាយរូបិយវត្ថុសកលឆ្លើយតបទៅនឹងសម្ពាធអតិផរណា; (៤). ការថមថយកំណើនសេដ្ឋកិច្ចសកល និងចិន ដោយសារកម្មវិបាកនៃគោលនយោបាយគាំពារនិយម និង (៥). ភាពកាន់តែស្រួចស្រាល់នៃការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ។

ជារួម, ការកើនឡើងនូវគោលនយោបាយគាំពារនិយម (Protectionist policies), ជាពិសេស តាមរយៈការដំឡើងអត្រាពន្ធគយបដិការ បាននិងកំពុងបង្កើនភាពតានតឹងមួយកម្រិតថែមទៀត ដល់ស្ថានភាពពាណិជ្ជកម្ម និងដាក់សម្ពាធដល់ការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចសកល តាមរយៈការបង្កើនកំដៅដល់ភាពតានតឹងនៃភូមិសាស្ត្រសេដ្ឋកិច្ចតំបន់ និងសកល ។ កម្មវិបាកនៃគោលនយោបាយនេះ នឹងបន្តចំបង្អាក់ដល់លំហូរពាណិជ្ជកម្មសកល និងខ្សែច្រវាក់ផលិតកម្ម ដែលអាចនឹងជំរុញឱ្យមានការកើនឡើងវិញនូវសម្ពាធអតិផរណា ។ ជាលទ្ធផល, ការបន្ធូរបន្ថយគោលនយោបាយរឹតបន្តឹងរូបិយវត្ថុ នឹងត្រូវបន្ថយល្បឿន ឬ អាចចាប់ផ្តើមរឹតបន្តឹងមកវិញក្នុងករណីដែលសម្ពាធអតិផរណា ចាប់ផ្តើមហក់ឡើង ។ ក្នុងន័យនេះ, កំណើនសេដ្ឋកិច្ចសកល នឹងទទួលរងផលប៉ះពាល់ផ្ទួនគ្នា ពោលគឺចេញផលប៉ះពាល់ និងកម្មវិបាកនៃគោលនយោបាយគាំពារនិយម ផង និងផលជះស្តែងចេញពីការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកល ផង ។ ជាមួយគ្នានេះ, ការប្រែប្រួលអាកាសធាតុ និងព្រឹត្តិការណ៍គ្រោះធម្មជាតិ រួមមាន គ្រោះទឹកជំនន់, គ្រោះរាំងស្ងួត និងគ្រោះមហន្តរាយផ្សេងទៀត ក៏នឹងបង្កភាពរាំងស្ទះដល់សកម្មភាពសេដ្ឋកិច្ច និងបង្កការខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលជារួមបង្កជាបន្ទុកដល់ហិរញ្ញវត្ថុសាធារណៈ ។

**ប្រអប់ទី១៖ ការវិភាគវេទយិតភាពនៃការអនុវត្តគោលនយោបាយពន្ធគយបដិការ**

ការអនុវត្តគោលនយោបាយពន្ធគយបដិការរបស់សហរដ្ឋអាមេរិក បាននិងកំពុងបង្កជាកម្មវិបាកអវិជ្ជមាន ទៅលើនិន្នាការសេដ្ឋកិច្ចសកល និងតំបន់, រួមទាំងកម្ពុជាផងដែរ ដែលពេលនេះមិនទាន់មានស្ថាប័នណា អាចប៉ាន់ស្មានអំពីទំហំនៃផលប៉ះពាល់ជាក់លាក់នៅឡើយទេ ខណៈស្ថានការណ៍មានការវិវត្តលឿន ។ ដូចបានបញ្ជាក់ខាងលើ, កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានទម្លាក់ពី ៦,៣% ដែលត្រូវបានគិតគូរមុនការដាក់ចេញនូវគោលនយោបាយពន្ធគយបដិការនេះ មកត្រឹម ៥,២% និង ៥% រៀងគ្នាសម្រាប់ឆ្នាំ ២០២៥ និង ២០២៦ ។ បើទោះបីទស្សនវិស័យគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌនេះ បានគិតគូរពីផលប៉ះពាល់នៃការអនុវត្តគោលនយោបាយពន្ធគយបដិការមកលើសេដ្ឋកិច្ចកម្ពុជាក៏ពិតមែន, ប៉ុន្តែទំហំនៃផលប៉ះពាល់មកលើសេដ្ឋកិច្ចកម្ពុជា នៅតែមិនអាចវាស់វែងឱ្យបានជាក់លាក់នៅឡើយ ត្បិតមកទល់បច្ចុប្បន្ន, ស្ថានភាពនៃការអនុវត្តពន្ធគយបដិការនេះ នៅតែស្ថិតក្នុងភាពមិនប្រាកដប្រជាខ្ពស់ ហើយអាចវិវត្តទៅក្នុងទិសដៅអវិជ្ជមាន ឬ វិជ្ជមានហួសជាងការរំពឹងទុក ។ គួរបញ្ជាក់ឡើងវិញថា, ផលប៉ះពាល់ និងកម្មវិបាកនៃពន្ធគយបដិការ

មកលើសេដ្ឋកិច្ច គឺអាស្រ័យលើកត្តាសំខាន់ៗមួយចំនួន ដូចជា៖ (១). លទ្ធផលជាក់ស្តែងនៃការចរចារវាងកម្ពុជា ជាមួយនឹងសហរដ្ឋអាម៉េរិក; (២). អត្រាពន្ធដែលត្រូវបានអនុវត្ត ចំពោះបណ្តាប្រទេសផ្សេងៗដែលជាដៃគូប្រកួតប្រជែងរបស់កម្ពុជា; និង (៣). លទ្ធភាពនៃការបង្វែរច្រវាក់ផលិតកម្ម និងពាណិជ្ជកម្ម ជាដើម ។

ផលប៉ះពាល់លើសេដ្ឋកិច្ចកម្ពុជាអាចនឹងមានទំហំធំជាងនេះ ជាមួយនឹងសន្មតិថាការចរចារបស់កម្ពុជាជាមួយសហរដ្ឋអាម៉េរិក មិនទទួលបានលទ្ធផលប្រសើរដូចការរំពឹងទុក ដោយអត្រាពន្ធ ៤៩% នឹងត្រូវអនុវត្តបន្ទាប់ពីត្រូវបានពន្យារពេលចំនួន ៩០ ថ្ងៃ ហើយមានផលប៉ះពាល់ខ្លាំងទៅលើស្ថានភាពការនាំចេញរបស់កម្ពុជា ទៅកាន់សហរដ្ឋអាម៉េរិក ហើយឆ្នាំ ២០២៦ នឹងរងផលប៉ះពាល់ធ្ងន់ធ្ងរជាងឆ្នាំ ២០២៥ ។ **សម្រាប់សេណារីយ៉ូទាបនេះ ការនាំចេញរបស់កម្ពុជាជារួមអាចថមថយមកត្រឹម ៩,៨% និង ៨,៦% ខណៈកំណើនសេដ្ឋកិច្ចអាចនឹងថមថយមកត្រឹម ៤,៧% និង ៤,១% សម្រាប់ឆ្នាំ ២០២៥ និង ២០២៦ រៀងគ្នា ។** សម្រាប់ឆ្នាំ ២០២៧ និង ២០២៨ កំណើនសេដ្ឋកិច្ច អាចនឹងថមថយមកត្រឹមប្រមាណ ៥,០% និង ៥,៥% ។ ក្នុងនោះ វិស័យដែលមានការប្រែប្រួលខ្លាំងគួរឱ្យកត់សម្គាល់ រួមមាន៖ វិស័យកាត់ដេរ, កម្មន្តសាលមិនមែនកាត់ដេរ, ដឹកជញ្ជូន និងស្តុក និងលក់ដុំ-រាយ ។ ការនាំចេញសរុប (% ផ.ស.ស.) ជារួម នឹងថមថយ ដោយសារការ-ធ្លាក់ចុះការនាំចេញទៅសហរដ្ឋអាម៉េរិក ពោលទាំងការនាំចេញផលិតផលកាត់ដេរ និងមិនមែនកាត់ដេរ ។ ជាមួយគ្នានេះ, ការនាំចូលសរុប (% ផ.ស.ស.) ក៏នឹងថមថយផងដែរ ដោយសារការធ្លាក់ចុះការនាំចូល, ជាពិសេសការនាំចូលវត្ថុធាតុដើមបម្រើឱ្យវិស័យផលិតកម្ម (កាត់ដេរ និងមិនមែនកាត់ដេរ)។

ការថមថយនៃសេដ្ឋកិច្ច, ពិសេសការធ្លាក់ចុះនូវការនាំចេញរបស់កម្ពុជា, នឹងផ្តល់ជាកម្មវិបាកជាអវិជ្ជមានមកលើការប្រមូលចំណូលដោយផ្ទាល់ និងប្រយោល ។ ជាក់ស្តែង, ផលប៉ះពាល់ដោយផ្ទាល់ ត្រូវបានរំពឹងទុកថានឹងមានទំហំតូច ដោយសារ ប្រភេទចំណូល ដែលប៉ះពាល់ផ្ទាល់ នៅមានទំហំតូច នៅឡើយ ដូចជាពន្ធលើប្រាក់បៀវត្ស និងពន្ធកាត់ទុកផ្សេងៗ, ខណៈពន្ធពីការនាំចូលនាំចេញ និងពន្ធលើប្រាក់ចំណូល នៃសហគ្រាសស្ថិតក្នុងវិស័យរងផលប៉ះទង្គិចខ្លាំងទាំង ២ ខាងលើ ត្រូវបានទទួលការលើកទឹកចិត្តពន្ធស្ទើរតែទាំងស្រុងរួចទៅហើយ ។ ដោយឡែក, ផលប៉ះពាល់ដោយប្រយោល ត្រូវបានរំពឹងទុកថានឹងមានទំហំធំ ដែលក្នុងនោះពន្ធប្រយោលត្រូវបានរំពឹងទុកថានឹងមានការថមថយ ដោយសារតម្រូវការប្រើប្រាស់ជារួមមានការ-ថមថយ, ទាំងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងតម្រូវការនាំចូល, ខណៈចំណូលពីវិស័យផ្សេងៗ ដែលត្រូវបានរងផលប៉ះទង្គិចដោយប្រយោល ហើយជាប្រភពចំណូលធំ ក៏ត្រូវបានរំពឹងទុកថានឹងរងផលប៉ះពាល់ ដូចជាវិស័យដឹកជញ្ជូន និងស្តុក, វិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង និងវិស័យអចលនទ្រព្យ ជាមួយនឹងភាព-ទុទិដ្ឋិនិយម និងភាពស្រពេចស្រពិលនៃសកម្មភាពសេដ្ឋកិច្ច ។ បន្ថែមលើនេះ, មូលដ្ឋានពន្ធ ក៏អាចនឹងថមថយ ក្នុងករណីសេដ្ឋកិច្ចកម្ពុជា ត្រូវបានរងផលប៉ះទង្គិចខ្លាំងពីគោលនយោបាយពន្ធគយបដិការ ដែលការណ៍-នេះ នឹងធ្វើឱ្យកំណើនចំណូលក្នុងរយៈពេលមធ្យម ពុំអាចសម្រេចបានដូចការរំពឹងទុក ។

**ផ្អែកលើសេណារីយ៉ូនេះ កំណើនចំណូលចរន្តនឹងមានការថមថយមកត្រឹម ៤,៣% ក្នុងឆ្នាំ ២០២៥, សមមូលនឹង ៩៦,០% នៃច្បាប់ថវិកាឆ្នាំ ២០២៥ ទាបជាងក្របខ័ណ្ឌមូលដ្ឋាន ១,៣ ពិន្ទុភាគរយនៃច្បាប់ថវិកាឆ្នាំ ២០២៥ ។ សម្រាប់ឆ្នាំ ២០២៦, ចំណូលចរន្ត ក្នុងសេណារីយ៉ូនេះ ត្រូវបានវាយតម្លៃថានឹងមានកំណើនត្រឹម ៣,៩%, សមមូលនឹង ៩៩,៧% នៃច្បាប់ថវិកាឆ្នាំ ២០២៥ ទាបជាងក្របខ័ណ្ឌមូលដ្ឋាន ៣,៣ ពិន្ទុភាគរយនៃច្បាប់ថវិកាឆ្នាំ ២០២៥ ដែលនឹងដាក់សម្ពាធលើថវិកាកាន់តែខ្លាំងឡើង ។** ក្នុងករណីនេះ, រាជរដ្ឋាភិបាល អាចនឹងត្រូវដាក់ចេញ នូវវិធានការពង្រឹងប្រសិទ្ធភាពចំណាយ តាមរយៈការរឹតបន្តឹងចំណាយ

ដែលមានគោលការណ៍ស្រាប់ តែមិនជាចាំបាច់ខ្លាំង ឬ អាចពន្យារពេលអនុវត្តបាន នៅក្នុងឆ្នាំ ២០២៥ ។ បន្ថែម-លើនេះ, សម្រាប់កញ្ចប់ចំណាយសាធារណៈឆ្នាំ ២០២៦, រាជរដ្ឋាភិបាលនឹងត្រូវធ្វើវិចារណកម្មមុខចំណាយមួយចំនួន ធៀបនឹងការគ្រោងថវិកាខាងលើ រួមមាន៖ (១). រក្សាចំណាយតាមវិស័យត្រឹមកម្រិតស្មើច្បាប់ថវិកាឆ្នាំ ២០២៥; (២). រក្សាចំណាយចរន្តក្រៅបន្ទុកបុគ្គលិកក្នុងការអនុវត្តគម្រោងត្រឹមកម្រិតស្មើច្បាប់ថវិកាឆ្នាំ ២០២៥; និង (៣). តម្រូវឱ្យប្រើប្រាស់ប្រាក់បញ្ញើរាជរដ្ឋាភិបាលប្រមាណ ៦០ លានដុល្លារអាម៉េរិក ដើម្បីបំពេញឱនភាព ។

## ខ. ភាពជាដៃគូរវាងរដ្ឋ និងឯកជន

គម្រោងការអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (Public-Private Partnerships - PPP) សំដៅដល់គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និង/ឬ គម្រោងផ្តល់សេវាសាធារណៈ ដែលអនុវត្តក្រោមក្របខ័ណ្ឌកិច្ចសន្យា PPP រវាងភាគីរដ្ឋ និងឯកជន ដោយដៃគូឯកជនត្រូវធ្វើការវិនិយោគ ទទួលបន្ទុកហានិភ័យមួយចំណែក និងទទួលអត្ថប្រយោជន៍ផ្អែកលើសមិទ្ធកម្ម និងលក្ខខណ្ឌនៃកិច្ចសន្យា ។ ជារួម, គម្រោង PPP អាចបង្កើតជាហានិភ័យតាមរយៈកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ ២ ប្រភេទដល់រាជរដ្ឋាភិបាល៖ **(១) កាតព្វកិច្ចហិរញ្ញវត្ថុដោយផ្ទាល់** ដែលបច្ចុប្បន្ន រាជរដ្ឋាភិបាលពុំទាន់មាននៅឡើយ; និង **(២) កាតព្វកិច្ចបំណុលយថាហេតុ** ។ ក្នុងនោះ, ការទាមទារទូទាត់លើការធានារបស់រដ្ឋ ឬ ការរំលាយកិច្ចសន្យាមុនកាលកំណត់ អាចបង្កើតជា កាតព្វ-កិច្ចបំណុលយថាហេតុ ដែលអាចបង្កជាសម្ពាធដល់ស្ថិរភាពហិរញ្ញវត្ថុសាធារណៈ ។ កាតព្វកិច្ចនេះក៏អាចកើតមានឡើង ក្នុងលក្ខខណ្ឌការអនុវត្តកិច្ចសន្យារបស់ដៃគូមានភាពរាំងស្ទះដោយសារកត្តាណាមួយ រួមមាន សកម្មភាពរបស់រាជរដ្ឋាភិបាល, ការផ្លាស់ប្តូរច្បាប់ និងហានិភ័យប្រធានសក្តិ, ជាពិសេស ប្រធានសក្តិខាងនយោបាយ ជាដើម ។

សម្រាប់កម្ពុជា, គម្រោង PPP មានទំហំប្រមាណ ៣៩% នៃផ.ស.ស. ។ បើទោះជា គម្រោង PPP នៅកម្ពុជា ហាក់មានទំហំធំធៀបនឹងទំហំសេដ្ឋកិច្ច, ហានិភ័យនេះ មានលទ្ធភាពកើតឡើងក្នុងកម្រិតទាប និងមានទំហំផលប៉ះពាល់ក្នុងកម្រិតទាប នៅឡើយ ដោយមួយចំនួនធំនៃគម្រោង PPP ជាគម្រោងដែលអាចរកប្រាក់ចំណូលបាន (Revenue generated project) ហើយគម្រោងមួយចំនួននៃគម្រោង PPP តម្រូវឱ្យរាជរដ្ឋា-ភិបាលទូទាត់ថ្លៃសេវាផ្អែកលើថវិការដ្ឋ (Availability Payment) ជាប្រចាំ ប៉ុណ្ណោះ ។ ក្នុងលក្ខខណ្ឌដែលរាជ-រដ្ឋាភិបាលមិនអាចប្រមូលកម្រៃគ្រប់គ្រាន់សម្រាប់ការទូទាត់ពីអ្នកប្រើប្រាស់ ក៏កាតព្វកិច្ចទូទាត់គម្រោងនេះ ស្ថិតក្នុងទំហំទឹកប្រាក់អាចគ្រប់គ្រងបាន និងមិនបង្កហានិភ័យដល់ស្ថិរភាពហិរញ្ញវត្ថុសាធារណៈ នៅឡើយ ។

បន្ថែមលើនេះ, គម្រោង PPP ដែលបាននិងកំពុងអនុវត្ត គឺមិនទទួលបានការធានាក្នុងទម្រង់ណាមួយឡើយ លើកលែងតែគម្រោង PPP ក្នុងវិស័យថាមពលចំនួនប្រមាណ ៣៨ គម្រោងប៉ុណ្ណោះ ដែលរាជរដ្ឋាភិបាលបានធានាទូទាត់ ក្នុងករណី អគ្គិសនីកម្ពុជា (EDC) ពុំមានលទ្ធភាពទូទាត់ជូនដៃគូឯកជន ។ ដោយឡែក, ផ្អែកតាមការអនុវត្តរបស់ EDC កន្លងមក រាជរដ្ឋាភិបាលពុំដែលបានទូទាត់សងទៅដៃគូឯកជនជំនួស EDC ឡើយ ហើយ EDC ក៏បន្តមានសមត្ថភាពហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការរ៉ាប់រង និងទូទាត់ជាមួយដៃគូឯកជនផងដែរ ។

ជាមួយគ្នានេះ, ក្រោមអធិការកិច្ចរបស់អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រាល់គម្រោង PPP ដែលបានអនុម័តបន្ទាប់ពីច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន ចូលជាធរមាន គឺតម្រូវឱ្យមានការសិក្សាសមិទ្ធិលទ្ធភាពរបស់គម្រោង ដែលជាការសិក្សាលើគ្រប់ទិដ្ឋភាព រួមទាំងទិដ្ឋភាពហិរញ្ញវត្ថុ, ទំហំនៃការគាំទ្រពីរាជរដ្ឋាភិបាល, ព្រមទាំងកំណត់នូវហានិភ័យរបស់គម្រោង និងយន្តការបញ្ចៀស

ហានិភ័យទាំងនោះ មុននឹងសម្រេចអនុវត្តក្រោមយន្តការ PPP ។ លើសពីនេះ, ដើម្បីត្រៀមលក្ខណៈកាត់បន្ថយការប៉ះទង្គិចពីហានិភ័យបំណុលយថាហេតុ, រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគោលនយោបាយមួយចំនួន រួមមាន៖ (១). ការចាប់ផ្ដើមអនុវត្តមូលនិធិបម្រុងហិរញ្ញវត្ថុ; (២). ការកំណត់ពិតាននៃការធានាទូទាត់សរុបប្រចាំឆ្នាំចំពោះគម្រោងថ្មី មិនលើសពី **១០%** នៃចំណូលថវិកាជាតិនាឆ្នាំកន្លងទៅ; (៣). ការបន្តមិនផ្តល់ការធានាឥណទាន (Credit/Loan Guarantee) ដោយផ្ទាល់ពីរដ្ឋចំពោះវិស័យឯកជន; (៤). ការប្រើប្រាស់យន្តការស្ថាប័នសម្រាប់ការគ្រប់គ្រងគម្រោង ដើម្បីទប់ស្កាត់ និងបញ្ចៀសផលប៉ះពាល់ ដែលអាចកើតមានឡើងពីគម្រោង រួមមាន ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន នីតិវិធីគ្រប់គ្រងប្រតិបត្តិការសម្រាប់គម្រោង; និង (៥). ការតាមដានជាប្រចាំ និងការពង្រឹងការអនុវត្តច្បាប់ និងយន្តការពាក់ព័ន្ធនានា ។

### គ. ហានិភ័យបំណុលរបស់រដ្ឋាភិបាល

ហានិភ័យបំណុលរបស់រដ្ឋាភិបាល មានលទ្ធភាពកើតឡើងក្នុងកម្រិតបញ្ចប ក្នុងរូបភាពជាការកើនឡើងបន្ទុកបំណុល និងបន្ទុកចំណាយបន្ថែម ហើយបង្កជាសម្ពាធដល់ថវិកាជាតិ រួមមាន ការកើននៃថ្លៃដើមហិរញ្ញប្បទាន តាមរយៈការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ ជាដើម ។ ជាមួយគ្នានេះ, ការត្រៀមខ្លួនចាកចេញពីក្រុមប្រទេសអភិវឌ្ឍតិចតួច (LDC) របស់កម្ពុជា អាចនឹងនាំឱ្យបាត់បង់ថែមទៀតនូវប្រភពហិរញ្ញប្បទានដែលមានកម្រិតសម្បទានខ្ពស់ ខណៈប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិមានការរួមតូច ព្រមទាំងការធ្លាក់ចុះនៃជំនួយហិរញ្ញប្បទានឥតសំណង ដែលអាចធ្វើឱ្យឱនភាពថវិកាមានការរីកធំ ។

ទោះជាយ៉ាងនេះក្តី, ហានិភ័យបំណុលនេះមានទំហំផលប៉ះពាល់ក្នុងកម្រិតទាប នៅឡើយ និងនៅតែបន្តរក្សាបាននូវចីរភាព សម្រាប់រយៈពេលខ្លី និងមធ្យមខាងមុខ ។ ក្នុងឆ្នាំ ២០២៤ (ប៉ាន់ស្មាន) សន្និធិបំណុលសាធារណៈមានទំហំប្រមាណ ១៩,៣% នៃផ.ស.ស. និងជាមធ្យមប្រមាណ ១៩,២% នៃផ.ស.ស. សម្រាប់ឆ្នាំ ២០២៥-២០២៧ ដែលជាលម្អធំធៀបនឹងអនុបាតគោល ៥៥% នៃផ.ស.ស. (តម្លៃបច្ចុប្បន្ន) ។ ជាមួយគ្នានេះ, ហានិភ័យបំណុល បន្តទទួលបានការយកចិត្តទុកដាក់ខ្ពស់ តាមរយៈការអនុវត្តយន្តការតាមដាន, ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង/កម្មវិធីក្រោមក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ និងមូលនិធិទ្រទ្រង់ថវិកា, ពិសេសការអនុវត្តគោលការណ៍ និងវិធានការគន្លឹះ ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាលក្នុង **«យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤-២០២៨»** ។

### ឃ. ហានិភ័យពីសហគ្រាសសាធារណៈ និងការវិនិយោគសាធារណៈ

ហានិភ័យពីសហគ្រាសសាធារណៈ អាចកើតឡើងក្នុងករណីភាពមិនច្បាស់លាស់នៃលក្ខខណ្ឌសេដ្ឋកិច្ច និងនយោបាយអន្តរជាតិ និងក្នុងស្រុក ដែលអាចធ្វើឱ្យមានប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុ ក៏ដូចជាលទ្ធភាពសងរបស់ឥណាយិក មករាជរដ្ឋាភិបាលវិញ ។ ការណ៍នេះទាមទារឱ្យមានការពិនិត្យឡើងវិញ និងកែសម្រួលប្រកាសស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងការផ្តល់ឥណទានរបស់រដ្ឋ ដល់គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ ក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឱ្យស្របតាមបរិការណ៍ជាក់ស្តែង តាមការចាំបាច់ ព្រមទាំងសិក្សារៀបចំយន្តការវាយតម្លៃឥណាយិក និងពង្រឹងការតាមដានស្ថានភាពហិរញ្ញវត្ថុ និងអាជីវកម្មរបស់ឥណាយិកជាប្រចាំ ។ ជាលទ្ធផលនៃការវាយតម្លៃ, ហានិភ័យពីសហគ្រាសសាធារណៈ មានលទ្ធភាពកើតឡើងក្នុងកម្រិតទាប និងមានទំហំនៃផលប៉ះពាល់ក្នុងកម្រិតទាបនៅឡើយ ដោយសហគ្រាសសាធារណៈមានស្វ័យភាពលើហិរញ្ញវត្ថុ, ការងារ និងការគ្រប់គ្រងរបស់

ខ្លួន ខណៈបច្ចុប្បន្នពុំទាន់មានសហគ្រាសសាធារណៈណាមួយទទួលលទ្ធផលខូចខាតធ្ងន់ធ្ងរនៅឡើយ ហើយសកម្មភាពកម្ចីរបស់សហគ្រាសសាធារណៈ ក៏ស្ថិតក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផងដែរ ពោលគឺសហគ្រាសសាធារណៈពុំមានសិទ្ធិស្នើសុំកម្ចីដោយផ្ទាល់ពីដៃគូអភិវឌ្ឍន៍ នោះទេ ។

ជាមួយគ្នានេះ, ហានិភ័យពីការវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ អាចកើតមានឡើងដោយការខូចខាតទ្រព្យសម្បត្តិ ឬ ការពន្យារពេល ក្នុងការអនុវត្តគម្រោងវិនិយោគ ។ សម្រាប់បរិការណ៍កម្ពុជា, គម្រោងវិនិយោគដែលប្រើប្រាស់ថវិកាជាតិជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) មានលំនាំត្រឹមជាគម្រោងជួស-ជុល និងការស្តារឡើងវិញ ព្រមទាំងការលើកកម្ពស់កម្រិតគុណភាពហេដ្ឋារចនាសម្ព័ន្ធ ដែលបានវិនិយោគដោយថវិកាដៃគូអភិវឌ្ឍន៍ក្នុងរយៈពេល ២ ឬ ៣ ទសវត្សរ៍កន្លងមក ។ ឈរលើមូលដ្ឋាននេះ, ហានិភ័យពីការវិនិយោគសាធារណៈ ត្រូវបានវាយតម្លៃថា មានលទ្ធភាពកើតឡើងក្នុងកម្រិតទាប និងមានទំហំនៃផលប៉ះពាល់ក្នុងកម្រិតទាប ។ បើទោះជាយ៉ាងនេះក្តី, ក្នុងករណីជួបប្រទះនឹងគ្រោះធម្មជាតិ ឬ កត្តាសត្យានុម័តណាមួយ ដែលធ្វើឱ្យខូច-ខាតដល់ហេដ្ឋារចនាសម្ព័ន្ធ ស្របពេលដែលសម្ពាធថវិកាពុំទាន់មានភាពធូរស្រាល, ហានិភ័យនេះ អាចនឹងមានការកើនឡើងពីកម្រិតទាប ទៅកម្រិតមធ្យម ។

## ង. ហានិភ័យពីវិស័យហិរញ្ញវត្ថុ

ហានិភ័យពីវិស័យហិរញ្ញវត្ថុ សំដៅដល់ការកើតមានវិបត្តិហិរញ្ញវត្ថុ នៃគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ ដែលអាចបង្កើតជាកាតព្វកិច្ចបំណុលដោយផ្ទាល់ និងប្រយោល និងបង្កើនចំណាយរបស់រាជរដ្ឋាភិបាល ។ ក្នុងករណីវិស័យហិរញ្ញវត្ថុមានវិបត្តិ, រាជរដ្ឋាភិបាលត្រូវបាត់បង់ប្រាក់ចំណូលជាតិ និងបង្កើនចំណាយមួយផ្នែកធំ ក្នុងន័យរក្សាស្ថិរភាពសង្គម-សេដ្ឋកិច្ច ពិសេសផ្តល់ការគាំទ្រដល់ស្ថាប័នហិរញ្ញវត្ថុដែលមានវិបត្តិ ដែលការណ៍នេះនឹងបង្កបានជាសម្ពាធក្នុងកម្រិតខ្ពស់ដល់ស្ថិរភាពហិរញ្ញវត្ថុសាធារណៈ ។ ក្នុងន័យនេះ, ការប្រែប្រួលក្នុងវិស័យហិរញ្ញវត្ថុមានផលជះខ្ពស់ដល់ស្ថានភាពហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា, ទាំងដោយផ្ទាល់ និងដោយប្រយោល, តាមរយៈឥទ្ធិពលសាយភាយ (Spillover effect) ដល់សកម្មភាពរស់នៅរបស់ប្រជាពលរដ្ឋ ក៏ដូចជាវិស័យដទៃទៀត ។

សម្រាប់រយៈពេលមធ្យមខាងមុខ, ហានិភ័យពីវិស័យហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា មានលទ្ធភាពកើតឡើងក្នុងកម្រិតមធ្យម ដែលបានឆ្លុះបញ្ចាំងតាមរយៈនិន្នាការកើននៃឥណទានមិនដំណើរការជាបន្តបន្ទាប់ ។ វិស័យហិរញ្ញវត្ថុ គឺជាវិស័យដ៏សំខាន់ ដែលទទួលបានការយកចិត្តទុកដាក់ខ្ពស់ និងស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ជាអាជ្ញាធររូបិយវត្ថុ មានតួនាទីត្រួតពិនិត្យប្រព័ន្ធធនាគារ, រក្សាស្ថិរភាពរូបិយវត្ថុ និងបានកំណត់គោលនយោបាយរូបិយវត្ថុជាបន្តបន្ទាប់ ប្រកបដោយប្រសិទ្ធភាព និងភាពប្រុងប្រយ័ត្នខ្ពស់ ។

## ច. ភាពជឿទុកចិត្តបាននៃក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ

ស្ថានភាពមិនប្រាកដប្រជាខ្ពស់នៃសេដ្ឋកិច្ចសកល និងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃនិន្នាការតម្រូវការ (demand trend) ក្នុងស្រុក បានបន្តបង្កើតជាបញ្ហាប្រឈមដល់ការប៉ាន់ស្មានការប្រមូលចំណូល និងលទ្ធផលនៃការប្រមូលចំណូលជាក់ស្តែង ។ ស្របគ្នានេះ, រាជរដ្ឋាភិបាល បាននិងកំពុងដាក់ចេញនូវគោលនយោបាយទ្រទ្រង់ជាបន្តបន្ទាប់ រួមមាន ការកាត់បន្ថយអត្រា និងការអនុគ្រោះពន្ធ ដែលការណ៍ទាំងនេះ បង្កឱ្យការប្រមូលចំណូលអាចនឹងមិនសម្រេចបានដូចទៅតាមការគ្រោង និងនាំឱ្យមានការថមថយនូវលទ្ធភាពទ្រទ្រង់ចំណាយសាធារណៈ ដែលបានគ្រោង ។ បន្ថែមលើនេះ, ភាពមានកម្រិតក្នុងការប្រមូលចងក្រងទិន្នន័យ, ទាំងគុណភាព,

វិសាលភាព និង ភាពទាន់ពេល, និងកត្តាសមត្ថភាពមន្ត្រីជំនាញ ក៏អាចចូលរួមបង្កឱ្យមានចន្លោះប្រហោងជាប្រព័ន្ធក្នុងការវិភាគ និងព្យាករក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ផងដែរ ។ ជារួម, ហានិភ័យនេះមានផលជះក្នុងកម្រិតមធ្យមដល់ស្ថិរភាពហិរញ្ញវត្ថុសាធារណៈ និងមានលទ្ធភាពកើតឡើងក្នុងកម្រិតមធ្យម ។ ដើម្បីអាចកាត់បន្ថយទាំងកម្រិតផលប៉ះពាល់ និងភាពអាចកើតឡើងនៃហានិភ័យនេះ, រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើវិធានការមួយចំនួន រួមមាន៖ (១). ការបន្តតាមដានប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ លើការប្រែប្រួលនៃលក្ខខណ្ឌសេដ្ឋកិច្ច និងសង្គម; (២). ការអភិវឌ្ឍធនធានមនុស្ស សំដៅបង្កើនភាពទុកចិត្តបានក្នុងការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ; និង (៣). ការពង្រឹងតួនាទីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាស្ថាប័នត្រួតពិនិត្យកណ្តាល (Central Oversight Body) ដើម្បីជួយសម្រួលដល់ការប្រមូល, ត្រួតពិនិត្យ និងគ្រប់គ្រងទិន្នន័យ ទន្ទឹមនឹងការប្រមូលផ្តុំធាតុចូលអន្តរកម្មពីភាគីពាក់ព័ន្ធ ដើម្បីពង្រឹងភាពធន់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

## ៦. សេចក្តីសន្និដ្ឋាន

**«ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៦-២០២៨»** ឬ **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨** ត្រូវបានរៀបចំឡើងយ៉ាងគត់មត់ អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២០០៤-២០២៥ ក៏ដូចជា **យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាបច្ចុប្បន្នកម្ម ឆ្នាំ ២០២៥-២០២៨** ។ **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨** ត្រូវបានរៀបចំក្នុងគោលបំណងរួមចំនួន ៣ គឺ ៖ (១). ជំរុញប្រសិទ្ធភាព និងតម្លាភាពថវិកា, ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ, សំដៅធានាចីរភាពហិរញ្ញវត្ថុសាធារណៈ; (២). ពង្រឹងភាពធន់សង្គម-សេដ្ឋកិច្ច ដែលមានលទ្ធភាពឆ្លើយតបបានរហ័សទៅនឹងវិបត្តិ នាពេលអនាគត; និង (៣). ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ដើម្បីជំរុញសម្ទុះនៃការអភិវឌ្ឍជាតិ ប្រកបដោយចីរភាព និងបរិយាប័ន្ន និងសំដៅសម្រេចឱ្យបាននូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ។

ផ្អែកលើស្ថានភាពនាពេលថ្មីៗនេះ, កំណើនសេដ្ឋកិច្ចជាតិរយៈពេលមធ្យម (២០២៦-២០២៨) រំពឹងថានឹងមានភាពថមថយបន្តិច មកនៅក្នុងអត្រាជាមធ្យម ៥,៤% ជាមួយនឹងអត្រាអតិផរណាក្នុងកម្រិតអាចគ្រប់គ្រងបាន, ក្នុងរង្វង់ ២,៥%, និងការរក្សាបាននូវស្ថិរភាពអត្រាប្តូរប្រាក់ ក្នុងរង្វង់ ៤ ០៦០ រៀល/ដុល្លារអាម៉េរិក ។ ទោះបីជា កម្ពុជា កំពុងទទួលផលលាភពីសន្តិភាព និង ស្ថិរភាពនយោបាយក្នុងប្រទេស ហើយសេដ្ឋកិច្ច ក៏កំពុងងើបឡើងវិញ និងត្រឡប់ទៅរកភាពប្រក្រតីក្រោយវិបត្តិនៃជំងឺកូវីដ-១៩ ក្តី, ក៏ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជាកំពុងត្រូវបានបន្តហ៊ុមព័ទ្ធដោយហានិភ័យ និង ភាពមិនប្រាកដប្រជាខ្ពស់, ពិសេសពីកត្តាខាងក្រៅ, ដែលលេចរូបរាងកាន់តែច្បាស់ រួមមាន៖ ភាពមិនប្រាកដប្រជាខ្ពស់ និង បញ្ហាប្រឈមនៃភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ចកាន់តែស្រួចស្រាល់ ព្រមទាំង ផលប៉ះពាល់កាន់តែធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ និង គ្រោះធម្មជាតិ ដែលហានិភ័យទាំងអស់នេះ ពុំចំណុះនឹងការគ្រប់គ្រងរបស់កម្ពុជានោះឡើយ ។

ក្នុងបរិបទនេះ, គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រយៈពេលមធ្យមខាងមុខ ត្រូវបានរៀបចំឡើងដោយប្រកាន់យកនូវការបន្តអនុវត្ត **«ជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន»** ដើម្បីធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈពេលមធ្យម ដោយផ្តោតជាសំខាន់ លើការបន្តពង្រឹងប្រសិទ្ធភាពថវិកា, ទាំងកម្រិតវិភាជន៍ និង កម្រិតប្រតិបត្តិការ និង ដោយតម្រង់ទិសធនធានទៅកាន់មុខសញ្ញា

ចំណាយដែលជាអាទិភាពចំពោះមុខ ព្រមជាមួយនឹងការខិតខំពង្រឹងការប្រមូលចំណូល ឱ្យកាន់តែប្រសើរ ដោយមានការថ្លឹងថ្លែងជាមួយនឹងការបន្តរក្សាឱ្យបាននូវចលនការ និង សម្ទុះនៃសកម្មភាពសេដ្ឋកិច្ច ហើយខិតខំចៀសវាងឱ្យបានជាអតិបរមានូវវិការភាពសេដ្ឋកិច្ច (economic distortion) ។ **ជាមួយនឹងការគិតគូរនេះ, ការ-ប្រមូលចំណូលចរន្តត្រូវបានគ្រោងថានឹងមានកំណើនជាមធ្យម ក្នុងរង្វង់ ៧,០% សម្រាប់ឆ្នាំ ២០២៦-២០២៨ ដែលក្នុងនោះ សម្រាប់ឆ្នាំ ២០២៦ មានកំណើន ៥,៩%, សមមូលនឹង ១៤,១៣% នៃ ផ.ស.ស. ។ ចំណាយសាធារណៈសរុប ត្រូវបានរំពឹងថានឹងមានកំណើនជាមធ្យម ៤,៦% ក្នុងមួយឆ្នាំ ដែលក្នុងនោះ ចំណាយចរន្តសម្រាប់ឆ្នាំ ២០២៦ មានកំណើនប្រមាណ ២,៥%, សមមូលនឹង ១២,០៥% នៃ ផ.ស.ស. ។ ជាលទ្ធផល, ឱនភាពថវិកានឹងថមថយមកត្រឹមរង្វង់ -២,២០% នៃ ផ.ស.ស. ជាមធ្យម សម្រាប់ឆ្នាំ ២០២៦-២០២៨ ដែលក្នុងនោះ សម្រាប់ឆ្នាំ ២០២៦ មានទំហំប្រមាណ -២,១៩% នៃ ផ.ស.ស. ។** ជាលទ្ធផល, ស្ថានភាពហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ត្រូវបានវាយតម្លៃថា នឹងនៅតែបន្តមានភាពរឹងមាំ និងប្រកបដោយចីរភាព ដោយអនុលោមបានទៅតាមវិធានហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញ ។ ក្របខ័ណ្ឌនេះ ក៏នឹងក្លាយជាមូលដ្ឋានសម្រាប់ការរៀបចំនូវ «**ក្របខ័ណ្ឌថវិការយៈពេលមធ្យម ២០២៦-២០២៨**» និង «**សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦**» ។

ជាការសន្និដ្ឋានរួម, ស្ថិតក្នុងបរិការណ៍មិនច្បាស់លាស់ទាំងអស់នេះ, រាជរដ្ឋាភិបាល នឹងបន្តខិតខំពង្រីក និងបន្តពង្រឹងមូលដ្ឋានខាងក្នុងឱ្យកាន់តែមានភាពប្រកួតប្រជែង ដើម្បីស្រូប និង ទាញយកប្រយោជន៍ពីកាលានុវត្ត-ភាពថ្មីៗទាំងនោះ ក៏ដូចជាបន្តកសាងភាពធន់នៃសង្គម-សេដ្ឋកិច្ច ដើម្បីអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការ-បញ្ចៀសហានិភ័យដែលនឹងកើតឡើងក្នុងពេលខាងមុខ ជាយថាហេតុ ។ រាជរដ្ឋាភិបាល នឹងបន្តតាមដានការវិវត្តនៃស្ថានការណ៍ និងវាយតម្លៃឡើងវិញពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នៅពាក់កណ្តាលឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំ **សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦** ។ ក្នុងស្ថានភាពដែលមានការវិវត្តប្រសើរ, រាជរដ្ឋាភិបាលនឹងបន្តប្រើប្រាស់ក្របខ័ណ្ឌនេះ ។ ក្នុងករណីស្ថានការណ៍កាន់តែអាក្រក់, រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពកែសម្រួលក្របខ័ណ្ឌនេះតាមស្ថានភាពជាក់ស្តែង ក្នុងន័យធានាឱ្យបាននូវភាព-ជឿទុកចិត្តបាននៃថវិកា និងឆ្លុះបញ្ចាំងពីស្ថានភាពពិត ។ ទន្ទឹមនឹងនេះ, រាជរដ្ឋាភិបាល នឹងបន្តត្រៀមខ្លួនប្រកបដោយស្មារតីប្រុងប្រយ័ត្ន, បុរេសកម្ម និងបត់បែនខ្ពស់ ក្នុងការរៀបចំ និង ដាក់ចេញនូវគោលនយោបាយ និងវិធានការអន្តរាគមន៍ សំដៅឆ្លើយតប និង សម្របតាមការវិវត្តនូវសភាពការណ៍ ឱ្យបានទាន់ពេល និងកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ក៖ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២២-២០២៨

| សូចនាករ | ២០២២ | ២០២៣ | ២០២៤ប | ២០២៥ព្យ | ២០២៦ព្យ | ២០២៧ព្យ | ២០២៨ព្យ |
|---|---|---|---|---|---|---|---|
| ផ.ស.ស. ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | 164,059 | 177,351 | 191,862 | 206,396 | 221,669 | 239,207 | 258,930 |
| ផ.ស.ស. សម្រាប់ម្នាក់ (ដុល្លារអាមេរិក) | 2,383 | 2,525 | 2,719 | 2,896 | 3,071 | 3,272 | 3,497 |
| កំណើន ផ.ស.ស. ពិត (%) | 5.1% | 5.0% | 6.0% | 5.2% | 5.0% | 5.5% | 5.8% |
| អត្រាបរិត្តផរណា ផ.ស.ស. (កំណើនប្រចាំឆ្នាំ) | 3.5% | 3.0% | 2.0% | 2.2% | 2.3% | 2.3% | 2.3% |
| អត្រាអតិផរណា (កំណើនជាមធ្យមប្រចាំឆ្នាំ) | 5.3% | 2.1% | 0.8% | 3.0% | 2.1% | 2.5% | 2.5% |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារអាមេរិក) | 4,087 | 4,110 | 4,070 | 4,054 | 4,052 | 4,050 | 4,050 |
| ការនាំចេញ (%នៃ ផ.ស.ស.) | 57.7% | 54.6% | 56.8% | 59.0% | 61.2% | 63.9% | 67.1% |
| ការនាំចូល (%នៃ ផ.ស.ស.) | -79.7% | -61.5% | -66.3% | -69.8% | -72.6% | -76.7% | -81.2% |
| សមតុល្យពាណិជ្ជកម្ម (%នៃ ផ.ស.ស.) | -22.0% | -6.9% | -9.5% | -10.8% | -11.4% | -12.9% | -14.1% |
| សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) (%នៃ ផ.ស.ស.) | -18.9% | 1.3% | 0.5% | -1.0% | -1.6% | -2.8% | -3.9% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | 17,805 | 19,998 | 22,511 | 24,450 | 26,336 | 28,299 | 30,125 |
| ចំនួនខែនៃការនាំចូល | 6.1 | 8.2 | 9.6 | 7.6 | 7.3 | 6.9 | 6.4 |

*ប្រភព៖ ធនាគារជាតិនៃកម្ពុជា (វិស័យខាងក្រៅឆ្នាំ ២០២៤) និងការព្យាករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ឧបសម្ព័ន្ធ ខៈ ក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ឆ្នាំ ២០២៤-២០២៨

## ខ១. ជាប៊ីលានរៀល

| សូចនាករ | 2024ប. | 2025ច្ប. | 2025កែ. | 2026ព្យ. | 2027ព្យ. | 2028ព្យ. |
|---|---|---|---|---|---|---|
| **ចំណូលសរុប** | **29,151** | **31,598** | **30,764** | **32,441** | **34,642** | **37,353** |
| **ចំណូលចរន្តសរុប** | **27,983** | **30,389** | **29,555** | **31,313** | **33,501** | **36,196** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 10,448 | 10,146 | 11,108 | 11,622 | 12,311 | 13,173 |
| អគ្គនាយកដ្ឋានពន្ធដារ | 14,023 | 16,272 | 14,493 | 15,360 | 16,386 | 17,664 |
| ចំណូលមិនមែនសារពើពន្ធ | 3,511 | 3,971 | 3,954 | 4,331 | 4,804 | 5,358 |
| **ចំណូលផ្សេងៗ** | **1,168** | **1,209** | **1,209** | **1,128** | **1,141** | **1,157** |
| **ចំណាយសរុប** | **34,701** | **37,950** | **37,950** | **37,305** | **39,647** | **43,356** |
| **ចំណាយចរន្តសរុប** | **24,068** | **26,054** | **26,054** | **26,702** | **28,325** | **29,699** |
| បន្ទុកបុគ្គលិក | 11,015 | 11,514 | 11,514 | 11,788 | 12,283 | 12,799 |
| បន្ទុកមិនមែនបុគ្គលិក | 13,052 | 14,540 | 14,540 | 14,914 | 16,042 | 16,900 |
| **ចំណាយមូលធនសរុប** | **10,633** | **11,896** | **11,896** | **10,603** | **11,321** | **13,657** |
| ហិរញ្ញប្បទានក្នុងប្រទេស | 4,425 | 5,025 | 5,025 | 3,553 | 4,090 | 5,369 |
| ហិរញ្ញប្បទានក្រៅប្រទេស | 6,208 | 6,871 | 6,871 | 7,050 | 7,231 | 8,289 |
| **អតិរេកចរន្ត** | **3,915** | **4,335** | **3,500** | **4,611** | **5,176** | **6,497** |
| **ឱនភាពថវិកា** | **-5,550** | **-6,352** | **-7,187** | **-4,864** | **-5,005** | **-6,004** |

## ខ២. កំណើនប្រចាំឆ្នាំ

| សូចនាករ | 2024ប. /2023 | 2025ច្ប. /2024ប. | 2025កែ. /2024ប. | 2026ព្យ. /2025ព្យ. | 2027ព្យ. | 2028ព្យ. |
|---|---|---|---|---|---|---|
| **ចំណូលសរុប** | **0.81%** | **8.40%** | **5.53%** | **5.45%** | **6.78%** | **7.82%** |
| **ចំណូលចរន្តសរុប** | **3.50%** | **8.60%** | **5.62%** | **5.95%** | **6.99%** | **8.04%** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 13.30% | -2.89% | 6.32% | 4.62% | 5.93% | 7.00% |
| អគ្គនាយកដ្ឋានពន្ធដារ | -3.95% | 16.04% | 3.35% | 5.98% | 6.68% | 7.80% |
| ចំណូលមិនមែនសារពើពន្ធ | 9.26% | 13.08% | 12.59% | 9.55% | 10.93% | 11.53% |
| **ចំណូលផ្សេងៗ** | **-85.66%** | **3.51%** | **3.51%** | **-6.68%** | **1.12%** | **1.38%** |
| **ចំណាយសរុប** | **-7.23%** | **9.36%** | **9.36%** | **-0.92%** | **6.28%** | **9.36%** |
| **ចំណាយចរន្តសរុប** | **4.40%** | **8.25%** | **8.25%** | **3.68%** | **6.08%** | **4.85%** |
| បន្ទុកបុគ្គលិក | 4.14% | 4.53% | 4.53% | 2.38% | 4.20% | 4.20% |
| បន្ទុកមិនមែនបុគ្គលិក | 4.62% | 11.40% | 11.40% | 4.72% | 7.56% | 5.35% |
| **ចំណាយមូលធនសរុប** | **-25.92%** | **11.88%** | **11.88%** | **-10.87%** | **6.78%** | **20.63%** |
| ហិរញ្ញប្បទានក្នុងប្រទេស | -35.21% | 13.55% | 13.55% | -29.29% | 15.11% | 31.25% |
| ហិរញ្ញប្បទានក្រៅប្រទេស | 5.83% | 10.69% | 10.69% | 2.59% | 2.57% | 14.63% |

## ខ៣. ជាភាគរយនៃ ផ.ស.ស.

| សូចនាករ | 2024ប. | 2025ច្បា. | 2025កែ. | 2026ព្យ. | 2027ព្យ. | 2028ព្យ. |
|---|---|---|---|---|---|---|
| ចំណូលសរុប | 15.19% | 15.31% | 14.91% | 14.63% | 14.48% | 14.43% |
| ចំណូលចរន្តសរុប | 14.58% | 14.72% | 14.32% | 14.13% | 14.01% | 13.98% |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 5.45% | 4.92% | 5.38% | 5.24% | 5.15% | 5.09% |
| អគ្គនាយកដ្ឋានពន្ធដារ | 7.31% | 7.88% | 7.02% | 6.93% | 6.85% | 6.82% |
| ចំណូលមិនមែនសារពើពន្ធ | 1.83% | 1.92% | 1.92% | 1.95% | 2.01% | 2.07% |
| ចំណូលផ្សេងៗ | 0.61% | 0.59% | 0.59% | 0.51% | 0.48% | 0.45% |
| ចំណាយសរុប | 18.09% | 18.39% | 18.39% | 16.83% | 16.57% | 16.74% |
| ចំណាយចរន្តសរុប | 12.54% | 12.62% | 12.62% | 12.05% | 11.84% | 11.47% |
| បន្ទុកបុគ្គលិក | 5.74% | 5.58% | 5.58% | 5.32% | 5.14% | 4.94% |
| បន្ទុកមិនមែនបុគ្គលិក | 6.80% | 7.04% | 7.04% | 6.73% | 6.71% | 6.53% |
| ចំណាយមូលធនសរុប | 5.54% | 5.76% | 5.76% | 4.78% | 4.73% | 5.27% |
| ហិរញ្ញប្បទានក្នុងប្រទេស | 2.31% | 2.43% | 2.43% | 1.60% | 1.71% | 2.07% |
| ហិរញ្ញប្បទានក្រៅប្រទេស | 3.24% | 3.33% | 3.33% | 3.18% | 3.02% | 3.20% |
| អតិរេកចរន្ត | 2.04% | 2.10% | 1.70% | 2.08% | 2.16% | 2.51% |
| ឱនភាពថវិកា | -2.89% | -3.08% | -3.48% | -2.19% | -2.09% | -2.32% |

## ឧបសម្ព័ន្ធ គ៖ ការវិភាគចំណាយថ្នាក់ជាតិតាមវិស័យ

### គ១. ជាប៊ីលានរៀល

| សូចនាករ | 2024ច្ប. | 2025ច្ប. | 2026ព្យ. | 2027ព្យ. | 2028ព្យ. |
|---|---|---|---|---|---|
| **ចំណាយសរុបថ្នាក់ជាតិ** | **34,497** | **35,398** | **35,007** | **37,198** | **40,724** |
| **វិស័យរដ្ឋបាលទូទៅ** | **3,173** | **3,453** | **3,390** | **3,793** | **4,017** |
| ចំណាយចរន្ត | 2,987 | 3,240 | 3,172 | 3,553 | 3,740 |
| ចំណាយមូលធន | 186 | 213 | 218 | 240 | 277 |
| **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | **5,488** | **5,641** | **5,788** | **5,995** | **6,271** |
| ចំណាយចរន្ត | 5,454 | 5,625 | 5,772 | 5,979 | 6,249 |
| ចំណាយមូលធន | 34 | 16 | 16 | 16 | 22 |
| **វិស័យសង្គមកិច្ច** | **9,796** | **10,616** | **10,976** | **11,877** | **12,669** |
| ចំណាយចរន្ត | 9,211 | 9,433 | 9,766 | 10,587 | 11,020 |
| ចំណាយមូលធន | 585 | 1,183 | 1,210 | 1,290 | 1,649 |
| **វិស័យសេដ្ឋកិច្ច** | **7,888** | **8,017** | **8,215** | **8,447** | **9,814** |
| ចំណាយចរន្ត | 1,756 | 1,838 | 1,888 | 1,900 | 1,956 |
| ចំណាយមូលធន | 6,132 | 6,180 | 6,326 | 6,547 | 7,858 |
| **ចំណាយផ្សេងៗ** | **8,152** | **7,671** | **6,638** | **7,087** | **7,952** |
| ចំណាយចរន្ត | 4,398 | 3,767 | 4,189 | 4,347 | 4,627 |
| ចំណាយមូលធន | 3,754 | 3,905 | 2,449 | 2,739 | 3,325 |

### គ២. កំណើនប្រចាំឆ្នាំ

| សូចនាករ | 2024ច្ប. | 2025ច្ប. | 2026ព្យ. | 2027ព្យ. | 2028ព្យ. |
|---|---|---|---|---|---|
| **ចំណាយសរុបថ្នាក់ជាតិ** | **-5.8%** | **2.6%** | **-1.1%** | **6.3%** | **9.5%** |
| **វិស័យរដ្ឋបាលទូទៅ** | **3.0%** | **8.8%** | **-1.8%** | **11.9%** | **5.9%** |
| ចំណាយចរន្ត | 5.1% | 8.5% | -2.1% | 12.0% | 5.3% |
| ចំណាយមូលធន | -21.9% | 14.2% | 2.5% | 9.8% | 15.6% |
| **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | **5.2%** | **2.8%** | **2.6%** | **3.6%** | **4.6%** |
| ចំណាយចរន្ត | 6.9% | 3.1% | 2.6% | 3.6% | 4.5% |
| ចំណាយមូលធន | -69.8% | -53.4% | 0.0% | 0.0% | 37.5% |
| **វិស័យសង្គមកិច្ច** | **9.0%** | **8.4%** | **3.4%** | **8.2%** | **6.7%** |
| ចំណាយចរន្ត | 16.2% | 2.4% | 3.5% | 8.4% | 4.1% |
| ចំណាយមូលធន | -45.0% | 102.4% | 2.3% | 6.6% | 27.8% |
| **វិស័យសេដ្ឋកិច្ច** | **12.0%** | **1.6%** | **2.5%** | **2.8%** | **16.2%** |
| ចំណាយចរន្ត | 11.0% | 4.6% | 2.8% | 0.6% | 3.0% |
| ចំណាយមូលធន | 12.2% | 0.8% | 2.4% | 3.5% | 20.0% |
| **ចំណាយផ្សេងៗ** | **-33.6%** | **-5.9%** | **-13.5%** | **6.8%** | **12.2%** |
| ចំណាយចរន្ត | 29.8% | -14.4% | 11.2% | 3.8% | 6.4% |
| ចំណាយមូលធន | -57.7% | 4.0% | -37.3% | 11.9% | 21.4% |

## គ៣. ជាភាគរយនៃ ផ.ស.ស.

| សូចនាករ | 2024ច្ប. | 2025ច្ប. | 2026ព្យ. | 2027ព្យ. | 2028ព្យ. |
|---|---|---|---|---|---|
| **ចំណាយសរុបថ្នាក់ជាតិ** | **17.98%** | **17.15%** | **15.79%** | **15.55%** | **15.73%** |
| **វិស័យរដ្ឋបាលទូទៅ** | **1.65%** | **1.67%** | **1.53%** | **1.59%** | **1.55%** |
| ចំណាយចរន្ត | 1.56% | 1.57% | 1.43% | 1.49% | 1.44% |
| ចំណាយមូលធន | 0.10% | 0.10% | 0.10% | 0.10% | 0.11% |
| **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | **2.86%** | **2.73%** | **2.61%** | **2.51%** | **2.42%** |
| ចំណាយចរន្ត | 2.84% | 2.73% | 2.60% | 2.50% | 2.41% |
| ចំណាយមូលធន | 0.02% | 0.01% | 0.01% | 0.01% | 0.01% |
| **វិស័យសង្គមកិច្ច** | **5.11%** | **5.14%** | **4.95%** | **4.96%** | **4.89%** |
| ចំណាយចរន្ត | 4.80% | 4.57% | 4.41% | 4.43% | 4.26% |
| ចំណាយមូលធន | 0.30% | 0.57% | 0.55% | 0.54% | 0.64% |
| **វិស័យសេដ្ឋកិច្ច** | **4.11%** | **3.88%** | **3.71%** | **3.53%** | **3.79%** |
| ចំណាយចរន្ត | 0.92% | 0.89% | 0.85% | 0.79% | 0.76% |
| ចំណាយមូលធន | 3.20% | 2.99% | 2.85% | 2.74% | 3.03% |
| **ចំណាយផ្សេងៗ** | **4.25%** | **3.72%** | **2.99%** | **2.96%** | **3.07%** |
| ចំណាយចរន្ត | 2.29% | 1.82% | 1.89% | 1.82% | 1.79% |
| ចំណាយមូលធន | 1.96% | 1.89% | 1.10% | 1.15% | 1.28% |